# សង្គតការណ៍

## ២៣

## ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម



ខៀវ សំផន (ឆ្វេង) និង អៀង សារី នៅក្នុងកម្មវិធីថ្លែងទៅកាន់កងយោធាខ្មែរក្រហមនៅជិតព្រំដែនថៃ ក្នុងអំឡុងឆ្នាំ១៩៨០ ។ រូបថតដោយ J. Kaufmann (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារកម្ពុជា◆ស្វែងរកការពិតដើម្បីការចងចាំនិងយុត្តិធម៌◆www.dccam.org

ខែសីហា ឆ្នាំ២០១៣

# ចាតិកា

ខែសីហា ឆ្នាំ២០១៣



សវនាការស្តាប់សក្ខីកម្ម


៣ សាក្សី សូ សុជាតិ
១០ សាក្សី ស៊ឹម ហោ
១៥ សាក្សី ឡេង ឈឿង
១៨ សាក្សី នូ ម៉ៅ
២២ សវនាការការដាក់បង្ហាញឯកសារ...
២៨ សាក្សី ពេជ ជឹម
៣២ សាក្សី ឡេវ ឡាំ
៣៥ សាក្សី ឯក ហេន
៣៨ សាក្សី ស៊ុំ អាឡាត់
៤២ អង្គជំនុំជម្រះសាលាដំបូងព្រមាន...
៤៣ ខៀវ សំផន នឹងនៅតែបន្តជាប់ឃុំ...
៤៧ ហេតុអ្វីខ្មែរក្រហមជម្លៀសប្រជាជន...
៥០ តើចម្លើយរបស់ដើមបណ្តឹង...



ក្រុមសង្កេតការណ៍ ៖
ឆាយ ឈុនលី, លឹម ជ័យទត្ត,
ឌី សុជាតា, និង ចាន ប្រាថ្នា

ពិនិត្យ និងផ្ទៀងផ្ទាត់ ដោយ វ៉ាន់ថាន់ ពៅដារ៉ា


*គណៈប្រតិភូរបស់រាជរដ្ឋាភិបាលរួបរួមជាតិ ដឹកនាំដោយ សារិន ឆាក (ទីប្រាំរាប់ពីស្តាំ) ក្នុងដំណើរទស្សនកិច្ចនៅ ប្រទេសអាល់បានី ។ ពីឆ្វេងទៅស្តាំ ៖ អ៊ីស៊ុប គន្ធី, ហាក់សៀនឡាយនី និង ហួត សម្បត្តិ ។ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)*

# សវនាការលើសំណុំរឿង០០២/០១ ៖ ការជម្លៀសប្រជាជនដោយបង្ខំក្នុងដំណាក់កាលទី១ និងទី២ និងការសម្លាប់អតីតទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ

### ថ្ងៃទី១០ ខែមិថុនា ដល់ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៣

ចាប់ពីថ្ងៃទី១០ ខែមិថុនា ដល់ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបើកសវនាការស្តាប់សក្ខីកម្មសាក្សីចំនួន ៨រូប ទាក់ទងនឹងការជម្លៀសប្រជាជននៅដំណាក់កាលទី១ និងដំណាក់កាលទី២ ព្រមទាំងការសម្លាប់ទាហាន លន់ នល់ នៅ ទួលពោធិ៍ជ្រៃ ។ សាក្សីទាំងនោះរួមមាន សូ សុជាតិ ជាប្រពន្ធរបស់ជនជាប់ចោទ ខៀវ សំផន, ស៊ឹម ហោ អតីតកងវរសេតូច៣០៦, ឡេង ឈឿង អតីតអ្នកបើករថយន្តឲ្យ ខៀវ សំផន, នូ ម៉ៅ អតីតសមាជិកឃុំ និងធ្លាប់ជាប្រធានសហករណ៍, ពេជ ជឹម អតីតយោធាខ្មែរក្រហម, ឡេវ ឡាំ ក៏ជាអតីតយោធាខ្មែរក្រហម ដែលធ្លាប់បាននាំមនុស្សយកទៅសម្លាប់នៅទួលពោធិ៍ជ្រៃ, ឯក ហេន អតីតអ្នកបម្រើការងារនៅក្នុងមន្ទីរកាត់ដេរ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរ ៨៧០ និងចុងក្រោយសាក្សី ស៊ុំ អាឡាត់ ។ ក្រៅពីស្តាប់សក្ខីកម្មសាក្សីក្នុងអំឡុងពេលនោះដែរ អង្គជំនុំជម្រះបើកសវនាការស្តីអំពីការដាក់ឯកសារគន្លឹះទាក់ទងនឹងអង្គហេតុសហឧក្រិដ្ឋកម្មរួមទម្រង់នៃការទទួលខុសត្រូវ និងតួនាទីរបស់ជនជាប់ចោទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សវនាការនេះអនុញ្ញាតឲ្យភាគីទាំងអស់ដាក់ឯកសារភស្តុតាងដែលពាក់ព័ន្ធទៅនឹងអង្គហេតុខាងលើ ហើយភាគីបដិបក្ខអាចធ្វើការជំទាស់ទៅលើឯកសារទាំងនោះបាន ។

ចំពោះនីតិវិធីក្នុងការសួរដេញដោលសាក្សី ជាទូទៅចាប់ផ្តើមដំបូងសួរដោយសហព្រះរាជអាជ្ញា បន្ទាប់មកក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចុងក្រោយគឺក្រុមមេធាវីការពារក្តីជនជាប់ចោទ ។ ដោយឡែកសាក្សីដែលត្រូវបានកោះហៅឲ្យផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចារិតរបស់ជនជាប់ចោទ (ឧទាហរណ៍ សាក្សី សូ សុជាតិ) នីតិវិធីសួរដេញដោល គឺចាប់ផ្តើមដំបូងដោយក្រុមមេធាវីការពារក្តីជនជាប់ចោទ បន្ទាប់មកក្រុមតំណាងសហព្រះរាជអាជ្ញា និងក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ គួររំឭកថាទាំងសវនាការស្តាប់សក្ខីកម្មរបស់សាក្សី និងសវនាការដាក់ឯកសារគន្លឹះទាក់ទងនឹងតួនាទី និងការទទួលខុសត្រូវរបស់ជនជាប់ចោទគឺមានតែជនជាប់ចោទ ខៀវ សំផន ប៉ុណ្ណោះដែលបានចូលរួមដោយផ្ទាល់ ។ ចំណែកជនជាប់ចោទ នួន ជា ស្នើសុំចូលរួមសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍ដែលរៀបចំទុកនៅក្នុងបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ ដោយសារជនជាប់ចោទរូបនេះមានបញ្ហាសុខភាពមិនអាចចូលរួមសវនាការដោយផ្ទាល់បាន ។



សមាជិកក្រុមការងារគេហ្វ្រោងឃ្លាំមើលសាលាក្តីខ្មែរក្រហមថតរូបអនុស្សាវរីយជាមួយអ្នកចូលរួម បន្ទាប់ការធ្វើបទបង្ហាញ

# សវនាការស្ដាប់សក្ខីកម្មសាក្សី ស៊ូ សុជាតិ

## នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣

### ១) ប្រវត្តិសាវតារសាក្សី ស៊ូ សុជាតិ

សាក្សី ស៊ូ សុជាតិ បានជម្រាបជូនអង្គជំនុំជម្រះទាក់ទងនឹងប្រវត្តិសាវតាររបស់ខ្លួនថា សព្វថ្ងៃមានអាយុ៦២ឆ្នាំ មានទីលំនៅក្នុងសង្កាត់មានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។ មានឪពុកឈ្មោះ ស៊ូ ឈឹម ម្ដាយឈ្មោះ អ៊ុង រៀម និងស្វាមីឈ្មោះ ខៀវ សំផន និងមានកូនបួននាក់ ។

បន្ទាប់មកអង្គជំនុំជម្រះបានជម្រាបជូនសាក្សី ស៊ូ សុជាតិ អំពីសិទ្ធិ និងករណីកិច្ចនៅចំពោះមុខអង្គជំនុំជម្រះ ដោយបញ្ជាក់ថា សាក្សីមានសិទ្ធិក្នុងការបដិសេធក្នុងការឆ្លើយតបនឹងសំណួរ ឬការធ្វើអំណះអំណាងណាមួយ ឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង និងមានសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង ។ សាក្សីមានករណីកិច្ចត្រូវតែឆ្លើយតបរាល់សំណួរដែលសួរដោយភាគី ឬដោយចៅក្រមនៃអង្គជំនុំជម្រះ និងត្រូវឆ្លើយតែអំពីអ្វីដែលពិតដែលសាក្សីបានឃើញ បានឮ បានដឹង បានចងចាំ ឬបានសង្កេត ឬមានបទពិសោធន៍ផ្ទាល់ពាក់ព័ន្ធទៅនឹងអង្គហេតុ ឬក៏ព្រឹត្តិហេតុទាំងឡាយដែលភាគី និងអង្គជំនុំជម្រះនឹងសួរចំពោះសាក្សី ។

អង្គជំនុំជម្រះចោទសួរថា តើសាក្សីធ្លាប់ផ្ដល់បទសម្ភាសន៍ជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេតដែលឬយ៉ាងណា ។ សាក្សី ស៊ូ សុជាតិ បានអះអាងថា គាត់ពុំធ្លាប់ផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេតទេ ។ ដូចជាសាក្សី ទន់ សឿន ដែរ សាក្សី ស៊ូ សុជាតិ បានបញ្ជាក់ជូនអង្គជំនុំជម្រះថា លោកស្រីបានធ្វើសម្បថមុនពេលចូលផ្ដល់សក្ខីកម្មនៅក្នុងសវនាការរួចហើយ ។ ដោយសារ សាក្សី ស៊ូ សុជាតិ មានជាប់សាច់ញាតិជាមួយនឹង ខៀវ សំផន តាមច្បាប់ពុំតម្រូវឲ្យសាក្សីរូបនេះធ្វើសម្បថឡើយ ប៉ុន្តែការណ៍តម្រូវឲ្យសាក្សីធ្វើសម្បថក៏ព្រោះតែអង្គជំនុំជម្រះត្រៀមទុកជាមុន នៅក្នុងករណីដែលសក្ខីកម្មរបស់សាក្សី ស៊ូ សុជាតិ មានជាប់ពាក់ព័ន្ធនឹងជនជាប់ចោទ នួន ជា ដែលពុំមែនជាញាតិ ហើយស្ថិតនៅក្នុងសំណុំរឿង០០២ជាមួយនឹងស្វាមីរបស់លោកស្រី ។

អង្គជំនុំជម្រះបានប្រគល់វេទិកាជូនក្រុមមេធាវីការពារក្ដី ខៀវ សំផន ដើម្បីសួរដេញដោល សាក្សី ស៊ូ សុជាតិ មុនប្រគល់វេទិកាជូនសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងក្រុមមេធាវីការពារក្ដី នួន ជា ។

### ២) ការសួរដេញដោលសាក្សីដោយក្រុមមេធាវីការពារក្ដី ខៀវ សំផន

លោក អាកទ្ធូរ វែកកែន មេធាវីអន្តរជាតិការពារក្ដីជនជាប់ចោទ ខៀវ សំផន បានចាប់ផ្ដើមសំណួរដំបូងរបស់ខ្លួន ដោយស្នើឲ្យសាក្សី ស៊ូ សុជាតិ រៀបរាប់អំពីប្រវត្តិសាវតារដោយលម្អិតសារជាថ្មីឡើងវិញ ។ ឆ្លើយតបនឹងសំណួរនេះ សាក្សី ស៊ូ សុជាតិ បានអត្ថាធិប្បាយថា លោកស្រីមានទីកន្លែងកំណើតនៅភូមិកក់ពោន



ស៊ូ សុជាតិ

ឃុំស្រែធំ ស្រុករវៀង ខេត្តព្រះវិហារ និងមានបងប្អូនទាំងអស់ ៩នាក់ ហើយលោកស្រីជាកូនទី៦ ។ ទាក់ទងនឹងប្រវត្តិនៃការសិក្សា សាក្សី សូ សុជាតិ បានបញ្ជាក់ថា នៅក្នុងឆ្នាំ១៩៦៩ ក្នុងអាយុ១៨ឆ្នាំ លោកស្រីបានបោះបង់ចោលការសិក្សានៅត្រឹមថ្នាក់ទី៥ ដោយសារត្រូវជួយធ្វើស្រែឪពុកម្តាយ ។ បន្ទាប់មកនៅឆ្នាំ១៩៧០ សេនាប្រមុខ លន់ នល់ បានធ្វើរដ្ឋប្រហារ ទម្លាក់សម្តេចព្រះនរោត្តម សីហនុ ចេញពីអំណាច ។ នៅពាក់កណ្តាលឆ្នាំ ១៩៧០ ដោយសារមានការអំពាវនាវឲ្យចូលរួមធ្វើបដិវត្តន៍ដើម្បីយកអំណាចថ្វាយសម្តេច សីហនុ វិញ សាក្សីក៏សម្រេចចិត្តចូលរួមនៅក្នុងចលនាបដិវត្តន៍នោះ ក្នុងតួនាទីជាពេទ្យភូមិ ដោយមានការជួយបង្រៀនពីគ្រូពេទ្យចាស់ៗរយៈពេលបីខែ ។ សាក្សីបញ្ជាក់ថាការចូលរួមចលនាបដិវត្តន៍នេះ ធ្វើឡើងដោយស្ម័គ្រចិត្តដើម្បីប្រឆាំងនឹងពួកចក្រពត្តិ ។ នៅពាក់កណ្តាលឆ្នាំ១៩៧១ អ្នកចូលរួមក្នុងបដិវត្តន៍ប្រមាណ២០០នាក់បានចាកចេញពីស្រុករវៀង ខេត្តព្រះវិហារ ទៅភូមិត្រពាំងទឹម ដែលមានទីតាំងនៅជិតស្ទឹងជីនិត ក្នុងខេត្តកំពង់ធំ ។ សាក្សីបានជួបជាមួយនឹង ប៉ុល ពត, នួន ជា និងខៀវ សំផន នៅទីនោះ ប៉ុន្តែនៅពុំទាន់ស្គាល់ ខៀវ សំផន នៅឡើយទេ ។ សាក្សីស្គាល់តែឈ្មោះ ហែម តែប៉ុណ្ណោះ ។ រយៈពេល៣ ឬ៤ខែក្រោយមក លោកស្រីត្រូវបានស្នើដោយ ខៀវ សំផន តាមរយៈឈ្មោះ យឹម ដើម្បីរៀបការ ។ នៅពេលដំបូងខ្លួនពុំបានដឹងថា ខៀវ សំផន ជានរណាទេ ដោយគ្រាន់តែដឹងតាមរយៈ យឹម ថា ខៀវ សំផន ជាកំឡោះចាស់ និងជាបញ្ញាជន ។ ក្រោយមក ខៀវ សំផន ក៏បានចូលស្នើសុំរៀបការម្តងទៀតតាមរយៈ យឹម ដដែល ពេលនោះខ្លួនក៏សម្រេចចិត្តរៀបការជាមួយ ខៀវ សំផន តែម្តង ។ ពិធីមង្គលការនោះ ពុំត្រូវបានរៀបចំជាលក្ខណៈប្រពៃណីឡើយ ដោយសារតែកំពុងរស់នៅក្នុងព្រៃ ហើយស្ថានភាពត្រូវតម្រូវឲ្យរក្សាការណ៍សម្ងាត់ ។ សាក្សីបានរំឭកថា គាត់រៀបអាពាហ៍ពិពាហ៍ប្រហែលនៅខែធ្នូ ឆ្នាំ ១៩៧២ ហើយក្រោយពេលរៀបការ ត្រូវធ្វើបំលាស់ទីនៅក្នុងព្រៃរហូត ។ ក្រោយពីរៀបការជាមួយនឹង ខៀវ សំផន សាក្សីនៅតែបន្តបំរើការនៅផ្ទះបាយ និងជួយរៀបចំបាយទឹកដដែល ។ សាក្សី សូ សុជាតិ បញ្ជាក់ទៀតថា លោកស្រីចាប់ផ្តើមដឹងថាប្តីរបស់ខ្លួន ឈ្មោះ ខៀវ សំផន នៅពេលអំឡុងពេលនៃកម្មវិធីទទួលសម្តេចព្រះនរោត្តម សីហនុ ហើយថា គាត់ពុំធ្លាប់បានឮឈ្មោះ ខៀវ សំផន ពីមុនមកទេ ។

ឆ្លើយតបនឹងសំណួររបស់មេធាវីទាក់ទងនឹងអត្តចរិតរបស់ ខៀវ សំផន សាក្សី សូ សុជាតិ បញ្ជាក់ជូនអង្គជំនុំជម្រះថា បន្ទាប់ពីរៀបការរួច ខៀវ សំផន ពុំធ្លាប់ធ្វើបាបគាត់ម្តងណាឡើយ មានតែជួយមើលថែ និងជួយធ្វើគ្រប់កិច្ចការទាំងអស់ ក្នុងអំឡុងពេលដែលខ្លួនសម្រាលកូនដំបូង ។ កូនដំបូង កើតនៅថ្ងៃទី៤ ខែ៥ ឆ្នាំ១៩៧៤ ។ សាក្សីបន្តថា នៅ១សប្តាហ៍ក្រោយថ្ងៃរំដោះទី១៧ ខែមេសា ឆ្នាំ១៩៧៥ គាត់បានធ្វើដំណើរមកដល់ទីក្រុងភ្នំពេញ ដោយត្រូវស្នាក់នៅមុំស្ថានីយរថភ្លើង ដើម្បីជួយរៀបចំម្ហូបអាហារ ។ រយៈពេលពីរសប្តាហ៍ក្រោយមក ទើបបានជួបជាមួយនឹង ខៀវ សំផន នៅមន្ទីរ ក-២ ប៉ុន្តែសាក្សីពុំបានដឹងថា ក-២ ជាកន្លែងអ្វីទេ ។ កន្លែងស្នាក់នៅត្រូវបានផ្លាស់ប្តូរជាញឹកញាប់ ចុងក្រោយបង្អស់ គឺមន្ទីរក-១ ដែលមានទីតាំងនៅជាប់ទន្លេបាសាក់ ប៉ុន្តែគាត់នៅតែជាអ្នកជួយរៀបចំបាយទឹកដដែល ។ សាក្សីបានបន្តថា មន្ទីរក-១ គឺជាកន្លែងធ្វើការរបស់មេដឹកនាំជាន់ខ្ពស់ ដូចជា ប៉ុល ពត និង នួន ជា ជាមួយនឹងអ្នកដទៃផ្សេងទៀត ហើយបរិវេទនៃមន្ទីរនោះ គឺហ៊ុំព័ទ្ធស័ង្កសីជុំវិញយ៉ាងជិត ។ ម្ហូបអាហារដែលរៀបចំសម្រាប់អ្នកទាំងអស់នោះ គឺមានត្រឹមតែសម្លកកូរ ឬប្រហើរតែប៉ុណ្ណោះ ។

នៅដើមឆ្នាំ១៩៧៦ សាក្សីបានបញ្ជាក់ថា មេដឹកនាំទាំងអស់បានផ្លាស់ទីតាំងទៅមន្ទីរក-៣ មានដូចជា ប៉ុល ពត, នួន ជា, អៀង សារី, សុន សេន, វន វេត និង ខៀវ សំផន ។ ប៉ុន្តែមេដឹកនាំទាំងអស់នោះស្នាក់នៅមន្ទីរក-៣ប្រហែល៤ឬ៥ខែ តែប៉ុណ្ណោះ បន្ទាប់មកអ្នកទាំងនោះបានចាកចេញទៅកន្លែងផ្សេង ដោយនៅសល់តែ ខៀវ សំផន ម្នាក់ប៉ុណ្ណោះ ដែលបន្តស្នាក់នៅឯមន្ទីរ ក-៣ ។ ប៉ុល ពត និង នួន ជា បានត្រឡប់ទៅធ្វើការនៅមន្ទីរ ក-១វិញ រីឯអ្នកផ្សេងទៀត បានចាកចេញទៅធ្វើការនៅតាមក្រសួងរបស់គេរៀងៗខ្លួន ។ សាក្សី សូ សុជាតិ បានបន្តថា គាត់បានស្នាក់នៅក្នុងមន្ទីរក-៣ជាមួយនឹង ខៀវ សំផន រហូតដល់ពេលដែលវៀតណាមចូលកាន់កាប់ប្រទេសកម្ពុជា ។ ឆ្លើយតប

នឹងសំណួររបស់មេធាវី ដែលសួរទាក់ទងនឹងភារកិច្ចរបស់ ខៀវ សំផន នៅក្នុងមន្ទីរក-៣ សាក្សីបានអះអាងថា ខ្លួនពុំដែលទៅដល់កន្លែងធ្វើការរបស់ ខៀវ សំផន ទេ ហើយក៏ពុំដឹងថា ខៀវ សំផន ធ្វើការងារអ្វីប្រាកដដែរ ប៉ុន្តែគ្រាន់តែបានដឹងថា ខៀវ សំផន រៀបចំអីវ៉ាន់គ្រប់មុខទាំងអស់ រួមមាន អំបិល ប្រហុក ខោអាវ ចាន ឆ្នាំង ដើម្បីដឹកយកទៅមូល-ដ្ឋាន ។ ខៀវ សំផន ម្តងម្កាល បានចាកចេញទៅមន្ទីរក-១ ជាមួយអ្នកបើកឡានឡាំប្រឺតាម្នាក់ ដោយពុំមានអង្គរក្សការពារឡើយ ។

នៅពេលសួរថា ចាប់តាំងពីពេលដែលមេដឹកនាំខ្មែរក្រហមចាកចេញពីមន្ទីរក-៣ទៅ តើមានមនុស្សរស់នៅក្នុងមន្ទីរក-៣ ច្រើននាក់ដែរឬទេ? ហើយថា តើការិយាល័យសកម្មភាពការងារ ឬមានបុគ្គលិកមកធ្វើការងារច្រើនឬទេ? សាក្សី សុជាតិ បានឆ្លើយបញ្ជាក់ថា នៅខាងក្នុងមន្ទីរក-៣ មាន មនុស្សត្រឹមតែ២នាក់ប៉ុណ្ណោះ ទីមួយគឺសាក្សីផ្ទាល់ និងទីពីរ គឺឈ្មោះ អឿន ក្រៅពីនេះគឺមានតែអ្នកយាមនៅខាងក្រៅបរិវេណមន្ទីរនេះប៉ុណ្ណោះ ។

ឆ្លើយតបនឹងសំណួររបស់មេធាវីទាក់ទងនឹងឈ្មោះ ឌឿន សាក្សីអះអាងថា ធ្លាប់ស្គាល់ ឌឿន នៅពេលមកធ្វើការនៅមន្ទីរក-៣ ប៉ុន្តែជួបគ្នាបានត្រឹមតែរយៈ២ទៅ៣ខែប៉ុណ្ណោះ ព្រោះ ឌឿន ខស្សាហ៍ចេញចូលមិនសូវនៅក្នុងមន្ទីរទេ ហើយសាក្សីក៏ពុំធ្លាប់បាននិយាយគ្នាជាមួយនឹង ឌឿន ដែរ ។

មុនពេលបញ្ចប់ការសួរដេញដោល មេធាវីអន្តរជាតិការពារក្តី ខៀវ សំផន, អាកទួរ វែកគែន បានសួរសាក្សី សូ សុជាតិ ថា “តើមូលហេតុអ្វីបានជាលោកស្រីអញ្ជើញមកទីនេះ? តើលោកស្រីចង់ពន្យល់អ្វីជូនតុលាការអំពីការចោទប្រកាន់ចំពោះស្វាមីរបស់លោកស្រី?” ឆ្លើយតបនឹងសំណួរនេះ សាក្សីបានរៀបរាប់យ៉ាងលម្អិតថា ៖

“ខ្ញុំចង់ជម្រាបលោកប្រធានតុលាការ ខ្ញុំមកនេះគឺចង់បង្ហាញថា ប្តីរបស់ខ្ញុំ ទោះបីជា តុលាការត្រូវដាក់ទោស គេចោទប្រកាន់យ៉ាងម៉េចក៏ដោយ ប៉ុន្តែខ្លួនខ្ញុំផ្ទាល់ គឺចង់បង្ហាញថា ប្តីខ្ញុំជាមនុស្សយ៉ាងម៉េចខ្ញុំដឹង ។ គឺជាមនុស្សស្លូតបូត រាបសា ទន់ភ្លន់ មិនប្រកាន់អ្នកណាក៏ដោយ មិនថាក្រ អ្នកមាន គឺប្តីខ្ញុំត្រូវទាំងអស់ ។ ហើយទោះបីជាលំបាកវេទនានៅក្នុងព្រៃមួយរយៈកាលដែលខ្ញុំ និងគាត់បានចាប់ដៃគ្នាជាប្តីប្រពន្ធមក ខ្ញុំឃើញប្តីខ្ញុំស្មោះត្រង់ ខ្ញុំជឿជាក់ស្មោះត្រង់ ទោះបីតុលាការចោទប្រកាន់ ឬក៏អ្នកណាចោទប្រកាន់យ៉ាងម៉េចក៏ដោយ ខ្ញុំសូមអះអាង ខ្ញុំជាប្រពន្ធ គឺមិនមែនស្រួលងាយដូចអ្នកទាំងអស់គ្នាមើលឃើញនោះទេ គឺលំបាកណាស់ ។ លំបាកទាំងក្នុងព្រៃ ជីវភាពលំបាកទាំងការរស់នៅ រត់លូន រហូតមកដល់មានផ្ទះ មានសម្បែង រំដោះហើយ ក៏មិនមានងាយស្រួលដូចអ្នកទាំងអស់គ្នាថានោះទេ គឺលំបាកណាស់ ។

ដូច្នេះ ប្តីខ្ញុំ បើប្រៀបធៀបនឹងប្រុសទាំងអស់ ខ្ញុំឃើញប្តីខ្ញុំល្អជាងគេ ។ ជាពិសេស សីលធម៌ គុណធម៌ មិនដែលធ្វើឲ្យខ្ញុំពិបាកចិត្តដោយសារអំពើអីមួយ គឺអត់ទេ ហើយ ស្មោះត្រង់ក្នុងមួយជីវិតនេះ គឺថាគ្មានបុព្វសិទ្ធិស្អីទាំងអស់ ។ សូម្បីតែផ្ទះ សូម្បីតែរបស់របរប្រើប្រាស់ សូម្បីតែឡាន ដែលអ្នកដឹកនាំទាំងអស់ មានឡាន មានផ្ទះ មានសម្បែង ស្អាតៗ ប្តីខ្ញុំអត់ទេ ។ មួយជីវិតស្មោះត្រង់ គឺត្រង់តែម្តង ។ ត្រង់នេះហើយ ដែលខ្ញុំជឿជាក់ៗប្តីខ្ញុំ គឺមិនមែនជាអ្នកឃោរឃៅកាប់សម្លាប់ ដើរចាប់ដើរចងគេឯងនោះទេ ។ ខ្ញុំសូមធានា គឺឃើញ ខ្ញុំឃើញជាក់ស្តែង ហើយខ្ញុំក៏រស់នៅលំបាកវេទនា ហើយជួយខ្ញុំ ក្នុងរយៈពេល៣ឆ្នាំ កូនចៅយ៉ាងម៉េច អត់យ៉ាងម៉េចក៏ដោយ ព្រោះគាត់អាណិតខ្ញុំណាស់ ។ ខ្ញុំជាស្រីលំបាកណាស់ ។

ហើយខ្ញុំដឹងថា បងប្អូនរងគ្រោះ ដែលនៅកន្លែងជម្លៀស ដែលនៅកន្លែងការដ្ឋាន គេបង្អត់បាយ បង្អត់ទឹក តែខ្ញុំក៏មានការលំបាកដូចតែគ្នាដែរ ។ តែក្នុងហ្នឹង តើហេតុអីបានវាមានអីចឹង ។ ខ្ញុំសូមតុលាការវិនិច្ឆ័យតាមហ្នឹងចុះ ពីព្រោះខ្ញុំធានាប្តីខ្ញុំថា មិនមែនជាអ្នកឃោរឃៅ កាប់សម្លាប់ ឬក៏ធ្វើអ្វីថោកទាប ដើរចាប់ចងមានអំណាច លោភលន់ បុណ្យស័ក្តិ គឺអត់មានទាំងអស់ ។ រស់នៅជាក់ស្តែងតាំងពីឆ្នាំមុន៧៥ ជាក់ស្តែងដូចខ្ញុំបាននិយាយរួចមកហើយ ហើយនិងពេលដែលវៀតណាមចូល មិនដែលបានជួបគ្នាម្តងណាសោះ រហូតដល់ឆ្នាំ៨៣ ។ ៨២-៨៣ បែកគ្នារហូតហើយជួបក៏មួយភ្លែតក៏បែកគ្នាតទៀត ។”

## ៣) ការសួរដេញដោលសាក្សីដោយចៅក្រមអង្គជំនុំជម្រះ

ប្រធានអង្គជំនុំជម្រះ ចៅក្រម និល ណុន បានបន្តប្រគល់វេទិកាសួរដេញដោលជូនចៅក្រម អន្តរជាតិសញ្ជាតិបារាំង ហ្សង់

ម៉ាក ឡាវ៉ែញ ។ ចៅក្រម ឡាវ៉ែញ បានចំណាយពេល២ម៉ោង ដើម្បីចោទសួរសាក្សី សូ សុជាតិ អំពីប្រធានបទជាច្រើន ដូចជា ការជម្លៀសប្រជាជន ប្រព័ន្ធទំនាក់ទំនង ការងារនៅក្នុងគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ របនាសម្ព័ន្ធរដ្ឋបាលថ្នាក់មូលដ្ឋាន គោលនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យ និងការបាត់ខ្លួននៃកម្មាភិបាលខ្មែរក្រហម ។ ប៉ុន្តែសំណួរភាគច្រើនត្រូវបានសាក្សីឆ្លើយបញ្ជាក់ត្រឹមតែពាក្យថា ពុំបានដឹង ។

សំណួរដំបូងរបស់ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែញ បានផ្តោតជាសំខាន់លើឈ្មោះរបស់ ខៀវ សំផន ដែលប្រើនៅក្នុងសំបុត្រអត្រានុកូលដ្ឋាន ដែល ខៀវ សំផន ប្រើឈ្មោះថា ស៊ីឡាង និងសួរទៀតថា តើឈ្មោះនេះត្រូវបានផ្លាស់ប្តូរតាំងពីពេលណា? ឆ្លើយតបនឹងសំណួរនេះ សាក្សី សូ សុជាតិ បានបញ្ជាក់ថា ស៊ីឡាង ជាឈ្មោះដែលបងប្អូននៅផ្ទះហៅតែប៉ុណ្ណោះ រីឯឈ្មោះពិតប្រាកដ គឺឈ្មោះ ខៀវ សំផន ។

ចៅក្រមបានបន្តសួរទាក់ទងនឹងការជម្លៀសប្រជាជននៅស្រុករវៀង ថាតើក្នុងអំឡុងពេលនៃការរំដោះ ប្រជាជននៅស្រុករវៀងត្រូវបានជម្លៀសចេញដែរឬយ៉ាងណា? ឆ្លើយតបនឹងសំណួរនេះ សាក្សីបានអះអាងថា ក្នុងអំឡុងពេលរស់នៅស្រុករវៀង សាក្សីពុំឃើញមានប្រជាជនណាម្នាក់ចាកចេញពីទីនោះទេ ។ រីឯព្រះសង្ឃក៏គង់ក្នុងវត្តនៅឡើយ ប៉ុន្តែនៅពេលដែលសាក្សីចូលរួមចលនាតស៊ូក្នុងព្រៃ លោកស្រីពុំបានដឹងថា នៅក្នុងភូមិមានព្រះសង្ឃទៀតឬយ៉ាងណានោះទេ ។

នៅពេលសួរសំណួរទាក់ទងនឹងការបង្កើតសហករណ៍ និងតួនាទីរបស់ ខៀវ សំផន និងតួនាទីរបស់មេដឹកនាំដទៃទៀតនៅក្នុងការធ្វើបដិវត្តន៍ សាក្សីបានឆ្លើយតបដោយខ្លីៗថា សាក្សីពុំបានដឹងអំពីបញ្ហានេះទេ ដោយសារតែ ខៀវ សំផន ពុំធ្លាប់និយាយប្រាប់អំពីបញ្ហានេះ គឺប្រាប់តែអំពីរឿងផ្ទាល់ខ្លួនប៉ុណ្ណោះ ។ ចៅក្រមសួរបន្តទៀតថា នៅពេលណាទើបសាក្សីដឹងថាប្តីរបស់ខ្លួនមានឋានៈជាឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងជាអគ្គមេបញ្ជាការកងទ័ពប្រជាជនរំដោះជាតិកម្ពុជា? ឆ្លើយតបនឹងសំណួរនេះសាក្សី សូ សុជាតិ បានឆ្លើយបញ្ជាក់ថា សាក្សីពុំបានដឹងអំពីឋានៈប្តីទេ គឺដឹងត្រឹម តែថា ខៀវ សំផន ជាបញ្ញាជន ។ ម្យ៉ាងវិញទៀត ខៀវ សំផន ពុំដែលចាត់ទុកខ្លួនឯងជាអ្នកធំឡើយ ។ បន្ទាប់មកចៅក្រម ឡាវ៉ែញ បានបន្តសួរទៀតថា តើបុគ្គលណាខ្លះដែលបានទៅទទួលសម្តេចព្រះ នរោត្តម សីហនុ នៅតំបន់រំដោះ? សាក្សីបានបញ្ជាក់ថា អ្នកដែលទៅចូលរួមទទួលសម្តេច សីហនុ រួមមាន ប៉ុល ពត និង ខៀវ សំផន និងអ្នកទដៃទៀត ប៉ុន្តែពុំចាប់អារម្មណ៍ថា នរណាជាអ្នកដឹកនាំទៅទទួលព្រះអង្គឡើយ ព្រោះសាក្សីគ្រាន់តែជាអ្នកបម្រើខាងផ្នែកបាយទឹក និងបន្ទប់ ។

នៅពេលសួរសំណួរទាក់ទងទៅនឹងគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍នៃរណសិរ្សរួបរួមជាតិកម្ពុជា សាក្សីបានអះអាងដដែលថា ពុំបានដឹងអំពីចំណុចនេះទេ ព្រោះសាក្សីពុំមែនជាអ្នកនយោបាយ និងពុំមានពេលពិគ្រោះជាមួយប្តីឡើយ ដោយសារមានភារកិច្ចធ្វើបំពេញរៀងៗខ្លួន ។ ទាក់ទងនឹងជនមហាក្បត់ទាំង៧ និងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ សាក្សី សូ សុជាតិ បានអះអាងថា មិន ដឹងអំពីបញ្ហាទាំងនោះទេ ។ ចៅក្រម ឡាវ៉ែញ បន្តសួរទៀតថា នៅក្រោយពេលទីក្រុងភ្នំពេញត្រូវបានរំដោះ តើ ខៀវ សំផន មានប្រាប់អំពីរឿងរាវទាក់ទងនឹងការជម្លៀសប្រជាជនចេញពីទីក្រុងដែរឬទេ?

សាក្សីបានឆ្លើយតបនឹងសំណួរនេះថា ខៀវ សំផន ធ្លាប់និយាយអំពីរឿងជម្លៀសប្រជាជនប្រាប់ខ្លួន បន្ទាប់ពីចូលមកដល់ទីក្រុងភ្នំពេញបានជិតមួយឆ្នាំ ។ ខៀវ សំផន បានអះអាងថា មានក្រុមគ្រួសារ និងមិត្តភក្តិរបស់គាត់ ក៏ស្ថិតនៅក្នុងចំណោមអ្នកដែលត្រូវបានជម្លៀសដែរ ហើយគាត់ក៏មានការព្រួយបារម្ភចំពោះការជម្លៀសនោះដែរ ។ ប៉ុន្តែ ក្រោយមកគិតថា ប្រហែលជាពុំមានបញ្ហាអ្វីកើតឡើងទេ ដោយសារតែអ្នកដែលត្រូវបានជម្លៀសទាំងអស់ប្រហែលជាត្រូវបានផ្តល់កន្លែងឲ្យស្នាក់នៅ ។

ឆ្លើយតបនឹងសំណួររបស់ចៅក្រម ដែលសួរថាតើសាក្សីធ្លាប់ឃើញ កុមារ ទារក មនុស្សចាស់ ស្លាប់ដោយសារអត់ចំណីអាហារហូបចុកគ្រប់គ្រាន់ដែរឬទេ? សាក្សីបញ្ជាក់ថា ពុំធ្លាប់បានឃើញផ្ទាល់ភ្នែក ហើយក៏ពុំបានដឹងអំពីបញ្ហានេះដែរ ដោយសារតែខ្លួនពុំសូវមានឱកាសចាកចេញពីកន្លែងស្នាក់នៅ ។ សាក្សី សូ សុជាតិ បានទទួលស្គាល់ថា នៅក្នុងអំឡុងពេលនោះពិតជាមានការខ្វះខាតអាហារខ្លះៗមែន ប៉ុន្តែសម្រាប់សាក្សីមិនចាត់ទុកថា

ជាការខ្វះខាតទេ ។ បន្ទាប់មកចៅក្រមបានចោទសួរបន្តថា តើនៅពេលនោះមេដឹកនាំ ដូចជា ប៉ុល ពត, នួន ជា, អៀង សារី, វ៉ន វ៉េត មានអាហារបរិភោគគ្រប់គ្រាន់ ដែរឬទេ? និងថា តើ ខៀវ សំផន ធ្លាប់បាននិយាយថា គាត់បានចូលរួមក្នុងកម្មវិធីជប់លៀងដែលមានម្ហូបអាហារឆ្ងាញ់ៗដែរឬទេ? សាក្សី សូ សុជាតិ បានអះអាងថា ការហូបចុករបស់មេដឹកនាំទាំងនោះពុំមានការខ្វះខាតឡើយ ប៉ុន្តែគ្រាន់តែពុំមានម្ហូបអាហារឆ្ងាញ់ៗសម្រាប់ហូប ដោយសារទើបតែងើបចេញពីសង្គ្រាម ។ ពេលនោះក៏ពុំមានអាហារអ្វីសម្រាប់ពិធីជប់លៀងដែរ ម្យ៉ាងវិញទៀត ខៀវ សំផន ក៏ពុំធ្លាប់និយាយប្រាប់អំពីការហូបចុកម្ហូបឆ្ងាញ់ៗដែរ ។ បន្ទាប់ពីទទួលបានចម្លើយពីសាក្សី ចៅក្រម ឡាវ៉េញ ស្នើសុំប្រធានអង្គជំនុំជម្រះដើម្បីបង្ហាញរូបថតមួយសន្លឹក ដែលបង្ហាញអំពីការស្រស់ស្រូបអាហារក្នុងកម្មវិធីជប់លៀងយ៉ាងអធឹកអធមមួយ ដែលមានវត្តមានរបស់ ខៀវ សំផន, អៀង សារី និង ព្រះអង្គម្ចាស់របស់ប្រទេសឡាវ សុផានុវង្ស ។ ចៅក្រមបានបន្តសួរថា តើសាក្សីនៅតែរក្សាចម្លើយរបស់ខ្លួន ដែលនិយាយថា ខៀវ សំផន ពុំដែលចូលរួមនៅក្នុងពិធីជប់លៀង ឬហូបចុកឆ្ងាញ់ទៀតឬយ៉ាងណា? សាក្សី សូ សុជាតិ បានបញ្ជាក់ថា លោកស្រីនៅតែរក្សាចម្លើយដដែល ដោយសារតែនៅពេលនោះលោកស្រីពុំបានដឹង ។

ឆ្លើយតបនឹងសំណួរដែលសួរថា តើ ខៀវ សំផន ធ្លាប់បានពិភាក្សាអំពីការបាត់ខ្លួនអ្នកដែល ធ្លាប់ស្គាល់គ្នាដែរឬយ៉ាងណា? សាក្សី សូ សុជាតិ បានអះអាងថា ខៀវ សំផន ពិតជាធ្លាប់បានប្រាប់អំពីការបាត់ខ្លួនកម្មាភិបាលសំខាន់ៗ ដូចជា ហ៊ូ នឹម, ហ៊ូ យន់ ដែលជាមិត្តជិតស្និទ្ធដោយនិយាយថា អ្នកទាំងនោះពុំគួរបាត់ខ្លួនទេ និងមានចម្ងល់ថា "ហេតុអ្វីបានជាពួកហ្នឹងអញ្ចឹង!" ។

ទាក់ទងនឹងការចាប់ខ្លួនសមាជិកគ្រួសារនៅក្នុងតំបន់១០៣ សាក្សី សូ សុជាតិ បានបញ្ជាក់ថា គាត់បានដឹងអំពីការចាប់ខ្លួនសមាជិកក្រុមគ្រួសារ ដោយមានអ្នកប្រាប់នៅមុនពេលនៃការចូលមកដល់របស់កងទ័ពវៀតណាម ។ សាក្សីបានពន្យល់ចៅក្រមថា ការដោះលែងសមាជិកក្រុមគ្រួសាររបស់គាត់ ចេញពីគុកនៅពេលនោះ ពុំមែនដោយសារការអន្តរាគមន៍របស់ ខៀវ សំផន ទេ គឺដោយសារអន្តរាគមន៍របស់ក្រសួងការបរទេស ដោយសារនៅពេលនោះមានការកត់សម្គាល់ឃើញមានប្រជាជនដែលមានរូបរាងស្គមស្គាំងឈរបោសសំរាមនៅតាមផ្លូវ និងនាំឲ្យក្រសួងមានចម្ងល់ ។ បន្ទាប់មកអ្នកធ្វើការនៅក្នុងក្រសួងរាយការណ៍ជូន ប៉ុល ពត ហើយ ប៉ុល ពត ក៏បានបញ្ជាឲ្យតាមដាន និងបញ្ជាឲ្យដោះលែងអ្នកទាំងអស់នោះ ។ សាក្សីបានបញ្ជាក់បន្ថែមថា សូម្បីតែប្តីរបស់ខ្លួនក៏ពុំបានដឹងអំពីការចាប់ខ្លួននេះដែរ និងសួរមកខ្លួនវិញថា "តើនរណាជាអ្នកចាប់មានដឹងទេ?" ។

ឆ្លើយតបនឹងសំណួររបស់ចៅក្រមទាក់ទងនឹងខ្មាំងស៊ីរ៉ូងផ្ទៃក្នុង និងខ្មាំងខាងក្រៅ សាក្សីបានអះអាងថា នៅក្នុងមន្ទីរដែលខ្លួនស្នាក់នៅមានការស្នើឲ្យមានការប្រុងប្រយ័ត្ន ដោយសារមានខ្មាំងចង់បំផ្លាញអង្គការ ។ សូម្បីនៅក្នុងផ្ទះបាយក៏ត្រូវតែប្រុងប្រយ័ត្នដែរ ។

បន្ទាប់ពី ចៅក្រម ហ្សង់ម៉ាក ឡាវ៉េញ បញ្ចប់ការសួរដេញដោលសាក្សីប្រធានអង្គជំនុំជម្រះ ចៅក្រម និល ណុន បានប្រគល់វេទិកាជូនតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តចោទសួរសាក្សី សូ សុជាតិ ទាក់ទងនឹងអត្តចរិករបស់ជនជាប់ចោទ ខៀវ សំផន ។

### ៤) ការសួរដេញដោលសាក្សីដោយតំណាងសហព្រះរាជអាជ្ញា

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ឃីត វ៉េន័រ បានចាប់ផ្តើមសំណួរដោយផ្តោតជាសំខាន់ លើការចាប់ខ្លួន ហ៊ូ នឹម និង ហ៊ូ យន់ ដែលជាបញ្ញាជនអ្នកតស៊ូ និងធ្លាប់ជាមិត្តជិតស្និទ្ធរបស់ ខៀវ សំផន ។ តំណាងសហព្រះរាជអាជ្ញា វ៉េន័រ សួរសាក្សី សូ សុជាតិ ថា តើ ខៀវ សំផន ធ្លាប់បានពិភាក្សា អំពីការចាប់ខ្លួន ហ៊ូ នឹម និង ហ៊ូ យន់ ជាមួយនឹងសាក្សីដែរឬទេ? ពាក់ព័ន្ធនឹងសំណួរនេះ សាក្សីបានថ្លែងថា ខៀវ សំផនពិតជាធ្លាប់បានពិភាក្សាអំពីការចាប់ខ្លួនហ៊ូ នឹម និង ហ៊ូ យន់ ជាមួយសាក្សីពិតមែន ប៉ុន្តែការសន្ទនានោះធ្វើឡើងនៅក្រោយការដួលរលំនៃរបបខ្មែរក្រហម ។ សាក្សីបន្តថា ខៀវ សំផន ពុំ ធ្លាប់ប្រាប់នរណាជាអ្នកបញ្ជាឲ្យចាប់ខ្លួននោះទេ ប៉ុន្តែគ្រាន់តែប្រាប់ថា "មនុស្សខំមកកំសត់កម្រទាំងអស់គ្នា ហើយដល់មកបាត់អីចឹង" ។

តំណាងសហព្រះរាជអាជ្ញាបានបន្តសួរថា ចាប់តាំងពីឆ្នាំ ១៩៧៩ តើសាក្សីធ្លាប់ជជែកជាមួយ ខៀវ សំផន អំពីការមូលហេតុនៃការស្លាប់របស់ប្រជាជនច្រើននាក់នៅក្នុងរបបកម្ពុជា

ប្រជាធិបតេយ្យដែរឬទេ? សាក្សី សូ សុជាតិ បានថ្លែងបញ្ជាក់ចំពោះសំណួរនេះថា សាក្សីពិតជាបានសួរ ខៀវ សំផន អំពីចំណុចនេះ ហើយ ខៀវ សំផន បានឆ្លើយប្រាប់ថា ប្រជាជនដែលត្រូវបានជម្លៀស ត្រូវបានបង្កត់បាយ និងគួរឲ្យរន្ធត់ខ្លោចផ្សា ប៉ុន្តែពុំមាននិយាយអំពីបញ្ហាប្រជាជនដែលត្រូវបានចោទប្រកាន់ថា បានពាក់ព័ន្ធនឹង សេ.អ៊ី.អា ទេ។

បន្ទាប់មក តំណាងសហព្រះរាជអាជ្ញា វែន៍រ បានលើកយកឯកសារជាច្រើនដើម្បីស្នើឲ្យសាក្សីបញ្ជាក់ មានដូចជា សំបុត្រដែល ហ៊ូ នឹម សរសេរផ្ញើជូនមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ ក្រោយពេលត្រូវបានចាប់ខ្លួន ដើម្បីតវ៉ាអំពីការចាប់ខ្លួន, បទសម្ភាសន៍រវាង ខៀវ សំផន និង ស៊្មីវ ហេដឌ័រ និងកំណត់ហេតុកិច្ចប្រជុំនៃគណៈអចិន្ត្រៃយ៍ ។ល។ ប៉ុន្តែរាល់សំណើសុំការបញ្ជាក់លើឯកសារទាំងអស់នោះត្រូវបានសាក្សី សូ សុជាតិ ថ្លែងបញ្ជាក់ថា សាក្សីពុំបានដឹង និងពុំមានលទ្ធភាពដើម្បីឆ្លើយតបនឹងសំណួរទាំងនោះបានទេ ដោយសារសាក្សីជាអ្នកដាំបាយពុំមែនជាអ្នកនយោបាយទេ។

ឆ្លើយតបនឹងសំណួរទាក់ទងនឹងការជួបទាក់ទងនឹងមេធាវីការពារក្ដីជនជាប់ចោទ ខៀវ សំផន និង ការជួបជាមួយនឹងជនជាប់ចោទ ខៀវ សំផន ដោយផ្ទាល់មុនពេលចូលមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ សាក្សី សូ សុជាតិ បានអះអាងថា គាត់ពិតជាបានជួបជាមួយនឹង ខៀវ សំផន ពិតមែន ដោយជួបមួយសប្ដាហ៍ម្ដងពីរដង ឬពេលខ្លះជួបបីដង។ សាក្សីបានបន្ថែមថា គាត់ក៏បានជួបជាមួយនឹងមេធាវីរបស់ ខៀវ សំផន ដែល ដោយសារមេធាវីបានអញ្ជើញគាត់ឲ្យចូលរួមផ្ដល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ ខៀវ សំផន។

បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ វែន៍រ បានលើកយកស្នើឲ្យសាក្សីធ្វើការបញ្ជាក់ លើចម្លើយរបស់សាក្សី ស សៀក និង សាក្សី មាស វឿន ដែលធ្លាប់បានចូលផ្ដល់សក្ខីកម្មនៅចំពោះអង្គជំនុំជម្រះ ហើយសក្ខីកម្មទាំងនោះមានជាប់ទាក់ទងនឹង ខៀវ សំផន ដែលបានធ្វើអន្តរាគមន៍ដើម្បីឲ្យមានការដោះ


ខៀវ សំផន (ស្ដាំ) កំពុងជួបពិភាក្សាជាមួយព្រះអង្គម្ចាស់ សុជានុវង្ស នៃប្រទេសឡាវ ក្នុងអំឡុងពេលដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់ព្រះអង្គនៅប្រទេសកម្ពុជា ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨។ (ប្រភពរូបថត៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

លែងបង់ថ្លៃរបស់ខ្លួន ដែលត្រូវជាបងរបស់សាក្សី សូ សុជាតិ ។ ប៉ុន្តែ សាក្សី សុជាតិ បានបដិសេធ ដោយអះអាងថា សាក្សីពុំបានដឹងអំពីការលើកឡើងរបស់សាក្សី មាស វឿន ទាក់ទងនឹងការធ្វើអន្តរាគមន៍របស់ ខៀវ សំផន ដើម្បីឲ្យមានការដោះលែងបងរបស់ខ្លួនទេ និងថា ការលើកឡើងនោះ គ្រាន់តែជាចម្លើយរបស់ មាស វឿន តែប៉ុណ្ណោះ ។

តំណាងសហព្រះរាជអាជ្ញាបានបន្តសួរសំណួរ ដោយលើកយកសម្តីដែលសាក្សី សូ សុជាតិ បានឆ្លើយនៅចំពោះមុខមេធាវីការពារក្តី ខៀវ សំផន ដើម្បីសាក្សីបញ្ជាក់បន្ថែមឲ្យកាន់តែច្បាស់ និងចោទសួរ ដោយព្យាយាមបង្ហាញថា ខៀវ សំផន ពិតជាបានធ្វើការរួមគ្នាជាមួយនឹងមេដឹកនាំផ្សេងទៀតនៅក្នុងមន្ទីរក-៣ អំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ តំណាងសហព្រះរាជអាជ្ញា វែន័រ បានបង្ហាញសាក្សីនូវសម្តីរបស់ ខៀវ សំផន ដែលធ្លាប់បានលើកឡើងថា «ចំពោះជីវិតប្រចាំថ្ងៃ ប៉ុល ពត និង នួន ជា បានហូបបាយជាមួយនឹងខ្ញុំ ហើយយើងហូបបាយជាមួយគ្នា ។ យើងមិនធ្វើអ្វីដាច់ដោយឡែកពីគ្នាទេ» ។ សាក្សី សូ សុជាតិ បានបដិសេធការលើកឡើងរបស់តំណាងសហព្រះរាជអាជ្ញា ដោយអះអាងថា ខៀវ សំផន ពុំបានធ្វើការជាមួយនឹងមេដឹកនាំដទៃផ្សេងទៀតនៅក្នុងមន្ទីរក-៣ទេ ដោយសារតែនៅពេលនោះ មេដឹកនាំទាំងអស់បានចាកចេញពីមន្ទីរក-៣ ដើម្បីធ្វើការនៅតាមក្រសួង និងស្ថាប័នរបស់គេរៀងៗខ្លួនអស់ទៅហើយ ។ ទោះបីជាយ៉ាងណា សាក្សីបានទទួលស្គាល់ថា នៅពេលទទួលទានអាហារ មេដឹកនាំទាំងអស់រួមជាមួយនឹង ខៀវ សំផន ផង បានស្រស់ស្រូបរួមគ្នានៅក្នុងមន្ទីរក-៣ ។

បន្ទាប់មក តំណាងសហព្រះរាជអាជ្ញា វែន័រ បន្តលើកយកចម្លើយរបស់សាក្សីមុនៗដែលបានផ្តល់សក្ខីកម្មទាក់ទងនឹង ខៀវ សំផន នៅចំពោះមុខអង្គជំនុំជម្រះ ដើម្បីឲ្យសាក្សីបញ្ជាក់ថា តើចម្លើយរបស់អ្នកទាំងនោះត្រឹមត្រូវដែរឬយ៉ាងណា ។ ក្នុងនោះរួមមានចម្លើយរបស់សាក្សី អឿន តាន ដែលជាប្រធានសន្តិសុខនៅមន្ទីរក-១ និងកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ឡេង ឈឿង ជាអតីតអ្នកបើកឡានជូន ខៀវ សំផន ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានអះអាងថា អំឡុងឆ្នាំ ១៩៧៨ អៀង សារី និង នួន ជា បានស្នាក់នៅក្នុងមន្ទីរក-៣ ដែរ ។ សាក្សីបានបញ្ជាក់ថា នួន ជា ពិតជាធ្លាប់បានមន្ទីរក-៣ មួងម្កាលមែន ប៉ុន្តែ នួន ជា ពុំបានស្នាក់នៅមន្ទីរក-៣ទេ គឺស្នាក់នៅមន្ទីរក-១ ។ តំណាងសហព្រះរាជអាជ្ញាបន្តលើកយកសម្តីរបស់ ខៀវ សំផន ទាក់ទងនឹងការស្នាក់នៅមន្ទីរក-៣ មកបង្ហាញសាក្សីទៀតថា «ចំពោះខ្លួនខ្ញុំផ្ទាល់ ខ្ញុំរស់នៅក-៣ បន្ទាប់ពីបានស្នាក់នៅក-១ បាន១ ឬ២ខែ បន្ទាប់ពីបានប្តូរមកពីប្រាសាទព្រះកែវមរកតនៅបរមរាជវាំង ។ ...តាមពិតមេដឹកនាំភាគច្រើនស្នាក់នៅក-៣ ដូចជា អៀង សារី, សុន សេន, នួន ជា ។ ចំណែកឯ ប៉ុល ពត វិញ គាត់បាន មកស្នាក់នៅក-៣ម្តងម្កាល» ។ ឆ្លើយតបនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញានៅត្រង់ផ្នែកនេះ សាក្សី សូ សុជាតិ បានបែងចែកកាលបរិច្ឆេទនៃការស្នាក់នៅរបស់មេដឹកនាំនៅក្នុងមន្ទីរក-៣ជាដំណាក់ៗថា នៅពេលដំបូងមេដឹកនាំទាំងអស់ រួមមាន ប៉ុល ពត, នួន ជា, អៀង សារី, សុន សេន ឌឿន វន វេត បានស្នាក់នៅមន្ទីរក-១មួយរយៈ បន្ទាប់មកអ្នកទាំងអស់នោះបានផ្លាស់ទៅស្នាក់នៅមន្ទីរក-៣ ។ ក្រោយពីស្នាក់នៅបានមួយរយៈ អ្នកទាំងអស់នោះបានចាកចេញពីមន្ទីរក-៣ទាំងអស់គ្នា ។

គួរកត់សម្គាល់ថា ការផ្តោតសំខាន់លើការធ្វើការរួមគ្នានៅមន្ទីរក-៣ រវាង ខៀវ សំផន និងមេដឹកនាំផ្សេងទៀត ដោយតំណាងសហព្រះរាជអាជ្ញា ដោយសារតែសហព្រះរាជអាជ្ញាព្យាយាមបង្ហាញជូនអង្គជំនុំជម្រះថា ខៀវ សំផន ប្រហែលជាបានរួមចំណែកក្នុងការធ្វើសេចក្តីសម្រេចនានាជាមួយនឹងមេដឹកនាំផ្សេងៗទៀតនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ប៉ុន្តែ ការសម្រេចថា ខៀវ សំផន បានចូលរួមក្នុងការធ្វើសេចក្តីសម្រេច ឬក៏មិនមែនជាសមត្ថកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយផ្អែកលើភស្តុតាង និងចម្លើយរបស់សាក្សីដែលគួរឲ្យជឿជាក់បាន ។

### ៥) ការសួរដេញដោលសាក្សីដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

មេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោក ហុង គីមសួន ត្រូវបានអង្គជំនុំជម្រះផ្តល់វេទិកាចោទសួរសាក្សី សូ សុជាតិ ទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ ខៀវ សំផន ។

មេធាវី គឹមសួន បានសួរសំណួរដោយផ្តោតជាសំខាន់លើប្រវត្តិសាវតាររបស់សាក្សី ។ សាក្សី សូ សុជាតិ បានឆ្លើយតបនឹងសំណួររបស់មេធាវី ដោយរៀបរាប់សារជាថ្មីឡើងវិញនូវចម្លើយដែលខ្លួនធ្លាប់បានឆ្លើយតបចំពោះមេធាវីការពារក្តី ខៀវ សំផន និងសហព្រះរាជអាជ្ញា ។ ដោយសារតែសំណួរភាគីច្រើនរបស់មេធាវី គឹមសួន មានលក្ខណៈដូចគ្នាទៅនឹងសំណួរដែលភាគីមុនៗបានសួររួចហើយ អង្គជំនុំជម្រះបានបង្គាប់ឲ្យមេធាវីផ្លាស់ប្តូរសំណួររបស់ខ្លួន ដើម្បីចំណេញពេលវេលា ។

បន្ទាប់មកមេធាវី គឹមសួន បានបន្តចោទសួរទាក់ទងនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ឆ្លើយតបនឹងសំណួរនេះ សាក្សី សុជាតិ បានថ្លែងថា សាក្សីបានចូលមកទីក្រុងភ្នំពេញ ក្រោយទីក្រុងភ្នំពេញត្រូវបានរំដោះមួយសប្តាហ៍ ដូច្នេះនៅតាមផ្លូវចូលក្នុងទីក្រុង សាក្សីពុំបានឃើញមានមនុស្សទេ ។ សាក្សីបន្តថា សាក្សីធ្វើដំណើរចូលមកទីក្រុងភ្នំពេញតាមរយៈម៉ូតូ និងមានឈ្មោះ សែម ជាអ្នកជូន ។

មេធាវីបានបន្តសួរថា នៅអំឡុងពេលរស់នៅទីក្រុងភ្នំពេញក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើសាក្សីធ្លាប់បានដឹងអំពីសំបុត្រអនុញ្ញាតឲ្យធ្វើដំណើរ មុនពេលចាកចេញទៅទីណាកន្លែងណាដែរឬទេ? ឆ្លើយតបនឹងសំណួរនេះ សាក្សីបានឆ្លើយបញ្ជាក់យ៉ាងខ្លីថា ខ្លួនពុំបានដឹងអំពីសំបុត្រអនុញ្ញាតឲ្យធ្វើដំណើរទេ ។ ចំពោះសំណួរទាក់ទងនឹងតួនាទីរបស់ ខៀវ សំផន នៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ សាក្សី សូ សុជាតិ បានអះអាងថា ខ្លួនពុំបានដឹងអំពីតួនាទីប្តីរបស់ខ្លួនទេ នៅអំឡុងពេលនៃរបបនោះ ។

ឆ្លើយតបនឹងសំណួររបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហុង គឹមសួន ដែលសួរថា ក្រោយពេលនៃការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ តើសាក្សីបានដឹងអំពីវិនាសកម្មនៅក្នុងសម័យខ្មែរក្រហមកាន់កាប់ប្រទេស ដូចជាការស្លាប់ប្រជាពលរដ្ឋរាប់លាននាក់ដែរឬទេ? សាក្សី សូ សុជាតិ បានបញ្ជាក់ថា នៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ សាក្សីពុំបានដឹងអំពីបញ្ហានេះទេ ប៉ុន្តែក្រោយមកទើបបានដឹង ។

សហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី អេលីហ្សាប៊ែត ស៊ីម៉ូណូហ្វត បានបន្តពីសហភាតាជាតិរបស់ខ្លួន ដើម្បីចោទសួរសាក្សី សូ សុជាតិ ។ មេធាវី ស៊ីម៉ូណូហ្វត បានសួរទាក់ ទងនឹងការថ្លែងសុន្ទរកថារបស់ ខៀវ សំផន ថា តើសាក្សីធ្លាប់បានស្តាប់ការថ្លែងសុន្ទរកថារបស់ ខៀវ សំផន នៅអំឡុងពេលនៃការប្រារព្ធខួបរំដោះទីក្រុងភ្នំពេញ ឬសុន្ទរកថានៅក្នុងឱកាសផ្សេងៗទៀតដែរឬទេ? សាក្សី សូ សុជាតិ ហាក់បីដូចជាពុំពេញចិត្តនឹងសំណួរនេះ ប៉ុន្តែបានឆ្លើយតបយ៉ាងខ្លីថា នៅអំឡុងពេលនោះ សាក្សីពុំដែលបានស្តាប់សុន្ទរកថាទេ ដោយសារជាប់រវល់ និងថា កន្លែងធ្វើការរបស់សាក្សីពុំមានវិទ្យុស្តាប់ ។ នៅពេលសួរទាក់ទងនឹងការចូលរួមក្នុងកិច្ចប្រជុំនានា ក៏សាក្សីបានឆ្លើយថា សាក្សីពុំដែលបានចូលរួមកិច្ចប្រជុំសូម្បីតែម្តង ។ សាក្សីបានឆ្លើយទៅកាន់មេធាវីទៀតថា ប្តីរបស់គាត់ នៅមុនឆ្នាំ១៩៧៥ ពុំមែនជាមេដឹកនាំជាន់ខ្ពស់ទេ ហើយនៅក្រោយឆ្នាំ១៩៧៥ សាក្សីពុំបានដឹងអំពីតួនាទីប្តីរបស់ខ្លួនឡើយ គ្រាន់តែដឹងថា ប្តីគាត់ធ្លាប់ទៅមន្ទីរក-១ម្តងម្កាលដើម្បីជួបជាមួយនឹងសម្តេច សីហនុ ។ នៅពេលដែលមេធាវី ស៊ីម៉ុនណូហ្វត សួរថា នៅចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩ តើសាក្សីពិតជាពុំបានដឹងអ្វីទាំងអស់ពីរបបខ្មែរក្រហមមែន ឬយ៉ាងណា? សាក្សី សូ សុជាតិ បានអះអាងថា លោកស្រីពុំបានដឹងអ្វីទាំងអស់ ។

នៅពេលដែលមេធាវី ស៊ីម៉ូណូហ្វត សួរថា រយៈពេលជាង ៣០ឆ្នាំ ចាប់តាំងពីឆ្នាំ១៩៧៩ រហូតមកដល់ពេលបច្ចុប្បន្ន ”លោកស្រីនៅតែមិនដឹងថាប្តីរបស់លោកស្រីមានមុខងារអ្វីទេ? តើត្រឹមត្រូវទេ? សាក្សី សូ សុជាតិ បានសម្តែងការមិនពេញចិត្តចំពោះសំណួរនេះ និងបានថ្លែងថា «អាហ្នឹងលោកស្រី យល់យ៉ាងម៉េចអាហ្នឹងរឿងរបស់លោកស្រី ។ ព្រោះខ្ញុំមកនេះ មិនមែនជាការដឹងថា អ្នកណាយល់យ៉ាងម៉េចៗទេ ។ លោកស្រីជាអ្នកតាមដាន លោកស្រីយល់យ៉ាងម៉េច អាហ្នឹងគឺជារឿងរបស់លោកស្រី» ។ ចុងក្រោយ សាក្សីបានបញ្ជាក់យ៉ាងខ្លីថា «ជាហូរហែមក ខ្ញុំមិនស្មានប្តីខ្ញុំជាអ្នកធំ » ។

កិច្ចដំណើរការនីតិវិធីសួរដេញដោលសាក្សី សូ សុជាតិ ស្តីអំពីអត្តចរិតរបស់ជនជាប់ចោទ ខៀវ សំផន បានបញ្ចប់នៅព្រឹកថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៣ ។

# សវនាការស្តាប់សក្ខីកម្មសាក្សី ស៊ឹម ហោ

## ថ្ងៃទី១២-១៣ ខែមិថុនា ឆ្នាំ២០១៣

នៅថ្ងៃទី១២-១៣ ខែមិថុនា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបន្តសវនាការជាធម្មតា ដោយកោះហៅសាក្សី ស៊ឹម ហោ មកផ្តល់សក្ខីកម្មបន្ទាប់ពីបញ្ចប់សវនាការសួរដេញដោលសាក្សី សូ សុជាតិ ។ ស៊ឹម ហោ ធ្លាប់បានផ្តល់បទសម្ភាសន៍ជាមួយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាម្តងរួចមកហើយកាលពីឆ្នាំ២០០៣ ហើយក្រោយមកបានផ្តល់បទបទសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅឆ្នាំ២០០៨ ។ សវនាការសួរដេញដោលសាក្សីរូបនេះ បានផ្តោតសំខាន់ទៅលើការងាររបស់សាក្សី ដែលជាកងទ័ពខ្មែរក្រហម ការងារទៅក្នុងក្រសួងពាណិជ្ជកម្ម ការចាប់ខ្លួនកម្មាភិបាលថ្នាក់ក្រោមបន្ទាប់ពីមានការចាប់ខ្លួន កុយ ធួន ជាលេខាភូមិភាគឧត្តរ និងសកម្មភាពរបស់ ខៀវ សំផន ទាក់ទងនឹងក្រសួងពាណិជ្ជកម្ម ។ ចំពោះនីតិវិធីនៃការសួរដេញដោលសាក្សីរូបនេះ បានប្រព្រឹត្តទៅតាមលំដាប់លំដោយពីអង្គជំនុំជម្រះ តំណាងសហព្រះរាជអាជ្ញា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តីជនជាប់ចោទទាំងពីរក្រុម ។

### ១) ការសួរដេញដោលដោយប្រធានអង្គជំនុំជម្រះ

ជាការចាប់ផ្តើម លោកចៅក្រម និល ណុន បានសួរសំណួរមួយចំនួនទាក់ទងនឹងប្រវត្តិសវិតារបស់សាក្សី ។ សាក្សី ស៊ឹម ហោ មានអាយុ៦២ឆ្នាំ រស់នៅភូមិត្រាច ឃុំកំពង់ចិនខាងជើង ស្រុកស្ទោង ខេត្តកំពង់ធំ និងមានមុខរបរជាប្រធានភូមិ ។ សាក្សីមានឪពុកឈ្មោះ ស៊ឹម និងម្តាយឈ្មោះ ប្រាក់ ។ ចំណែកប្រពន្ធឈ្មោះ យ៉ត និងមានកូនប្រាំមួយនាក់ ។

ទាក់ទងនឹងបទសម្ភាសន៍ដែលធ្លាប់ធ្វើកន្លងមក សាក្សីបានបញ្ជាក់ថា ខ្លួនធ្លាប់បានផ្តល់បទសម្ភាសន៍ ជាមួយសហចៅក្រមស៊ើបអង្កេតចំនួនពីរដងរួចមកហើយ ។ បន្ទាប់មក អង្គជំនុំជម្រះបានបញ្ជាក់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់សាក្សីក្នុងការចូលរួមសវនាការនេះ ។

### ២) ការសួរដេញដោលសាក្សីដោយតំណាងសហព្រះរាជអាជ្ញា

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ វីរំងសង់ ដឺវ៉ាលដេស្មាឯល បានចាប់ផ្តើមដោយសួរសាក្សី ថាតើសាក្សីធ្លាប់បានផ្តល់បទសម្ភាសន៍ជាមួយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាដែរឬទេ ។ សាក្សីបានទទួលស្គាល់ថា ខ្លួនពិតជាធ្លាប់បានផ្តល់បទសម្ភាសន៍ពិតមែនកាលពីឆ្នាំ២០០៣ ។ តំណាងសហព្រះរាជ



អៀង សារី (ទីបួនរាប់ពីស្តាំ) កំពុងនាំគណៈប្រតិភូចិន ដឹកនាំដោយ វ៉ាំង
គណៈប្រតិភូចិនទស្សនាព្រះបរមរាជវាំង និងតំបន់ផ្សេងៗទៀតទូទាំងទីក្រុង
ហាន ធៀនឡុង អនុរដ្ឋមន្ត្រីការបរទេសចិន, ហ៊ូ យ៉ាវបាន អគ្គលេខាធិកា
និង ស៊ីន ជា អនុប្រធានផ្នែកទំនាក់ទំនងអន្តរជាតិនៃបក្សកុម្មុយនីស្តចិន ។ (

អាជ្ញាអន្តរជាតិបានបន្តដោយលើកយកប្រវត្តិរូបរបស់សាក្សីមកបង្ហាញ ហើយសាក្សីក៏បានទទួលស្គាល់ថា ប្រវត្តិរូបនោះខ្លួនបានសរសេរដោយផ្ទាល់ដៃប៉ុន្តែពុំចាំថា អ្នកណាជាអ្នកបញ្ជាឲ្យខ្លួន

សរសេរនោះទេ ។

សាក្សីបានរៀបរាប់ថា បានចូលធ្វើជាកងទ័ពខ្មែរក្រហម នៅឆ្នាំ១៩៧២ ក្នុងកងវរសេនាតូច៧០៤ ដោយសារពេលនោះ មានការជ្រើសរើសទ័ពដើម្បីប្រឆាំងនឹងវៀតណាម ។ តំណាងសហព្រះរាជអាជ្ញា អន្តរជាតិបានបន្តអានសេចក្តីដកស្រង់នៅក្នុងឯកសារប្រវត្តិរូបរបស់សាក្សី ដែលមានសរសេរថា "យោធាអង្គភាព គឺវរសេនាតូច៣០៦" ដើម្បីឲ្យសាក្សីពន្យល់ ។ ត្រង់ចំណុចនេះ សាក្សីបានបញ្ជាក់ថា សាក្សីមាននាទីជាកងទ័ពវរសេនាតូច៣០៦ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ប្រធានកងពលឈ្មោះ តាពក នៅក្នុងភូមិភាគឧត្តរ ។ បន្ទាប់មក បានផ្លាស់ទៅធ្វើទ័ពនៅកងវរសេនាតូច៧០៩វិញ ក្នុងខេត្តសៀមរាប ដែលមានប្រធានកងវរសេនាតូចឈ្មោះ តាបេង ។ ទាក់ទងនឹងវិន័យរបស់កងទ័ពវិញ សាក្សីគ្រាន់តែបានបញ្ជាក់ថា ថ្នាក់ក្រោមពុំអាចមានសិទ្ធិជំទាស់នឹងការបញ្ជារបស់ថ្នាក់លើបានទេ ។ នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧២ សាក្សី ស៊ឹម ហោ បានទៅច្បាំងជាមួយទាហាន លន់ នល់ នៅខេត្តសៀមរាប ហើយត្រឡប់មកច្បាំងនៅខេត្តកំពង់ធំ ម្តុំស្រយ៉ូវ ។ នៅពេលនោះ សាក្សីបានរងរបួស ហើយពុំបានចូលរួមរំដោះទីក្រុងភ្នំពេញទេ គ្រាន់តែបានដឹងអំពីផែនការជាមុនតែប៉ុណ្ណោះ ។ បន្ទាប់ពីការដួលរលំនៃទីក្រុងភ្នំពេញ ហោ ត្រូវបានបញ្ជូនឲ្យទៅធ្វើកម្មករនៅកំពង់សោមរយៈពេលមួយឆ្នាំ ហើយក្រោយមក បានត្រឡប់មកនៅប្រាំងចំរេះ និងធ្វើជាកម្មករនៅក្នុងក្រសួងពាណិជ្ជកម្ម ជាអ្នកលីសែង និងវាយសំឡីក នៅក្នុងវត្តទួលទំពូងវិញ ។


...ដុងស៊ីង (ទីបីរាប់ពីស្តាំ) ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨ ។ អៀង សារី បាននាំ...ភ្នំពេញ ។ ពីឆ្វេងទៅស្តាំ ៖ ស៊ុន ហាវ អគ្គរដ្ឋទូតចិនប្រចាំរបបខ្មែរក្រហម, ...នៃបក្សកុម្មុយនីស្តចិន, មិនស្គាល់, អៀង សារី, វ៉ាំង ដុងស៊ីង, មិនស្គាល់ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ឆ្លើយតបនឹងសំណួរបន្ទាប់របស់តំណាងសហព្រះរាជអាជ្ញា ទាក់ទងនឹងការចូលមកដល់ទីក្រុងភ្នំពេញ សាក្សីបានបញ្ជាក់ថា បានចូលមកដល់ទីក្រុងភ្នំពេញក្រោយពេលទទួលបានជ័យជម្នះរយៈពេលបីថ្ងៃ ហើយនៅពេលនោះសាក្សី និងកងទ័ពដទៃទៀតបានទៅប្រមូលផ្តុំនៅគីឡូលេខ៦ ក្នុងសង្កាត់ប្រាំងចំរេះ ដើម្បីប្រជុំអបអរសាទរជ័យជម្នះ ។ នៅទីនោះ ហោ បានឃើញប្រជាជនដែលជម្លៀសចេញពីទីក្រុងភ្នំពេញ ដោយធ្វើដំណើរកាត់គីឡូម៉ែត្រលេខ៦ ប៉ុន្តែក្រុមកងទ័ពរបស់ ហោ ពុំបានធ្វើសកម្មភាពអ្វីទៅលើប្រជាជននោះទេ ។ ពាក់ព័ន្ធនឹងការងាររបស់សាក្សីនៅក្នុងអង្គភាពពាណិជ្ជកម្មវិញ សាក្សីបានរៀបរាប់ថា នៅទីនោះមានកប៉ាល់ចិនដឹកជញ្ជូនអង្ករ និងសម្ភារៈផ្សេងៗដូចជា ចប បង្គីប៉ែល និងមានរថយន្តមកជាមួយថែមទៀតមកប្រទេសកម្ពុជា ។ បន្ទាប់ពីត្រឡប់មកពីកំពង់សោម សាក្សីបានមកធ្វើការងារជាកម្មករលីសែងអង្ករ និងស៊ីម៉ង់ស៍នៅប្រាំងចំរេះវិញ ហើយក្រោយមកទើបត្រូវបញ្ជូនទៅធ្វើការនៅតាខ្មៅមួយរយៈមុនពេលផ្លាស់ទៅធ្វើការនៅទួលទំពូង ។

តំណាងសហព្រះរាជអាជ្ញា វ៉ាំងសង់ ដឺវ៉ាយ ដេស្វាឯល បានបន្តសួរទាក់ទងនឹងការចាប់ខ្លួនកម្មាភិបាលថ្នាក់ប្រធានកងតូច ប្រធានកងធំ ប្រធានអនុសេនាតូចជាដើម បន្ទាប់ពីមានការចាប់ខ្លួន កុយ ធួន ហៅ ធុច ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា ក្រោយពេលចាប់ខ្លួនអ្នកទាំងនោះមក មានការកោះហៅអ្នកដែលនៅថ្នាក់ក្រោមជាកម្មករជាដើមមកប្រជុំរៀបចំជាអនុសេនា

តូច ។ នៅពេលនោះ មានការប្រកាសថា កម្មាភិបាលថ្នាក់លើ ត្រូវចាប់ខ្លួន ដោយសារតែអ្នកទាំងនោះជាខ្សែបណ្ដាញរបស់ កុយ ធួន ។ សាក្សីបានបន្ដថា អ្នកដែលដឹកនាំប្រជុំនៅពេលនោះ គឺ តាវិទ្ធ ដែលបានផ្លាស់មកពីភូមិភាគនិរតី ។ ក្រោយពេលត្រឡប់មកពី កំពង់សោមវិញ សាក្សីត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅប្រាំងចំរេះ និងតាខ្មៅ បន្ទាប់មកទើបផ្លាស់ទៅនៅទួលទំពូង ។ តំណាងសហព្រះរាជអាជ្ញាបានបន្ដសួរទាក់ទងនឹងការចាប់ខ្លួនកងទ័ពបន្ទាប់ពី កុយ ធួន ហៅ ធុច ត្រូវបានចាប់ខ្លួន ។ សាក្សីបានបញ្ជាក់ឡើងវិញថា នៅពេលនោះ មានការកោះហៅទ័ពឲ្យទៅប្រជុំនៅវត្តភ្នំ ដើម្បីរៀបចំកម្មករឡើងវិញ ហើយខ្មែរក្រហម គ្រាន់តែបានប្រកាសថា កុយ ធួន ជាជនក្បត់ដែលមានគម្រោងធ្វើរដ្ឋប្រហារប្រឆាំងនឹងបងធំទី១ និងបងធំទី២ ។ សាក្សីបានបន្ដថា វិទ្ធ ជាប្រធានផ្នែកនៅវត្តទួលទំពូង បាននិយាយថា កុយ ធួន ជា គិញ សេ.អ៊ី.អា ថែមទៀត ។

ទាក់ទងនឹងការងារក្នុងក្រសួងពាណិជ្ជកម្មនៅវត្តទួលទំពូងវិញ សាក្សី ស៊ឹម ហេ បានបញ្ជាក់ថា នៅពេលនោះ សាក្សីជាប្រធានក្រុមដែលទទួលបន្ទុកខាងសម្រិតសម្រាំងសំឡីក និងត្រួតពិនិត្យម៉ាស៊ីន វាយសំឡីក ក្រោមការគ្រប់គ្រងរបស់ តាហុង (តាហុងមានឋានៈក្រោម តាវិទ្ធ ដែលទទួលខុសត្រូវខាងក្រសួងពាណិជ្ជកម្មនៅក្នុងប្រទេស) ។ ថ្ងៃមួយធ្មេញម៉ាស៊ីនវាយគបានបាក់ ដោយសារតែមានកម្ទេចឈើ ឬដែកដែលប្រជាជននៅតាមមូលដ្ឋានច្រកដោយមកជាមួយគ ដូច្នេះ តាវិទ្ធ បានប្រជុំថា "...ស្លាបព្រាមួយឲ្យតែបាក់ គឺខ្មាំងមិនខានអស់ទេ" ។ ឮដូច្នោះ សាក្សីមានការភ័យខ្លាចដោយពុំដឹងថា ថ្ងៃក្រោយនឹងមានរឿងអ្វីកើតឡើងចំពោះខ្លួននោះទេ ។ ចំពោះការចាប់ខ្លួនមនុស្សនៅក្នុងក្រសួងពាណិជ្ជកម្មវិញ សាក្សី ស៊ឹម ហេ បានរៀបរាប់ថា ថ្ងៃមួយមានការចាប់ខ្លួន មិត្តជា ជានិរសាររបស់ តាញ៉ែម ដែលត្រូវបានចាប់ខ្លួនមុនពេល តាវិទ្ធ មកគ្រប់គ្រងផ្នែកពាណិជ្ជកម្ម ។ នៅពេលនោះ មានខ្មែរក្រហម ៤នាក់បានបើកឡានម៉ាកអាស៊ីមីស័រ ដែលមានស្លាកម-៧០មកដឹក មិត្តជា ។ ក្រោយមក សាក្សីបានទទួលដំណឹងតាមរយៈឈ្មោះ រី ដែលថា សាក្សីនឹងត្រូវចាប់ខ្លួន ។ ដូច្នេះ សាក្សីបានទៅជួបជាមួយ មិត្តថា ដើម្បីប្រាប់ មិត្តថា អំពីភាពស្អាតស្អំរបស់ខ្លួន ទើបសាក្សីមិនត្រូវបានចាប់ខ្លួននៅពេលនោះ ។ មិនយូរប៉ុន្មាន សាក្សីបានឃើញរថយន្ដដែលមានស្លាកលេខម-៧០ដូចឡាន ដែលមកដឹក មិត្តជា ដែរ បានមកដឹកប្រជាជនដែលមកពីភូមិភាគបូព៌ាទាំងឡាន១ ដែលក្នុងចំណោមអ្នកទាំងនោះក៏មានក្មួយរបស់សាក្សីម្នាក់ដែរ ដើម្បីយកទៅធ្វើដូវរទេះភ្លើង ប៉ុន្ដែអ្នកទាំងនោះពុំដែលត្រឡប់មកវិញទេ ។

ទាក់ទងនឹងវត្តមានរបស់ ខៀវ សំផន ក្នុងពេលធ្វើទស្សនកិច្ចនៅក្រសួងពាណិជ្ជកម្មវិញ សាក្សីបានរៀបរាប់ថា នៅឆ្នាំ១៩៧៨ ខៀវ សំផន និង វិទ្ធ បានមកពិនិត្យមើលការផលិតសំឡីកនៅកន្លែងដែលខ្លួនធ្វើការ ។ ខៀវ សំផន បានណែនាំឲ្យកម្មករថា "*...ធ្វើការឲ្យស្អាតណាស់! ព្រោះរបស់នេះ សម្រិតសម្រាំងសម្រាប់យកទៅបរទេស គឺខាងក្រៅប្រទេសយើង*" ។ នៅពេលនោះ តាវិទ្ធ បានអមដំណើរជាមួយ ខៀវ សំផន ដែរ ។ បន្ទាប់មក តំណាងសហព្រះរាជអជ្ញាអន្ដរជាតិ វ៉ាំងសង់ ដឺវ៉ាល ដេស្វាឯល បានបន្ដលើកយកបទសម្ភាសន៍របស់សាក្សីជាមួយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាទាក់ ទងនឹងសមាសភាពមេដឹកនាំខ្មែរក្រហម ។ សាក្សី ស៊ឹម ហេ បានបញ្ជាក់ថា ប៉ុល ពត ជាបងធំទី១ និងជានាយករដ្ឋមន្ត្រីសុន សេនទទួលបន្ទុកខាងក្រសួងការពារជាតិ អៀង សារី ទទួលបន្ទុកខាងក្រសួងការបរទេស នួន ជា ជាប្រធានសភាប្រជាជន ។ ចំពោះថ្នាក់ដឹកនាំនៅក្រសួងវិញ សាក្សីបានបញ្ជាក់ថា វ៉ាន់ រិទ្ធ ជាប្រធានក្រសួង ហើយ មិត្តថា ជាប្រធានមន្ទីរពាណិជ្ជកម្ម ។ សាក្សីបានបន្ដរៀបរាប់ថា នៅខែមករា ឆ្នាំ១៩៧៩ខ្លួនបានទៅចូលរួមប្រជុំនៅបុរីកីឡា ដែលនៅពេលនោះ ខៀវ សំផន បានប្រកាសឲ្យមានការជីកលេណដ្ឋានសម្រាប់លាក់ខ្លួន និងដើម្បីតបតជាមួយវៀតណាម ។

### ៣) ការសួរដេញដោលដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី

នៅពេលចាប់ផ្ដើមមេធាវីជាតិ ដេត វ៉ាន់លី បានសួរដើម្បីឲ្យសាក្សីបញ្ជាក់ទៅលើចម្លើយរបស់សាក្សីដែលបានឆ្លើយនឹងតំណាងសហព្រះរាជអាជ្ញា អំពីការងាររបស់សាក្សីនៅកំពង់សោម ។ សាក្សីបានរៀបរាប់ថា ខ្លួនធ្វើការនៅកំពង់សោមចាប់ពីខែ៧ ឆ្នាំ១៩៧៥រហូតដល់ឆ្នាំ១៩៧៦ ។ នៅពេលនោះសាក្សីបានត្រឡប់មកធ្វើការនៅទួលទំពូងវិញ ដោយសារមានការទម្លាក់

គ្រាប់បែកដោយយន្តហោះរបស់សហរដ្ឋអាមេរិកមកលើកប៉ាល់ចិន ដែលចតនៅជិតឃ្លាំងដាក់ទំនិញ ។ ផ្ទុយទៅវិញ គ្រាប់បែកនោះបានធ្លាក់មកលើឃ្លាំងដាក់ឥវ៉ាន់បណ្តាលឲ្យឃ្លាំងនោះឆេះអស់ ទើបកម្មករនៅទីនោះត្រូវបានបញ្ជូនមកនៅទួលទំពូងវិញ ។ ពេលត្រឡប់មកវិញ កម្មករទាំងនោះត្រូវបានយកទៅស្នាក់នៅវត្តខណ្ឌាឡោម និងត្រូវចាត់តាំងឲ្យទៅរៀបចំឥវ៉ាន់នៅផ្សារថ្មី ។ ពេលនោះ សាក្សីបានជួបនារីម្នាក់ដែលលក់ដូរនៅក្នុងផ្សារថ្មី ។ នារីនោះបានប្រាប់មិនឲ្យសាក្សីចូលទៅក្នុងផ្សារទេ ដោយសារផ្សារនោះមានលក់ម្ហូបអាហារ និងរបស់របរសម្រាប់ជនបរទេសប៉ុណ្ណោះ ។ បន្ទាប់ពីមកនៅទួលទំពូង សាក្សីបានបញ្ជាក់ថា នៅទីនោះពុំមានព្រះសង្ឃគង់នៅក្នុងវត្តទៀតទេ ហើយ តារិទ្ធ បានប្រាប់ខ្លួនថា វត្តទួលទំពូងនឹងត្រូវកម្ទេចដោយបំផ្ទុះគ្រាប់មីន ដើម្បីយកថ្មទៅធ្វើរោងចក្រចៀសជាងការទុកវត្ត ដែលមានរូបគំនូរឥតប្រយោជន៍ ។

ទាក់ទងនឹងការផលិតសំឡីវិញ សាក្សី ស៊ឹម ហោ បានបញ្ជាក់ថា រោងចក្រនៅទួលទំពូងមានម៉ាស៊ីនសម្រាប់វាយបំបែកផ្លែកហើយបន្ទាប់មកគនោះត្រូវដឹកយកទៅដាក់នៅតាខ្មៅបន្តទៀត ។ នៅទីនោះ មានម៉ាស៊ីនគ្រីបសំឡីគ និងច្រកបាវដែលមានទម្ងន់មួយរយគីឡូក្រាមសម្រាប់ដឹកទៅលក់នៅឯបរទេស ។ បន្ទាប់មក មេធាវីបានបន្តសួរទាក់ទងនឹងការប្រជុំ ដែលមានរៀបរាប់អំពីតួនាទីរបស់មេដឹកនាំខ្មែរក្រហម ។ សាក្សីបានបញ្ជាក់ថា នៅពេលនោះ រិទ្ធិ ជាអ្នកប្រាប់ដល់បុគ្គលិកនៅក្នុងក្រសួង ហើយការប្រជុំនោះធ្វើឡើងបីដងក្នុងមួយខែ ដែលភាគច្រើនទាក់ទងនឹងការងារដឹកនាំរបស់បក្ស ការអប់រំឲ្យប្រជាជនខំធ្វើការងារ និងសកម្មភាពរបស់ខ្មាំងស៊ីរូងផ្ទៃក្នុងជាដើម ។

បន្ទាប់មក មេធាវីអន្តរជាតិ ម៉ាទីន ម៉ាទីណូ បានបន្តការសួរទាក់ទងការងាររបស់សាក្សីបន្ទាប់ ពីត្រូវបញ្ជូនទៅធ្វើការនៅកំពង់សោម ។ សាក្សី ស៊ឹម ហោ បានបញ្ជាក់ថា បន្ទាប់ពីទៅធ្វើការនៅកំពង់សោម សាក្សីពុំមានការតព្វកិច្ចនៅក្នុងកិច្ចការយោធាទៀតឡើយ ។ នៅទីនោះ សាក្សីធ្វើការងារជាអ្នកលីសែងទំនិញពីកប៉ាល់មកដាក់នៅក្នុងឃ្លាំប៉ុណ្ណោះ ។ ទំនិញដែលនាំចូលមកប្រទេសកម្ពុជារួមមាន ចប ប៉ែល ថ្នាំបាញ់សម្លាប់សត្វល្អិត និងរថយន្តជាដើម ។ ចំណែកផលិតផលដែលនាំចេញរួមមានកៅស៊ូឆៅ កៅស៊ូក្រែប សណ្តែកសៀង សណ្តែកបាយ អង្ករ និងសំឡីគរជាដើម ។ សាក្សី ស៊ឹម ហោ បានបន្តថា ដោយសារតែមានការខ្វះកម្មករនៅប្រាំងចំរេះ សាក្សី និងកម្មករផ្សេងទៀតបានមកធ្វើការនៅប្រាំងចំរេះវិញ ។ ទាក់ទងនឹងនឹងកុមារដែលធ្វើការនៅតាខ្មៅវិញ សាក្សីបានបញ្ជាក់ថា នៅទីនោះមានកុមារអាយុ១២-១៣ឆ្នាំដែលជាកូនរបស់កម្មករចាស់ៗនៅជំនាន់ លន់ នល់ ត្រូវបានចាត់តាំងឲ្យធ្វើការនៅកន្លែងគ្រីបសំឡីគជាមួយកម្មករថ្មីដូចជារូបសាក្សីផ្ទាល់ ដើម្បីឲ្យកុមារទាំងនោះបង្រៀនអំពីរបៀបធ្វើការងារ ។

## ៨) ការសួរដេញដោលដោយចៅក្រម ហ្សង់ម៉ាក ឡាវើញ

ចៅក្រម ឡាវើញ បានចាប់ផ្តើមដោយសួរទាក់ទងនឹងការផ្លាស់ប្តូរទីកន្លែងធ្វើការរបស់សាក្សី ។ សាក្សី ស៊ុម ហោ បានបញ្ជាក់ថា បន្ទាប់ពីថ្ងៃទី១៧មេសា ឆ្នាំ១៩៧៥ កងទ័ពនៅក្នុងកងវររបស់ខ្លួន ត្រូវបានបញ្ជូនទៅផ្សារចាស់ដើម្បីរំសាយមុននឹងបញ្ជូនទៅកំពង់សោម ។ ពេលធ្វើការនៅកំពង់សោម សាក្សីធ្លាប់បានឮឈ្មោះ តាញ៉ែម ដែលជាអ្នកគ្រប់គ្រងនៅក្រសួងពាណិជ្ជកម្មនៅទីក្រុងភ្នំពេញ ។ ប៉ុន្តែ ពេលដែលសាក្សីត្រឡប់មកធ្វើកម្មករលីសែងនៅទួលទំពូង តារិទ្ធ បានមកជំនួសតំណែងនេះវិញ ព្រោះ តាញ៉ែម ត្រូវបានចាប់ខ្លួនដោយសារជាប់ខ្សែក្បត់ជាមួយ កុយ ធួន ជាកម្មាភិបាលនៅភូមិភាគឧត្តរ ។ ក្រោយមកទើបមានការចាប់ខ្លួន ជា ដែលជានីរសាររបស់ តាញ៉ែម បន្តទៀត ។

## ៩) ការសួរដេញដោលដោយមេធាវីការពារក្តីទាំងពីរក្រុម

### ក) មេធាវីការពារក្តី ខៀវ សំផន

ជាការចាប់ផ្តើម មេធាវីជាតិ គង់ សំអុន បានសួរសាក្សីទាក់ទងនឹងឯកសារប្រវត្តិរូបរបស់សាក្សីទាក់ទងនឹងកាលបរិច្ឆេទដែលសាក្សីផ្លាស់ទៅធ្វើការនៅកំពង់សោម ។ សាក្សី ស៊ុម ហោ បានបញ្ជាក់ថា គាត់បានទៅធ្វើការនៅកំពង់សោមនៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៥ ។ សាក្សីបានបន្តថា ពេលទៅធ្វើការនៅកំពង់សោមបានប្រហែលកន្លះខែមានយន្តហោះប្រដេញមួយគ្រឿងបានហោះឆ្វែលមកទម្លាប់គ្រាប់បែកលើឃ្លាំងឥវ៉ាន់ ប៉ុន្តែសាក្សីពុំបានដឹងច្បាស់ថា មានការខូចខាតកម្រិតណានោះទេ ។

សាក្សីបានបន្តថា តាមពិតយន្តហោះនោះមានបេតនាទម្ងាក់គ្រាប់បែកដើម្បីកំទេចកប៉ាល់ដឹកទំនិញទេ ប៉ុន្តែបែរជាត្រូវចំយ្ហាំងទៅវិញ ។ ទាក់ទងនឹងវត្តមានរបស់ ខៀវ សំផន នៅក្រសួងពាណិជ្ជកម្មវិញ សាក្សីបានបញ្ជាក់ថា មានពេលមួយនៅក្នុងក្រសួងមានការប្រជុំប្រាប់ឲ្យកម្មករធ្វើការងាររវេចខ្ចប់សំឡីឲ្យបានល្អ ពីព្រោះ ខៀវ សំផន នឹងចុះមកពិនិត្យទំនិញ ។ នៅពេលនោះ សាក្សីបានឃើញ ខៀវ សំផន ដោយផ្ទាល់ក្នុងសំលៀកបំពាក់ពណ៌ខ្មៅ ហើយមានរូបរាងស្តើង ប៉ុន្តែសាក្សីពុំបានដឹងអំពីតួនាទីរបស់ ខៀវ សំផន នោះទេ ។ មេធាវីបានបន្តសួរទាក់ទងនឹងរណសិរ្សរួបរួមជាតិកម្ពុជា ហើយសាក្សីគ្រាន់តែបានបញ្ជាក់ថា សាក្សីធ្លាប់ឮពាក្យនេះនៅដើមឆ្នាំ១៩៧៩ប៉ុណ្ណោះ ប៉ុន្តែសាក្សីបានឮឈ្មោះ វ៉ាន់ រិទ្ធ (តារិទ្ធ) តាំងពី ឆ្នាំ១៩៧៧មកម្ល៉េះ ។ បន្ទាប់មក មេធាវីបានសួរឲ្យសាក្សីបញ្ជាក់ឡើងវិញអំពីដំណើរទស្សនៈកិច្ចរបស់ ខៀវ សំផន នៅក្រសួងពាណិជ្ជកម្ម ។ ស៊ឹម ហោ គ្រាន់តែបានបញ្ជាក់ថា នៅពេលនោះមាន ខៀវ សំផន វ៉ាន់ រិទ្ធ និងនីរសារពីរបីនាក់ទៀតបានដើរឱនៗពីក្រោយ ខៀវ សំផន ។ ទាក់ទងនឹងកិច្ចប្រជុំនៅបុរីកីឡាវិញ សាក្សីបានបញ្ជាក់ថា នៅថ្ងៃទី៥ ខែមករា មានការប្រជុំមួយនៅពេលព្រឹក នៅបុរីកីឡា ដោយមានការចូលរួមពីអគ្គភាព និងក្រសួងផ្សេងៗ ។ ពេលនោះ ខៀវ សំផន បានចូលរួមជាអធិបតីដោយប្រកាសឲ្យកម្មាភិបាលទាំងអស់ត្រៀមដឹកលេណដ្ឋាននៅអរិយក្សត្រ និងនៅមុខរដ្ឋសភាដើម្បី តតាំងដាច់ខាតជាមួយវៀតណាម ។ នៅពេលនោះ មានការបាញ់ផ្លោងខ្លះៗនៅម្តុំអ្នកលឿង ប៉ុន្តែមិនទាន់ចូលមកដល់ភ្នំពេញនៅឡើយទេ ។ នៅថ្ងៃទី៦ ខែមករា កងទ័ពវៀតណាមបានផ្លោងគ្រាប់នៅម្តុំផ្សារថ្មី ប៉ុន្តែគម្រោងការដឹកលេណដ្ឋាននៅមិនទាន់បានធ្វើនៅឡើយទេ ដូច្នេះខ្មែរក្រហមទាំងអស់បានរត់បែកគ្នាខ្ចាត់ខ្ចាយអស់ ។

បន្ទាប់មក មេធាវីអន្តរជាតិ អាកទូ វែកគែន បានបន្តសំណួរដើម្បីឲ្យសាក្សីបញ្ជាក់អំពីការប្រជុំ និងទាក់ទងនឹងការដឹកលេណដ្ឋានការពារពេលវៀតណាមចូលមកដល់ ។ ត្រង់ចំនុចនេះ សាក្សីបែរជាបញ្ជាក់ថា ពេលនោះ ខៀវ សំផន បានប្រកាសឲ្យដឹកលេណដ្ឋានដើម្បីការពារខ្លួន ប៉ុណ្ណោះដោយសារទ័ពខ្មែរក្រហមពុំមានអាវុធគ្រប់គ្រាន់ដើម្បីទប់ទល់នឹងវៀតណាមទេ ហើយនៅថ្ងៃទី៧ ខែមករា កងទ័ព វៀតណាមបានចូលមកដល់ និងមានការបាញ់គ្នាខ្លាំង ។ មេធាវីបានបន្តសួរឲ្យសាក្សីញ្ជាក់ឡើងវិញទាក់ទងនឹងការចាប់ខ្លួនបុគ្គលមួយចំនួននៅក្នុងក្រសួងពាណិជ្ជកម្ម ហើយសាក្សីបានរៀបរាប់ដូចដែលអ្វីដែលខ្លួនលើកឡើងចំពោះមុខភាគីផ្សេងទៀតដែរ ។

## ១) ការសួរដេញដោលដោយមេធាវីការពារក្តី នួន ជា

មេធាវីអន្តរជាតិ វ៉ិចទ័រ កុបប៉េ បានផ្តើមសំណួរទាក់ទងនឹងការចាប់ខ្លួនទាហាន លន់ នល់ ក្នុងពេលជម្លៀសប្រជាជន ។ ចំពោះករណីនេះ សាក្សីបានឃើញនៅក្នុងកងវររបស់ខ្លួនពេលនៅកំពង់ធំ និងបញ្ជូនទៅឲ្យប្រធានកងវរ ប៉ុន្តែសាក្សីពុំបានបញ្ជាក់ថា ទាហានទាំងនោះត្រូវបានបញ្ជូនទៅសម្លាប់ ឬយ៉ាងណាទេ ។ ទាក់ទងនឹងការស្លាប់របស់ទាហាន លន់ នល់ សាក្សី ស៊ឹម ហោ គ្រាន់តែបានបញ្ជាក់ថា សាក្សីធ្លាប់ឃើញទាហានទាំងនោះស្លាប់ក្នុងពេលច្បាំងគ្នាជាមួយខ្មែរក្រហម ប៉ុន្តែមិនធ្លាប់ឃើញសម្លាប់ដោយសារតែការចាប់ចងផ្សេងៗនោះទេ ។

បន្ទាប់ពីបញ្ចប់ការសួរដេញដោលដោយមេធាវីការពារក្តី នួន ជា សវនាការស្តាប់សក្ខីកម្មរបស់ សាក្សី ស៊ឹម ហោ ត្រូវបានបញ្ចប់ ហើយអង្គជំនុំជម្រះបានបន្តសវនាការដែលនៅសេសសល់កាលពីលើកមុនទាក់ទងនឹងសំណើរបស់ភាគី ក្នុងការបន្ថែមទំហំនៃសេចក្តីសន្និដ្ឋានចុងក្រោយរបស់ខ្លួននៅក្នុងសំណុំរឿង០០២/០១ ។



គណៈប្រតិភូ ភូមា ដឹកនាំដោយប្រធានាធិបតី ណេ វីន នៅប្រទេសកម្ពុជា ក្នុងខែ វិច្ឆិកា ឆ្នាំ១៩៧៧ ។ (ប្រភពរូប : មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សវនាការស្តាប់សក្ខីកម្មសាក្សី ឡេង ឈឿង

## ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣

នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបន្តបើកសវនាការស្តាប់សក្ខីកម្មសាក្សី ឡេង ឈឿង ។ ការសួរដេញដោលសាក្សីធ្វើឡើងក្នុងរយៈពេលមួយថ្ងៃពេញ ដោយផ្តោតលើមុខងារជាអ្នកបើកបររថយន្តឲ្យ ខៀវ សំផន នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅក្នុងការស្តាប់សក្ខីកម្មសាក្សីរូបនេះ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់វេទិការសួរដេញដោលជូនក្រុមមេធាវីការពារក្តី ខៀវ សំផន ធ្វើការតាំងសំណួរមុនភាគី ផ្សេងៗ ។ គួរបញ្ជាក់ថា ក្រុមមេធាវីការពារក្តី នួន ជា ពុំមានសំណួរចំពោះសាក្សី ឡេង ឈឿង នោះទេ ។

### ១) ប្រវត្តិសាវតារ

សាក្សីឈ្មោះ ឡេង ឈឿង ភេទប្រុសអាយុ៥០ឆ្នាំ បច្ចុប្បន្នរស់នៅ ស្រុកសំពៅលូន ខេត្តបាត់ដំបង ។ ឪពុករបស់សាក្សីឈ្មោះ ឆេង ខួង និងម្តាយឈ្មោះ អ៊ុន អន ។ សាក្សីមានប្រពន្ធ ឈ្មោះ ហួត ទ្រី និងមានកូនចំនួនបីនាក់ ។ សាក្សីធ្លាប់ផ្តល់បទសម្ភាសន៍ជូនសហចៅក្រមស៊ើបអង្កេត កាលពីឆ្នាំ២០០៩ ។

### ២) ការសួរដេញដោលដោយមេធាវីការពារក្តី ខៀវ សំផន

មេធាវីអន្តរជាតិ អង់តា ហ្គីសសេ ការពារក្តីជនជាប់ចោទ ខៀវ សំផន បានចាប់ផ្តើមសួរដេញដោលទាក់ទងនឹងការចូលរួមបដិវត្តរបស់សាក្សីកាលពីឆ្នាំ១៩៧៣ ។ ជាដំបូង សាក្សីបានចូលរួមបដិវត្តនៅខេត្តតាកែវ លុះក្រោយមកនៅឆ្នាំ១៩៧៦ អង្គការបានចាត់តាំងឲ្យសាក្សីមករស់នៅភ្នំពេញ ដែលសម្រាកនៅក្នុងសាលាបច្ចេកទេសខ្មែរ-សូវៀត ។ នៅក្នុងសាលានេះ ខ្មែរ-ក្រហមបានបែងចែកមនុស្សជាពីរប្រភេទគឺ មនុស្សតូចធ្វើការនៅរោងចក្រ និងមនុស្សធំត្រូវទៅរៀនបើកបរឡាន ។ សាក្សីស្ថិតនៅក្នុងក្រុមមនុស្សធំ ត្រូវរៀនបើកបរឡានអស់រយៈពេល ២ឆ្នាំនៅក្នុងមន្ទីរក-១២ ដែលមានអ្នកគ្រប់គ្រងឈ្មោះ មៀល ។ បន្ទាប់មកនៅឆ្នាំ១៩៧៨ សាក្សីត្រូវជ្រើសរើសឲ្យធ្វើជាអ្នកបើកបរឲ្យ ខៀវ សំផន ។ រហូតដល់ដើមឆ្នាំ១៩៧៩ ខណៈដែលរបបកម្ពុជាប្រជាធិបតេយ្យត្រូវដួលរលំ សាក្សី ឈប់បើកឡានឲ្យ ខៀវ សំផន ហើយបានរត់គេចខ្លួនឡើងទៅខាងលើភ្នំ ។ តាមរយៈការដកស្រង់សាក្សីបានបញ្ជាក់ថា ខៀវ សំផន ពុំមានមន្ទីរធ្វើការជាក់លាក់ទេ ប៉ុន្តែសាក្សីបានដឹងថា ផ្ទះរបស់ ខៀវ សំផន ស្ថិតនៅមន្ទីរក-៣ ។ សាក្សីយល់ថា ផ្ទះនោះពុំមែនជាកន្លែងធ្វើការទេ ដោយសារឃើញមានតែ តុ សាឡុង កៅអី សម្រាប់ទទួលភ្ញៀវ និងមានអង្រឹងសម្រាប់គាត់សម្រាកប៉ុណ្ណោះ ។ សាក្សីបន្តថា ខៀវ សំផន មិនមានលេខាផ្ទាល់ ឬអ្នកកាន់ទូរស័ព្ទទេ ប៉ុន្តែមានទូរស័ព្ទខ្សែមួយគ្រឿងនៅក្នុងផ្ទះសម្រាប់គាត់ប្រើប្រាស់ ។ នៅពេលចេញក្រៅម្តងៗ ខៀវ សំផន តែងតែចាក់សោរផ្ទះ ។ សាក្សី ឧស្សាហ៍បើកឡានជូន ខៀវ សំផន ទៅផ្ទះម្តាយរបស់គាត់នៅម្តុំបឹងកេងកង ។ សាក្សីធ្លាប់ឃើញ ខៀវ សំផន ជួបជាមួយ នួន ជា ក្នុងពេលហាត់ប្រាណនៅពេលល្ងាច ។ សាក្សីបញ្ជាក់ទៀតថា ផ្ទះរបស់ នួន ជា មានទីតាំងមិនសូវឆ្ងាយពីផ្ទះរបស់ ខៀវ សំផន នោះទេ គឺស្ថិតនៅចម្ងាយប្រមាណរំលងមួយផ្លូវប៉ុណ្ណោះ ។ សាក្សីបានជម្រាបជូនអង្គជំនុំជម្រះទាក់ទងនឹងមន្ទីរក-៣ ដែលមានប្រធានឈ្មោះ សាមិ ថាជាកន្លែងសម្រាប់អ្នកដឹកនាំ ប៉ុន្តែពុំមានសាលប្រជុំនោះទេ ។ សាក្សីពុំធ្លាប់ឃើញមេដឹកនាំ ប្រជុំគ្នានៅទីនេះឡើយ ប៉ុន្តែមន្ទីរក-៣ មានកន្លែងហូបបាយរួមគ្នានៅក្រោមផ្ទះដ៏ធំមួយ និងមានតុវែងមួយទៀតផង ។ ក្នុងនាមជាអ្នកបើកបររថយន្តសម្រាប់ ខៀវ សំផន មេធាវីបានសួរដេញដោល ទាក់ទងនឹងការផ្លាស់ទីរបស់ ខៀវ សំផន ។ សាក្សីបានជម្រាបជូនអង្គជំនុំជម្រះថា កន្លែងដែល ខៀវ សំផន ឧស្សាហ៍ទៅមានដូចជាមន្ទីរក-១, កន្លែងមួយម្តុំខាងមុខព្រះបរមរាជវាំងនៅជិតសភាចាស់ និងពេលខ្លះចេញទៅខាងក្រៅទីក្រុងភ្នំពេញ ។ សាក្សីបានបន្ថែមថា ជាការពិតសាក្សីពុំធ្លាប់ឃើញ ខៀវ សំផន ទៅការដ្ឋានការងារដើម្បីត្រួតពិនិត្យទំនប់ ឬការជីកប្រឡាយនោះទេ ។ ខៀវ សំផន ទៅខេត្តកណ្តាល មួយ

លើក និងខេត្តតាកែវបានមួយលើកដែរ ។ សាក្សីមិនសូវឃើញ ខៀវ សំផន មានការងារច្រើនទេ ប៉ុន្តែបានដឹងថា ខៀវ សំផន ជាប្រធានគណៈប្រធានរដ្ឋ តាមរយៈការប្រកាសផ្សាយតាមវិទ្យុ ។ យូរៗម្តង ខៀវ សំផន បានបង្គាប់ឲ្យសាក្សីបើកឡានដើម្បីពិនិត្យមើលទីក្រុង ហើយសាក្សីបានបញ្ជាក់ថា ការជិះនេះមិនឆ្ងាយប៉ុន្មានទេ ស្ថិតនៅក្នុងចម្ងាយ៥-១០ គីឡូម៉ែត្រប៉ុណ្ណោះ ហើយ ខៀវ សំផន ពុំបានចុះពីលើឡានដើម្បីពិនិត្យមើលនោះឡើយ ។ មេធាវីបានសួរទាក់ទងនឹងអំណាចរបស់ ខៀវ សំផន នៅខណៈពេលដែលសាក្សីធ្វើជាអ្នកបើកបរ ។ សាក្សីបានឆ្លើយស្របនឹងអ្វីដែលខ្លួនបានជម្រាបជូនចៅក្រមស៊ើបអង្កេតកាលពីពេលកន្លងមកថា សាក្សីយល់ថា ខៀវ សំផន ពុំមានអំណាចអ្វីនោះទេ ព្រោះគាត់ហាក់ដូចជាគ្មានការងារធ្វើទេ ភាគច្រើននៅតែក្នុងទីក្រុងភ្នំពេញប៉ុណ្ណោះ ។ សាក្សីធ្លាប់ជូន ខៀវ សំផន មកចូលរួមក្នុងកិច្ចប្រជុំដែលមានទ្រង់ទ្រាយធំនៅស្តាតអូឡាំពិក ដែលមានកម្មាភិបាល និងកម្មកររាប់ពាន់នាក់ និងមានមេដឹកនាំដូចជា ខៀវ សំផន, នួន ជា និង ប៉ុល ពត ។ សាក្សីពុំបានដឹងពីខ្លឹមសារនៃកិច្ចប្រជុំនោះទេ ដោយសារមុខងាររបស់ខ្លួន ពុំមានភារកិច្ចចូលទៅខាងក្នុង ហើយត្រូវនៅរង់ចាំខាងក្រៅ ។ សាក្សីធ្លាប់ជូន ខៀវ សំផន ទៅចូលរួមកិច្ចប្រជុំមួយទៀត ស្ថិតនៅសភាចាស់ដែលមានអ្នកចូលរួមជាកម្មាភិបាលមកពីភូមិភាគនិងតំបន់ជាច្រើន ។ ទាក់ទងនឹងកងការពារឬអង្គរក្សរបស់ ខៀវ សំផន សាក្សីបានរំឭកថាមានកងការពារម្នាក់ឈ្មោះសឿន ដែលបានស្លាប់កាលពីឆ្នាំ ១៩៧៩ ។ ឈ្មោះ សឿន តែងតែតាមការពារ ខៀវ សំផន ជាប់ជានិច្ច ។

ទាក់ទងនឹងការរត់គេចខ្លួនពីភ្នំពេញ ឆ្ពោះទៅខាងលើភ្នំក្នុងឆ្នាំ ១៩៧៩ សាក្សីបានបញ្ជាក់ថា សាក្សីបានធ្វើដំណើរពីភ្នំពេញទាំងយប់ជាមួយ ខៀវ សំផន និងកងការពារម្នាក់ឈ្មោះ សឿន ។ ការចាកចេញ នេះពុំបាននាំយករបស់របរអ្វីជាប់ខ្លួននោះទេហើយប្រពន្ធរបស់ ខៀវ សំផន ពុំបានធ្វើដំណើររួមគ្នាទេ ។ មេធាវីបានព្យាយាមសួរដេញដោលពាក់ព័ន្ធនឹងដំណើររបស់ ខៀវ សំផន មុនពេលគេចខ្លួនចេញពី ទីក្រុងភ្នំពេញ នៅយប់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ សាក្សីបានបំភ្លឺថា ខៀវ សំផន ពុំបានចេញទៅទីកន្លែងណាមួយ ឬចូលរួមនៅក្នុងកិច្ចប្រជុំទេមុនពេលចាកចេញពីទីក្រុងភ្នំពេញ ។ មេធាវីបានលើកឡើងថា សក្ខីកម្មនោះមានសភាពផ្ទុយគ្នាចំពោះសក្ខីកម្មរបស់សាក្សី រស់ ស៊ុយ ដែលបានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះកាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣ ។ គួរបញ្ជាក់ថាសាក្សី រស់ ស៊ុយ បានបំភ្លឺជូនអង្គជំនុំជម្រះថា បានជួបប្រជុំជាមួយ ខៀវ សំផន នៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៩ ។ នៅពេលនោះ ខៀវ សំផន បានណែនាំឲ្យអង្គភាពឃ្លាំងមើលថែរទាំសម្ភារៈ ។ នៅក្នុងសវនាការនាថ្ងៃនេះសាក្សី ឡុង ឈឿង ដែលជាអ្នកបើកបរឲ្យ ខៀវ សំផន បានបំភ្លឺជូនអង្គជំនុំជម្រះថា នៅមុនយប់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ប៉ុន្មានថ្ងៃ ខៀវ សំផន ពុំបានចូលរួមនៅក្នុងកិច្ចប្រជុំណាមួយទេ បើយោងតាមការធ្វើដំណើររបស់ ខៀវ សំផន ដែលមានតែសាក្សី ឡុង ឈឿង ផ្ទាល់ជាអ្នកបើកបរតែម្នាក់គត់សម្រាប់ ខៀវ សំផន នៅពេលនោះ ។ មុននឹងបញ្ចប់សំណួររបស់ខ្លួន មេធាវីបានសួរឲ្យសាក្សីពណ៌នាដោយសង្ខេបពីអាកប្បកិរិយារបស់ ខៀវ សំផន ។ សាក្សី បានរៀបរាប់ថា បើទោះបីជាសាក្សីរស់នៅជាមួយ ខៀវ សំផន រយៈពេលខ្លី ប៉ុន្តែសាក្សីមើលឃើញថា ខៀវ សំផន ជាមនុស្សស្លូតបូតសុភាពរាបសា ។ សាក្សីឮវិទ្យុប្រកាសថា ខៀវ សំផន ជាប្រមុខរដ្ឋ ហើយជាក់ស្តែងពុំឃើញ ខៀវ សំផន ចាត់ចែងអ្វីទាំងអស់ ប្រមុខរដ្ឋនៅពេលនោះអត់មានអំណាចទេ ស្ថិតក្រោមការគ្រប់គ្រងរបស់បក្សកុម្មុយនីស្ត ។ សាក្សីបន្តថា សូម្បីតែកម្មសិទ្ធិទ្រព្យសម្បត្តិក៏ ខៀវ សំផន គ្មានដែរចាប់តាំងពីសាក្សីស្គាល់និងរស់នៅជាមួយ ។

## ៣) ការសួរដេញដោលដោយសហព្រះរាជអាជ្ញា

តំណាងសហព្រះរាជអាជ្ញាជាតិ ចាន់ តារាស្មី បានសួរសាក្សីទាក់ទងនឹងការចូលបដិវត្តនៅក្នុង វ័យ១០ឆ្នាំ ។ សាក្សី ឡុង ឈឿង រៀបរាប់ថាការចូលរួមបដិវត្តធ្វើឡើងដោយការស្ម័គ្រចិត្ត បន្ទាប់ពីមេភូមិសួរក្រុមកុមារពីការចូលបម្រើបដិវត្តខណៈដែលក្រុមកុមារកំពុងរៀននៅក្រោមផ្ទះ ។ សាក្សីនិយាយថាខ្មែរក្រហមបានចូលរំដោះនៅតំបន់ត្រាំខ្នាក្នុងភូមិភាគនិរតី តាំងពីឆ្នាំ១៩៧៣ ។ នៅពេលរំដោះពុំឃើញ មានប្រជាជននៅទេមានតែកងកុមាររបស់សាក្សី និងកងនារីប៉ុណ្ណោះ ដែលនៅដឹកជញ្ជូន

និងរៀបចំសម្ភារៈ ។ នៅអំឡុងឆ្នាំ១៩៧៣-១៩៧៦ កងកុមារត្រូវលើកទំនប់ និងជីកប្រឡាយ ។ តំណាងសហព្រះរាជអាជ្ញាបានសួរពីមូលហេតុដែលខ្មែរក្រហមបង្ខំកុមារក្នុងវ័យ១០-១១ឆ្នាំឲ្យធ្វើការងារធ្ងន់ធ្ងរបែបនេះ ។ សាក្សីបានបញ្ជាក់ថា នៅពេលនោះដូចជាពុំមានការបង្ខំនោះទេ ។ ចំពោះកុមារទូទៅសាក្សី មិនអាចក្តាប់បានទេ ប៉ុន្តែនៅក្នុងអង្គភាពរបស់សាក្សី កុមាររស់នៅជាមួយគ្នាត្រូវតែគោរពវិន័យរបស់អង្គការ ។ រឿងមួយដែលសាក្សីយល់ថា ជាការបង្ខិតបង្ខំ គឺការប្រជុំដើម្បីដកបទពិសោធ និងដាក់វិធានការ ហើយមិនអាចធ្វើអ្វីមួយដោយសេរី ។ ទាក់ទងនឹងការបំបែកកុមារឲ្យរស់នៅឆ្ងាយពីឪពុកម្តាយ សាក្សីបានឆ្លើយថាពុំបានដឹងពីបញ្ហានេះទេហើយចំពោះសាក្សីផ្ទាល់បានចាកចេញពីគ្រួសារ ដោយការស្ម័គ្រចិត្ត ។ បើទោះជាស្ម័គ្រចិត្តពេលខ្លះសាក្សីនៅតែយំនឹកឪពុកម្តាយ ប៉ុន្តែព្យាយាមខិតខំអត់ធ្មត់ និងធ្វើតាមការអប់រំ ។ ឆ្លងកាត់ការលះបង់ពេលវេលា និងការខិតខំប្រឹងប្រែងដើម្បីបដិវត្ត សាក្សីពុំមានវិប្បដិសារីចំពោះសកម្មភាពរបស់ខ្មែរក្រហមនោះទេ ដោយសារក្នុងរបបនោះ សាក្សីនៅតូចរស់នៅកន្លែងធម្មតានិងតម្រូវឲ្យគោរពអង្គការតែប៉ុណ្ណោះ ។ សាក្សីបានបញ្ជាក់ថា នៅឆ្នាំ១៩៧៦ សាក្សីបានធ្វើការនៅមន្ទីរក-១២ ។ នៅពេលនោះ ដោយសារសាក្សីនៅក្នុងវ័យកុមារ ដូច្នេះ ត្រូវធ្វើជាអ្នកបោសសម្អាតផ្ទះ ។ ក្នុងនាមជាអ្នកបើកបរសាក្សីពុំបានដឹងថា ខៀវ សំផន ជួបនរណាខ្លះនោះទេ ។ ឧទាហរណ៍ដូចជា នួន ជា ជាដើមសាក្សីដឹងថា ខៀវ សំផន ជួបនួនជាប្រសិនបើឃើញអ្នកបើកឡានរបស់គាត់ ។ ចំពោះមេដឹកនាំធំដូចជា ប៉ុល ពត, តាម៉ុក និង សុន សេន ដែលចេញចូល ក្នុងមន្ទីរក-៣ សាក្សីឆ្លើយថាសាក្សីពុំបានជួបផ្ទាល់នោះទេត្រឹមតែស្គាល់ឡានរបស់ពួកគាត់ប៉ុណ្ណោះ ។ សាក្សីបន្តថា ខណៈពេលដែលសាក្សីធ្វើជាអ្នកបើកបរពុំឃើញ ខៀវ សំផន ទទួលស្វាគមន៍គណៈប្រតិភូ ឬភ្ញៀវធំៗនោះទេ ។ តំណាងសហព្រះរាជអាជ្ញាបានសួរពីមូលហេតុ ដែលសាក្សីមានការគោរពចំពោះ ខៀវ សំផន ។ សាក្សីនិយាយថាការគោរពនេះចំពោះតែសាក្សីម្នាក់ប៉ុណ្ណោះ ដោយសារសាក្សីធ្លាប់រស់នៅជាមួយ ខៀវ សំផន ហើយគាត់មានបុកពារសុភាពរាបសារ ។

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ វាំងសង់ ដឺវ៉ាល់ ដេស្មាឯល បានសួរទាក់ទងនឹងទំនាក់ទំនងរវាង ខៀវ សំផន និងមេដឹកនាំផ្សេងទៀត ។ សាក្សីឆ្លើយថា នៅក្នុងអំឡុងពេលដែលខ្លួនបំពេញការងារពុំធ្លាប់ឃើញ ខៀវ សំផន មានទំនាក់ទំនងជាមួយមេដឹកនាំផ្សេងទេ ។ សាក្សីបានបញ្ជាក់ទៀតថា នៅក្នុងក្រសួងនីមួយៗក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានចាក់មេក្រូ ហើយពេលសាក្សីបើកឡាន បានស្តាប់ពុ ។ ជាធម្មតា សាក្សីសង្កេតឃើញ ខៀវ សំផន ចូលចិត្តស្តាប់វិទ្យុដែលមានវិទ្យុតូចមួយសម្រាប់ចល័តតាមខ្លួនរបស់គាត់ ហើយពេលខ្លះ ខៀវ សំផន ពុំមែនស្តាប់ជាភាសាខ្មែរនោះទេ ។

### ៤) ការសួរដេញដោលដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

មេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពេជ អង្គ បានចាប់ផ្តើមតាំងសំណួរទាក់ទងនឹងមុខរបររបស់សាក្សី ។ មុខរបរបច្ចុប្បន្នរបស់សាក្សី ជាមន្ត្រីនគរបាលជាតិ ក្នុងឋានៈជានាយរងផ្នែកស្ថិតិប្រចាំស្រុកសំពៅលូន ។ បន្ទាប់មក មេធាវីបានសួរដេញដោលអំពីការអប់រំរបស់ ខៀវ សំផន ថាតើសាក្សីបានទទួលការអប់រំអ្វីខ្លះ? សាក្សីបានបញ្ជាក់ថា ការអប់រំនោះស្តីអំពីការរស់នៅ ។ ការពិត ខៀវ សំផន ពុំបានអប់រំដល់សាក្សីនោះទេ ប៉ុន្តែសាក្សីបានរៀនសូត្រពីរបៀបរស់នៅរបស់ ខៀវ សំផន ដោយខ្លួនឯង ដោយសារយល់ថា ខៀវ សំផន ជាមនុស្សល្អ ។ ឆ្លើយតបនឹងសំណួរបន្ទាប់សាក្សីបានបញ្ជាក់ថា ភាគច្រើនសាក្សីដឹក ខៀវ សំផន ទៅមន្ទីរក-១ នៅពេលព្រឹក និងពេលរសៀល ។ សាក្សីពុំមានលទ្ធភាពដឹងអំពីជំនួបរបស់ ខៀវ សំផន ជាមួយបុគ្គលណាម្នាក់ឬចូលរួមប្រជុំណាមួយឡើយ ដោយសារសាក្សីពុំមានសិទ្ធិចូលទៅខាងក្នុងមន្ទីរក-១ ។ សាក្សីពុំអាចដឹងពីមុខងាររបស់ សូ សុជាតិ ដែលជាប្រពន្ធរបស់ ខៀវ សំផន នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានទេ ក៏ប៉ុន្តែដឹងថា សូ សុជាតិ នៅខាងផ្នែកដាំស្ល ។ ដោយហេតុថា មេធាវីការពារក្តី នួន ជា ពុំមានសំណួរចោទទៅសាក្សី ដូច្នេះការសួរដេញដោលសាក្សី ឡេង ឈឿង បានបញ្ចប់បន្ទាប់ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពេជ អង្គ បញ្ចប់ការតាំងសំណួររបស់ខ្លួន ។

# សវនាការស្តាប់សក្ខីកម្មសាក្សី នូ ម៉ៅ

## ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣

នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបន្តបើកសវនាការស្តាប់សក្ខីកម្មសាក្សី នូ ម៉ៅ ទាក់ទងនឹងការជម្លៀសប្រជាជននៅដំណាក់កាលទី១ (ចេញពីទីក្រុងភ្នំពេញ) និងដំណាក់កាលទី២ (ជម្លៀសប្រជាជនពីតំបន់មួយទៅតំបន់មួយទៀតក្នុងអំឡុងពេលខ្មែរក្រហមកាន់អំណាច) ។ មុនពេលអនុញ្ញាតឲ្យភាគីទាំងអស់សួរដេញដោលប្រធានអង្គជំនុំជម្រះលោកចៅ-ក្រម និល ណុន បានប្រាប់អំពីសិទ្ធិរបស់ នូ ម៉ៅ ក្នុងការនៅស្ងៀមមិនឆ្លើយតបចំពោះសំណួរទាំងឡាយណាដែលនាំឲ្យដាក់បន្ទុកលើខ្លួនឯង ដែលមានន័យថា តាមរយៈចម្លើយនៃសំណួរទាំងនោះសាក្សីអាចប្រឈមមុខការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌណាមួយ ។ ប៉ុន្តែក្នុងនាមជាសាក្សី នូ ម៉ៅ មានករណីកិច្ចឆ្លើយតបគ្រប់សំណួរទាំងអស់ដែលសួរដោយភាគី លើកលែងតែការឆ្លើយនូវសំណួរដែលនាំឲ្យដាក់បន្ទុកលើខ្លួនឯង ។

នីតិវិធីក្នុងការសួរដេញដោលសាក្សី នូ ម៉ៅ បានប្រព្រឹត្តទៅតាមលំដាប់ ដោយចាប់ផ្តើមពីប្រធានអង្គជំនុំជម្រះ (សួរដើម្បីកំណត់អត្តសញ្ញាណរបស់សាក្សី) តំណាងសហព្រះរាជអាជ្ញា ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា និង ខៀវ សំផន ។ ក្នុងការសួរដេញដោលភាគីបានផ្តោតសំខាន់អំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងជម្លៀសពីតំបន់មួយទៅដំបន់មួយទៀត (ជម្លៀសដំណាក់កាលទី២) ។ ក្រៅពីនេះ ភាគីសួរទាក់ទងនឹងកិច្ចប្រជុំមួយចំនួនដែល នូ ម៉ៅ បានចូលរួមដោយមាន តាម៉ុក, ជូ ជេត ហៅ ស៊ុ, ហ៊ូ យន់ ។ល ។ ជាអ្នកធ្វើបទខុទ្ទេសនាមអំពីផែនការវាយយកទីក្រុងភ្នំពេញ និងជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។ គួរបញ្ជាក់ថា ដោយសារសាក្សីមានវ័យចំណាស់ (អាយុ៧៨ឆ្នាំ) ដូច្នេះក្នុងការសួរដេញដោលគឺមានការលំបាកមួយចំនួនសម្រាប់ភាគី ឬមិនទទួលបានចម្លើយ ដោយសាក្សីបញ្ជាក់ថា គាត់មានការភ្លេចភ្លាំងច្រើន ហើយមានអង្គហេតុមួយចំនួនគាត់បានឆ្លើយច្របូកច្របល់ ។

គួរបញ្ជាក់ផងដែរ សវនាការនេះធ្វើឡើងដោយមានតែវត្តមានរបស់ជនជាប់ចោទ ខៀវ សំផន ប៉ុណ្ណោះ ។ ចំណែកជនជាប់ចោទ នួន ជា ស្នើសុំចូលរួមសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍នៅក្រោមសាលសវនាការ ដោយលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ព្រោះតែបញ្ហាសុខភាព ។

### ១) ប្រវត្តិសាវតាររបស់សាក្សី នូ ម៉ៅ

នូ ម៉ៅ អាយុ ៧៨ឆ្នាំ មានស្រុកកំណើតនៅឃុំ យុទ្ធសាមគ្គី (ពីមុនហៅថាឃុំជើងរាស់) ស្រុកខ្ទដុង្គ ខេត្តកំពង់ស្ពឺ ។ បច្ចុប្បន្នរស់នៅភូមិត្រពាំងធំ ឃុំយុទ្ធសាមគ្គី ស្រុកខ្ទដុង្គ ខេត្តកំពង់ស្ពឺ ដោយប្រកបរបរធ្វើស្រែចម្ការ ។ ឪពុកឈ្មោះ នូ ម្តាយឈ្មោះ ហួន ប៊ុត ប្រពន្ធឈ្មោះ ឡាច ណន មានកូនចំនួន ៧នាក់ ។ នូ ម៉ៅ ចូលរួមក្នុងចលនាបដិវត្តខ្មែរក្រហមក្នុងឆ្នាំ១៩៧១ ហើយក្លាយជាសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងឆ្នាំ១៩៧២ ។ ក្នុងអំឡុងពេលខ្មែរក្រហមវាយប្រយុទ្ធជាមួយទាហាន លន់ នល់ នូ ម៉ៅ មានតួនាទីជាអ្នកដឹកនាំប្រជាជននៅសមរភូមិក្រោយ ឲ្យដឹកជញ្ជូនស្បៀងសម្រាប់ផ្គត់ផ្គង់យោធាខ្មែរក្រហមនៅសមរភូមិមុខ ។ នូ ម៉ៅ មានតួនាទីជាសមាជិកភូមិ ក្រោយមកក្លាយជាសមាជិកឃុំ ។

### ២) កិច្ចប្រជុំរៀនសូត្រនយោបាយ

ឆ្លើយតបនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ឃីត វែន័រ សាក្សី នូ ម៉ៅ បានបញ្ជាក់ថា ក្នុងអំឡុងឆ្នាំ ១៩៧២ សាក្សីបានដឹងថាមានកិច្ចប្រជុំមួយនៅក្នុងខេត្តកំពង់ឆ្នាំង ដោយមានព្រះសង្ឃចូលរួមប្រមាណបីពាន់អង្គ ក្រោមអធិបតីភាពរបស់ តាម៉ុក ។ ពេលនោះ តាម៉ុក បានណែនាំដល់ ព្រះសង្ឃទាំងអស់កុំឲ្យកងទ័ពវៀតណាមស្នាក់នៅក្នុងវត្ត និងក្នុងភូម ។ ចំណែក ជូ ជេត ដែលទទួលបន្ទុកផ្នែកនយោបាយ បានធ្វើចលនាអូសទាញព្រះសង្ឃ (តាមរយៈធម្មការ) ឲ្យផ្សឹកដើម្បីចូលរួមចលនាតស៊ូជាមួយកម្លាំងខ្មែរក្រហម ។ ជាលទ្ធផល មានព្រះសង្ឃជាច្រើន

បានសឹក ដើម្បីចូលរួមជាមួយចលនាបដិវត្តន៍ខ្មែរក្រហមប្រឆាំងនឹងរបប លន់ នល់ ។

ក្រោយពីកិច្ចប្រជុំនេះ នូ ម៉ៅ បានចូលរួមកិច្ចប្រជុំរៀនសូត្រមួយទៀតមានរយៈពេលជិត១ខែ ។ កិច្ចប្រជុំនេះត្រូវបានរៀបចំធ្វើនៅជិតវត្តកែវទេក ស្រុកថ្ពង ដោយមានកម្មាភិបាលមកពីថ្នាក់ស្រុក និងតំបន់ ប្រមាណ ២០០នាក់ ក្រោមអធិបតីភាពរបស់ ជូ ជេត ហៅ ស៊ុំ ។ នៅក្នុងកិច្ចប្រជុំនោះ ជូ ជេត បានណែនាំកម្មាភិបាលទាំងអស់ឲ្យធ្វើការបំផុសបំផុលប្រជាជនឲ្យចូលរួមក្នុងចលនាតស៊ូរំដោះជាតិ ។ ចំណែក តាម៉ុក ដែលទទួលបន្ទុកផ្នែកយោធា បានធ្វើបទឧទ្ទេសនាមពាក់ព័ន្ធនឹងផែនការវាយយកទីក្រុងភ្នំពេញ និងជម្លៀសប្រជាជនចេញពីទីក្រុង ។ តាម៉ុក បានលើកឡើងថា "យើងវ៉ៃលុកចូលទីក្រុងភ្នំពេញ យើងត្រូវតែជម្លៀសប្រជាជនចេញឲ្យអស់ពីទីក្រុង ។ មិនថាប្រជាជនណា ឬថ្នាក់ណា គឺជម្លៀសឲ្យអស់ឲ្យស្អាតពីភ្នំពេញតែម្តង" ។ ពាក់ព័ន្ធនឹងផែនការជម្លៀសនេះ នូ ម៉ៅ បានបញ្ជាក់ថា មានការខ្វែងគំនិតគ្នារវាង តាម៉ុក និង ជូ ជេត ។ ជូ ជេត បានជំទាស់ចំពោះការមានបំណងចង់ជម្លៀសប្រជាជនចេញពីទីក្រុង ដោយផ្តល់ហេតុផលថា ប្រជាជននៅក្នុងទីក្រុងភ្នំពេញពុំចេះធ្វើស្រែចម្ការ ។ ទោះបីជាយ៉ាងណាក្តី តាម៉ុក នៅតែទាមទារជម្លៀសដោយខានពុំបាន ។ ទាក់ទងនឹងការជម្លៀសនេះដែរ តំណាងសហព្រះរាជអាជ្ញា ឃីត វ៉េន៍ បានដកស្រង់កំណត់ហេតុដែល នូ ម៉ៅ បានផ្តល់ចម្លើយជូនលោក ប៉ែន យៀនិន ថា នៅក្នុងឆ្នាំ១៩៧៤ មានការរៀបចំផែនការវាយដណ្តើមយកទីក្រុងភ្នំពេញ និងជម្លៀសប្រជាជនចេញ បន្ទាប់ពីវាយកាន់កាប់បាន ។ តាម៉ុក និង ខៀវ សំផន បានគាំទ្រឲ្យជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។ ចំណែក ជូ ជេត, ហ៊ូ នឹម និង ហ៊ូ យន់ ពុំគាំទ្រឡើយ ។ សាក្សី នូ ម៉ៅ បានបញ្ជាក់សារជាថ្មីថា ជូ ជេត, ហ៊ូ នឹម និង ហ៊ូ យន់ ពិតជាមិនចង់ឲ្យមានការជម្លៀសប្រជាជនចេញពីទីក្រុងមែន ។

## ៣) ការជម្លៀសប្រជាជន

ទាក់ទងនឹងគោលនយោបាយជម្លៀសប្រជាជន នូ ម៉ៅ បញ្ជាក់ថា ផែនការរបស់ខ្មែរក្រហមបានកំណត់ថា "យើងត្រូវតែជម្លៀសប្រជាជនគ្រប់តំបន់ទាំងអស់ ។ ពីដើងរាស់ទៅកោះកុង ពីកោះកុង មកដើងរាស់ ។ ពីកំពង់ស្ពឺទៅកំពុងឆ្នាំង ពីកំពង់ឆ្នាំងមកកាន់កំពង់ស្ពឺវិញ" ។ តាមរយៈផែនការនេះ ទាំងប្រជាជនចាស់ដែលរស់នៅក្នុងតំបន់រំដោះ និងប្រជាជនថ្មីត្រូវបានជម្លៀសដូចគ្នា ហើយត្រូវបានចោទថា ជាប្រជាជន លន់ នល់ ។ ប្រជាជនមូលដ្ឋានដែលរស់នៅស្រែះធុល (ជាទីកន្លែងរបស់ នូ ម៉ៅ) ត្រូវបានជម្លៀសទៅកោះកុង ហើយប្រជាជននៅកោះកុងត្រូវបានជម្លៀសមកឲ្យរស់នៅស្រែះធុលវិញ ។ លើសពីនេះទៀត សាច់ញាតិរបស់ នូ ម៉ៅ ជាច្រើនត្រូវបានជម្លៀសទៅខេត្តបាត់ដំបង ហើយគាត់ពុំមានសង្ឃឹមថាអ្នកទាំងនោះនៅមានជីវិតឡើយ ។ នូ ម៉ៅ បានផ្តល់ការយល់ឃើញថា ខ្មែរក្រហមជម្លៀសប្រជាជនពីកន្លែងមួយទៅកន្លែងមួយផ្លាស់ប្តូរចុះឡើងៗនេះ គឺដើម្បីកុំឲ្យមានការផ្សារភ្ជាប់គ្នារវាងថ្នាក់ដឹកនាំ និងប្រជាជន និងរវាងប្រជាជនមូលដ្ឋានជាមួយប្រជាជនដែលត្រូវបានជម្លៀសមក ។ ការអនុវត្តន៍គោលការណ៍នេះធ្វើឲ្យមានភាពច្របូកច្របល់ប្រជាជន ដែលនាំឲ្យស្អប់ទាំងប្រជាជនចាស់ និងប្រជាជនថ្មី ។

## ៤) អំពីប្រជាជនខ្មែរវៀតមិញ

ទាក់ទងនឹងខ្មែរវៀតមិញ នូ ម៉ៅ បញ្ជាក់ថា បន្ទាប់ពីបញ្ចប់ចលនាតស៊ូប្រឆាំងបារាំង ប្រជាជនខ្មែរប្រមាណបីពាន់នាក់ ត្រូវបានវៀតណាមយកទៅអប់រំទាំងផ្នែកនយោបាយ និងយោធានៅទីក្រុងហាណូយ ។ ប្រជាជនទាំងនេះត្រូវបានហៅថា "ខ្មែរវៀតមិញ" ។ ក្រោយមក ប្រជាជនប្រមាណបីពាន់នាក់នេះ ត្រូវបានបញ្ជូនមកប្រទេសកម្ពុជាវិញ ដោយរួបរួមកម្លាំងជាមួយខ្មែរក្រហម ដើម្បីប្រឆាំងជាមួយ លន់ នល់ ។ វៀតណាមបានរៀបចំចាត់តាំងប្រជាជនទាំងនេះឲ្យធ្វើជាអ្នកជំនាញការទាំងផ្នែកនយោបាយ យោធា និងសេដ្ឋកិច្ច (ក្នុងការបង្កបង្កើនផលដើម្បីផ្គត់ផ្គង់ស្បៀងដល់សមរភូមិមុខ ដែលប្រយុទ្ធជាមួយទាហាន លន់ នល់) នៅតាមគ្រប់រចនាសម្ព័ន្ធដឹកនាំរបស់ខ្មែរក្រហម ពោលគឺនៅតាមគណៈឃុំ គណៈស្រុក គណៈតំបន់ គណៈភូមិភាគ និងអង្គការថ្នាក់លើ ។ នូ ម៉ៅ បញ្ជាក់ថា ក្រោយមកអង្គការថ្នាក់ លើបង្គាប់ឲ្យកម្មាភិបាលថ្នាក់ក្រោមប្រមូលប្រជាជនខ្មែរវៀតមិញប្រមាណបីពាន់នាក់នោះ ដោយប្រាប់ថាត្រូវទៅរៀនសូត្របន្ថែម ។ ប្រជាជនទាំងនេះត្រូវបានប្រមូល ហើយបញ្ជូនទៅអង្គការថ្នាក់លើទាំង

អស់ ។ ចាប់ពីពេលនោះមក ប្រជាជនទាំងនោះបាត់ខ្លួនរហូតដោយពុំមាននរណាម្នាក់អាចត្រឡប់មកវិញឡើយ ។ នូ ម៉ៅ ផ្តល់ការប៉ាន់ស្មានថា ប្រជាជនទាំងនោះពិតជាត្រូវបានសម្លាប់ ព្រោះខ្មែរក្រហមនឹងមិនយកទៅឲ្យរៀនសូត្រឡើយ ។

## ៥) បញ្ហាផ្សេងៗ

មុនពេលសួរដល់អង្គហេតុដែលត្រូវចោទប្រកាន់ចំពោះជនជាប់ចោទទាំងពីររូបមានភាពចម្រូងចម្រាស់មួយចំនួនរវាងតំណាងសហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តីជនជាប់ចោទពាក់ព័ន្ធនឹងការប្រើប្រាស់កំណត់ហេតុរបស់ លោក ប៉ែន យៀនិន ដើម្បីសួរសាក្សី នូ ម៉ៅ ។ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ឃីត វ៉ែន័រ លើកយកកំណត់ហេតុ១មានចំនួន៩ទំព័រជាភាសាអង់គ្លេស ដែលលោក ប៉ែន យៀនិន បានកត់ត្រានៅពេលសម្ភាសន៍ជាមួយ នូ ម៉ៅ នៅខុដុង្គថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៨១ (នូ ម៉ៅ ទទួលស្គាល់ថា គាត់ពិតជាបានផ្តល់បទសម្ភាសន៍ជូនលោក ប៉ែន យៀនិន ប្រាកដមែន) ។ គោលបំណងនៃការលើកយកឯកសារនេះមកបង្ហាញ គឺដើម្បីដកស្រង់ខ្លឹមសារមួយចំនួនមកបង្ហាញ នូ ម៉ៅ ដែលគាត់បានឆ្លើយជូនលោក ប៉ែន យៀនិន ដើម្បីជាការរំឭកដល់ការចងចាំ ។ ប៉ុន្តែការប៉ុនប៉ងនេះ ត្រូវបានជំទាស់ជាច្រើនដងពីក្រុមមេធាវីការពារក្តី ។ ក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន បានលើកឡើងថា មុននឹងដកស្រង់ខ្លឹមសារកំណត់ហេតុនេះមកសួរបញ្ជាក់សាក្សី តំណាងសហព្រះរាជអាជ្ញាគប្បីសួរសំណួរបឋមមួយចំនួនសិន ដើម្បីបញ្ជាក់ថាសាក្សីពិតជាបានស្គាល់ឯកសារនោះប្អត់ ។ ចំណែកក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា ហាក់ដូចជាបង្ហាញមន្ទិលសង្ស័យចំពោះកំណត់ហេតុនេះ ។ លោក វិចទ័រ កូបប៉េ បានលើកឡើងថាកំណត់ហេតុនោះមានច្បាប់ដើមជាភាសាអង់គ្លេស ប៉ុន្តែសាក្សី នូ ម៉ៅ ពុំចេះភាសាអង់គ្លេសឡើយ ។ ដូច្នេះឯកសារនេះពុំមានជាប់ពាក់ព័ន្ធ ដែលត្រូវបង្ហាញជូនសាក្សីពិនិត្យឡើយ ។ ឆ្លើយតបនឹងសំណួរបឋមមួយចំនួនរបស់តំណាងសហព្រះរាជអាជ្ញា សាក្សី នូ ម៉ៅ បញ្ជាក់ថា នៅពេលសម្ភាសន៍នោះ លោក ប៉ែន យៀនិន ពិតជាបានកត់ត្រាប្រាកដមែន (ដោយមានអ្នកបកប្រែ) ព្រមទាំងថតជាខ្សែអាត់ថែមទៀត ។ លោក ប៉ែន យៀនិន បានទៅសម្ភាសន៍គាត់ដល់ស្រុកខុដុង្គ អមដំណើរដោយលោក ម៉៉ៃខលវិកឃើរី ដែលជាអ្នកកាសែតម្នាក់ដែលបានសម្ភាសន៍ជាមួយ នូ ម៉ៅ ក្នុងអំឡុងពេលសង្គ្រាមរវាងខ្មែរក្រហម និងរដ្ឋាភិបាល លន់ នល់ ។ គួរបញ្ជាក់ថា ក្នុងការសួរដេញដោលសាក្សី នូ ម៉ៅ តំណាងសហព្រះរាជអាជ្ញាជាញឹកញាប់បានដកស្រង់ខ្លឹមសារនៃកំណត់ហេតុនេះមកសួរបញ្ជាក់ ។

ក្នុងការសួរដេញដោលសាក្សីនេះ ក៏មានការវែកញែកគំនិតគ្នាមួយចំនួនរវាងតំណាងសហព្រះរាជអាជ្ញា និងក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ ការវែកញែកគំនិតគ្នានេះបានចាប់ផ្តើមដោយតំណាងសហព្រះរាជអាជ្ញា ឃីត វ៉ែន័រ ធ្វើការកត់សម្គាល់ធ្ងន់ៗនៅពេលមេធាវី ឡោ ជុនធី សួរសាក្សីអំពីការវែកញែកគំនិតគ្នារវាង តាម៉ុក និង ជូ ជេត ទាក់ទងនឹងការសម្រេចជម្លៀស



ការប្រារព្ធពិធីបើកកម្មវិធីធ្វើបទបង្ហាញស្តីពីការវិវឌ្ឍថ្មីៗ នៅសាលាក្តី

ប្រជាជន ។ ឃីត វ៉េន័រ បានលើកឡើងថា “...គឺថា មានច្រើនដង ហើយ ដែលលោកប្រធានបានជម្រាបដល់សហមេធាវីនាំ មុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនឲ្យធ្វើការសួរសំណួរដដែល ៗ ដែលផ្អែកទៅលើមូលដ្ឋានដដែល ដូចដែលខាងសហព្រះរាជអាជ្ញា បានសួររួចទៅហើយ ។ សំណួរហ្នឹងគឺថាមូលដ្ឋានដូចគ្នាទៅលើបញ្ហា ដូចគ្នា ដែលបានសួរដោយខាងព្រះរាជអាជ្ញា ។ ដូច្នេះ តាមការ ស្នើសុំរបស់ខ្ញុំគឺថា សំណួរនេះមិនមែនជាមុខងារជាចម្បងរបស់ ដើមបណ្តឹងរដ្ឋប្បវេណី ។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវស្វែងយល់ អំពីព្យសនកម្ម និងការឈឺចាប់នានា ។ ដូច្នេះ ខ្ញុំគិតថា ដើមបណ្តឹង រដ្ឋប្បវេណីគួរតែគោរពទៅតាមតួនាទីរបស់ខ្លួន ហើយសួរសំណួរ ពាក់ព័ន្ធទៅនឹងតួនាទីរបស់ខ្លួន” ។ ភ្លាមៗនោះ សហមេធាវីជាតិនាំ មុខដើមបណ្តឹងរដ្ឋប្បវេណី ពេជ អង្គ បានឆ្លើយតបដោយទទួល ស្គាល់ថា សំណួរមួយចំនួនពិតជាមានការប្រាំដែល ។ ប៉ុន្តែ លោក បានបដិសេធដាច់ខាត ដែលតំណាងសហព្រះរាជអាជ្ញាមានបំណង កម្រិតឲ្យក្រុមមេធាវីតំណាងដើមរដ្ឋប្បវេណីសួរចំពោះអង្គហេតុ ណាដែលគ្រាន់តែដើម្បីបង្ហាញនូវការឈឺចាប់ និងព្យសនកម្ម ។ លោក ពេជ អង្គ ផ្តល់ហេតុផលថា មេធាវីតំណាងដើមបណ្តឹង រដ្ឋប្បវេណីមានតួនាទីក្នុងការគាំទ្រដល់ការចោទប្រកាន់ ។ ដូច្នេះ ការមានបំណងកម្រិតតួនាទីនេះពុំត្រឹមត្រូវឡើយ ។ ជាលទ្ធផល អង្គជំនុំជម្រះយល់ស្របតាមការលើកឡើងរបស់មេធាវី ពេជ អង្គ ។ អង្គជំនុំជម្រះបញ្ជាក់ថា ខ្លួននឹងមិនកម្រិតតួនាទីរបស់ក្រុម មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដូចការស្នើសុំរបស់តំណាង សហព្រះរាជអាជ្ញានោះទេ ព្រោះតាមការអនុវត្តកន្លងមកគឺពុំមាន ការកម្រិតដូច្នេះឡើយ ។



ខ្មែរក្រហម ដោយសមាជិកកម្រោងឃុំមើលសាលាក្តីខ្មែរក្រហម នៅសាកលវិទ្យាល័យការពារជាតិ កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០១២

# សវនាការស្តីពីការដាក់បង្ហាញឯកសារទាក់ទងនឹងអង្គហេតុសហឧក្រិដ្ឋកម្មរួម ទម្រង់នៃការទទួលខុសត្រូវ និងតួនាទីរបស់ជនជាប់ចោទ

## ថ្ងៃទី២៤-២៧ ខែមិថុនា ឆ្នាំ២០១៣

នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការផ្តល់ឱកាសជូនភាគីដាក់បង្ហាញឯកសារគន្លឹះដែលពាក់ព័ន្ធនឹងអង្គហេតុនៃសហឧក្រិដ្ឋកម្មរួមក្នុងសំណុំរឿង ០០២/០១ ដើម្បីឲ្យអង្គជំនុំជម្រះមានមូលដ្ឋានក្នុងការវាយតម្លៃអំពីតម្លៃនៃភស្តុតាងនៃឯកសារពាក់ព័ន្ធ ។ ក្នុងអំឡុងពេលសវនាការនេះ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេល៤ថ្ងៃកន្លះ ដើម្បីដាក់បង្ហាញឯកសារពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួម ទម្រង់នៃការទទួលខុសត្រូវ និងតួនាទីរបស់ជនជាប់ចោទ ។ ចំណែកឯជនជាប់ចោទ នួន ជា មានពេលវេលា១ថ្ងៃ ។ សម្រាប់ក្រុមមេធាវីការពារក្តី ខៀវ សំផន មានពេលវេលាកន្លះថ្ងៃដើម្បីធ្វើការកត់សម្គាល់ ឬធ្វើអត្ថាធិប្បាយលើឯកសារគ្រប់ប្រភេទទាំងអស់ ។ ទាំងក្រុមមេធាវីការពារក្តី នួន ជា និងមេធាវីការពារក្តី ខៀវ សំផន ពុំបានប្រើប្រាស់ពេលវេលាទាំងអស់នេះទេ ដោយសារមេធាវីការពារក្តីទាំងពីរក្រុមពុំមានឯកសារដាក់បង្ហាញនៅអំឡុងពេលសវនាការនោះ ។ ប៉ុន្តែ មេធាវីទាំងពីរក្រុមបានព្យាយាមជំទាស់នឹងរបៀបក្នុងការបង្ហាញឯកសាររបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយអះអាងថា ឯកសារដែលបានដាក់បង្ហាញពុំទាក់ទងនឹងសវនាការដំណាក់កាលដំបូង ពោលគឺសំណុំរឿង០០២/០១ ។

### ១) ឯកសារដែលដាក់បង្ហាញដោយសហព្រះរាជអាជ្ញា

ក្នុងអំឡុងពេលនៃសវនាការនេះ សហព្រះរាជអាជ្ញាបានដាក់បង្ហាញនូវឯកសារពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួមទាក់ទងនឹងការជម្លៀសប្រជាជនស៊ីវិលដោយបង្ខំដំណាក់កាលទី១ និងដំណាក់កាលទី២ ។ ឯកសារទាំងនោះមានពាក់ព័ន្ធនឹងព្រឹត្តិការណ៍ដូចជា ៖

១) គោលនយោបាយស្នូលរបស់បក្សកុម្មុយនីស្តកម្ពុជាមុនការជម្លៀសប្រជាជន ។ គោលនយោបាយនេះ គឺជាឯកសារផ្លូវការបោះពុម្ពផ្សាយដោយបក្សកុម្មុយនីស្តកម្ពុជា ដូចជាលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា និងបញ្ហានៅក្នុងទង់បដិវត្តរហូតដល់មនោគមវិជ្ជារបស់បក្សកុម្មុនីស្តកម្ពុជាដើម្បីចម្រាញ់ពួកខ្មាំង និងការជម្លៀសប្រជាជនស៊ីវិល ។

២) ឧទាហរណ៍អំពីគោលនយោបាយចម្រាញ់ប្រជាជន និងការជម្លៀសប្រជាជនដោយបង្ខំ នៅក្នុងខេត្តក្រចេះ កំពង់-ចាម សៀមរាប ភូមិភាគបូព៌ា ភូមិភាគនរតី ជាពិសេសព្រឹត្តិការណ៍នៅឧដុង្គ ក្នុងខែមីនា ឆ្នាំ១៩៧៤ ។

៣) មតិដែលលើកឡើងដោយ ខៀវ សំផន ក្នុងសុន្ទរកថា ដែលថ្លែងនៅកូរ៉េខាងជើងនៅថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៧៤ រយៈពេលប៉ុន្មានសប្តាហ៍បន្ទាប់ពីការវាយប្រហារនៅក្រុងឧដុង្គ និងឯកសារផ្លូវការដែលនិយាយអំពីការវាយប្រហារទីក្រុងឧដុង្គ ។

៤) ការធ្វើដំណើររបស់ ខៀវ សំផន និង អៀង សារី ដែលជាតំណាងដ៏សំខាន់របស់រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាក្នុងអំឡុងពេលដំណើរទស្សនកិច្ចផ្លូវការទៅកាន់ប្រទេសវៀតណាម ចិន និងបណ្តាប្រទេសនៅអឺរ៉ុប និងអាហ្វ្រិក ពីខែមីនា ឆ្នាំ១៩៧៤ រហូតដល់ចុងខែឧសភា ឆ្នាំ១៩៧៤ ។

៥) សេចក្តីសម្រេចជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញដែលមានភស្តុតាងនៃជំនួបរវាង ប៉ុល ពត និង អៀង សារី ក្នុងខែមិថុនា ឆ្នាំ១៩៧៤ និងមតិយោបល់ដែលលើកឡើងដោយ នួន ជា ទាក់ទងនឹងការធ្វើសេចក្តីសម្រេច និងការប្រើមធ្យោបាយការប្រជាធិបតេយ្យ ។

៦) ការទទួលបានសារទូរលេខនៃការជម្លៀសប្រជាជន និងការសម្លាប់ជនស៊ីវិលនៅចុងឆ្នាំ១៩៧៤ ។

៧) របាយការណ៍របស់សហរដ្ឋអាមេរិក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៥ ។

៨) ខ្ទឹមសារនៃសុន្ទរកថា ដែលថ្លែងដោយ ខៀវ សំផន ដែលនាំទៅដល់ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំលើកដំបូង និងឯកសារដែលបង្ហាញអំពីទីកន្លែង និងបុគ្គល ដែលនៅជាមួយគាត់ ។

៩) សេចក្ដីថ្លែងរបស់ អៀង សារី ទៅកាន់អ្នកកាសែតអន្តរជាតិ បង្ហាញអំពីយុត្តិកម្មគាំទ្រការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។

បន្ទាប់មក តំណាងសហព្រះរាជអាជ្ញា ឃីត រេយ៍ន័រ បាន ចាប់ផ្ដើមដាក់បង្ហាញឯកសារជាក់លាក់ចំពោះមុខអង្គជំនុំជម្រះ ។ ឯកសារទាំងនោះមានដូចជា ៖ លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា នៅត្រង់មាត្រា៤ ដែលលើកឡើងអំពីវិន័យរបស់បក្ស ។

សៀវភៅនិពន្ធដោយ ខៀវ សំផន ដែលមានចំណងជើងថា “ពិចារណាទៅលើប្រវត្តិសាស្ត្រកម្ពុជាពីដំណាក់កាលដំបូង រហូតដល់ដំណាក់កាលនៃរបបកម្ពុជាប្រជាធិបតេយ្យ” និងសៀវភៅ “ប្រវត្តិសាស្ត្រថ្មីៗនៃប្រទេសកម្ពុជា និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់” ។ ចំណុចដែលមានពាក់ព័ន្ធនៅក្នុងឯកសារនេះ នៅត្រង់ចំណុច ដែលលើកឡើងទាក់ទងនឹងគោលនយោបាយបក្ស ដែលនិយាយថា វណ្ណៈជិះជាន់ គឺជាខ្មាំងរបស់បដិវត្តន៍ និងជាឧបករណ៍របស់ពួកចក្រពត្តិអាមេរិក និងការបង្កើនល្បឿនរបបកុម្មុយនីស្តនៅក្នុងប្រទេសកម្ពុជា ។

ឯកសារទង់បដិវត្ត ខែសីហា ឆ្នាំ១៩៧៥, ខែធ្នូ ឆ្នាំ១៩៧៦, ខែមករា ឆ្នាំ១៩៧៧ ដែលនិយាយអំពី “កងការពារសម្ងាត់” និង “ការវាយខ្មាំងតាមរូបភាពនយោបាយ” ។

សាររបស់ ខៀវ សំផន ដែលធ្វើឡើងនៅថ្ងៃទី២១ ខែមេសា [ឆ្នាំ១៩៧៥] ដែលមានចំណងជើងថា “សារអបអរសាទរជ័យជម្នះរបស់ឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា រដ្ឋមន្ត្រីក្រសួងការពារជាតិ និងអគ្គមេបញ្ជាការកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជាទៅកាន់អង្គការនានានៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងប្រជាជនកម្ពុជា” ។

ឯកសារស្ដីអំពី “របបកុម្មុយនីស្តនៅក្នុងប្រទេសកម្ពុជា” និពន្ធដោយ ស៊ីវ ហេងឌ័រ ។

ឯកសារដែលដកស្រង់ចេញពីការសែតឡឺម៉ុងដ៍ ដែលមានចំណងជើងថា “ការសម្ភាសជាមួយនឹងជនបដិវត្តកម្ពុជា” ដែលជាអត្ថបទនិយាយអំពីបទសម្ភាសន៍រវាងអ្នកកាសែតម្នាក់ ដែលបានជួបជាមួយ អៀង សារី នៅទីក្រុងប៉េកាំង ដើម្បីនិយាយអំពីការវិវត្តនៅក្នុងប្រទេសកម្ពុជា ។

កំណត់ហេតុស្ដាប់ចម្លើយរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ ដែលបានសួរជនជាប់ចោទ ខៀវ សំផន ទាក់ទងនឹងខ្ទឹមសារនៃសុន្ទរកថាដែល ខៀវ សំផន បានថ្លែង ។

ឯកសារ “សេចក្ដីថ្លែងការណ៍ដោយ ខៀវ សំផន, ហ៊ូ យន់ និង ហ៊ូ នឹម” ធ្វើឡើងនៅក្នុងខែមករា ឆ្នាំ១៩៧៣ ទាក់ទងនឹងព្រឹត្តិការណ៍ក្នុងឆ្នាំ១៩៧២ ដែល ខៀវ សំផន បានធ្វើទស្សនកិច្ចនៅតំបន់រំដោះ ដូចជា សៀមរាប ព្រះវិហារ និងកំពង់ធំ ។

សៀវភៅ “ថាតើ ប៉ុល ពត ឡើងកាន់អំណាចដោយរបៀបណា” និពន្ធដោយ ប៊ែន គៀរនិន ពាក់ព័ន្ធនឹងចំណុចដែលសរសេរស្ដីអំពី បដិវត្តន៍ប្រជាធិបតេយ្យ១៩៧៣ ដល់១៩៧៥ ។

អត្ថបទរបស់កាសែត នូវើល ឌុយកាំបូដស៍ ទាក់ទងនឹងការធ្វើដំណើររបស់ ខៀវ សំផន និង អៀង សារី ទៅបរទេស ។

អត្ថបទកាសែត ញូវយ៉កថាមស៍ ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ១៩៨២ ដែលមានចំណងជើងថា “សម្ព័ន្ធមិត្តបីរបស់កម្ពុជាក្នុងសង្គ្រាមនៅវៀតណាម” ។ មនុស្សបីនាក់ដែលបានយោង ក្នុងឯកសារនេះ គឺសម្ដេចព្រះបាទ នរោត្ដម សីហនុ, សឺន សាន និង ខៀវ សំផន ។ នៅក្នុងអត្ថបទនេះមានដកស្រង់សម្ដីរបស់ ខៀវ សំផន ទាក់ទងនឹងសេចក្ដីសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។

កិច្ចសម្ភាសន៍រវាង នួន ជា ជាមួយនឹងអ្នកកាសែតជប៉ុននៅថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៦ ទាក់ទងនឹងអ្នកដែលមានសមត្ថកិច្ចក្នុងការចូលរួមធ្វើសេចក្ដីសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។ នួន ជា បានអះអាងថា គណៈអចិន្ត្រៃយ៍ គឺជាអ្នកធ្វើសេចក្ដីសម្រេចជម្លៀសប្រជាជននៅពេលនោះ ។

សារទូរលេខពីស្ថានទូតអាមេរិកនៅទីក្រុងភ្នំពេញ ចុះថ្ងៃ

ទី១០ ខែកក្កដា ឆ្នាំ១៩៧៨ ផ្ញើជូនក្រសួងការបរទេសស្តីអំពីការជម្លៀសប្រជាជនទៅអ្នកលឿន ។

ឯកសារសុន្ទរកថារបស់ ប៉ុល ពត នៅទីក្រុងប៉េកាំង ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៧៧ ។

អត្ថបទព័ត៌មាននៅក្នុងសារព័ត៌មាន “ឈីកាហ្គោ ទ្រីប្យូន” នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៧៨ សរសេរដោយលោក រ៉ូណាល់ យ៉េត ដែលបានដកស្រង់សម្តីរបស់ អៀង សារី ទាក់ទងនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។

អត្ថបទនៃទស្សនាវដ្តីញូវស៊ីក ដែលបានចុះផ្សាយនៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ១៩៧៥ សរសេរដោយលោក ព្រីង ហ្គុល ។ លោក ព្រីង ហ្គុល បានចោទសួរ អៀង សារី អំពី មូលហេតុដែលនាំឲ្យមានការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។

អត្ថបទដែលចុះផ្សាយនៅក្នុងកាសែតញូវយកថែមស៍ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៧៨ មានចំណងជើងថា “ប្រទេសកម្ពុជានិយាយការពារការបិទប្រទេសនៅក្នុងឆ្នាំ១៩៧៥ ថាជាការបង្ការសង្គ្រាមស៊ីវិល” ។

កំណត់ហេតុនៃទស្សនកិច្ចរបស់គណៈអចិន្ត្រៃយ៍ ទៅតាមភូមិភាគពីថ្ងៃទី២០ ដល់ថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៧៥ ។ ឯកសារនេះមានចំណងជើងថា សភាពការណ៍សេដ្ឋកិច្ចបង្កបង្កើនផល និងកសិកម្មដំណាំស្រូវ ។

ឯកសារបក្សកុម្មុយនីស្តកម្ពុជា ចុះខែកញ្ញា ឆ្នាំ១៩៧៥ មានចំណងជើងថា “ពិនិត្យក្តាប់ និងអនុវត្តន៍មាគ៌ានយោបាយស្តារសេដ្ឋកិច្ច និងរៀបចំកសាងប្រទេសគ្រប់ផ្នែក” ។

អត្ថបទចុះផ្សាយក្នុងទីភ្នាក់ងារសារព័ត៌មានបារាំង ដែលមានចំណងជើងថា “កម្ពុជា, របាយការណ៍របស់កាសែតញូវយកថែមស៍ ស្តីអំពីការជម្លៀសប្រជាជនដោយបង្ខំជាថ្មីម្តងទៀត ដែលបង្កគ្រោះថ្នាក់ដល់អាយុជីវិតមនុស្ស” ។

បន្ទាប់ពីតំណាងសហព្រះរាជអាជ្ញា ឃីត រេយ៍ន័រ អង្គជំនុំជម្រះបានប្រគល់វេទិកាជូនតំណាងសហព្រះរាជអាជ្ញា វាំងសង់ វ៉ាយជ៍ ដេស្មាឯល ដើម្បីបន្តដាក់បង្ហាញឯកសារ ។ តំណាងសហព្រះរាជអាជ្ញា វាំងសង់ បានបន្តបង្ហាញឯកសារទាក់ទងនឹងគោលនយោបាយស្តីពីសហករណ៍ និងជំរំការងារ ។ ក្រុមមេធាវីការពារក្តី ខៀវ សំផន បានក្រោកឡើងជំទាស់ភ្លាមៗ បន្ទាប់ពីសហព្រះរាជអាជ្ញាមានបំណងចង់ដាក់បង្ហាញឯកសារទាក់ទងនឹងគោលនយោបាយស្តីពីសហករណ៍ និងជំរំការងារ ។ ក្រុមមេធាវីការពារក្តី ខៀវ សំផន អះអាងថា ឯកសារទាំងនោះពុំមានជាប់ពាក់ព័ន្ធនឹងសំណុំរឿង០០២/០១ ។ បន្ទាប់ពីមានការជំទាស់ពីមេធាវីការពារក្តី អង្គជំនុំជម្រះបានប្រគល់វេទិកាជូនលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉្រាយត៍ ដើម្បីដោះស្រាយបញ្ហាដែលមេធាវីបានលើកឡើង ។ ចៅក្រម ខាតវ្រ៉ាយត៍ បានបញ្ជាក់ថា ឯកសារពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយទាំងអស់ អាចអនុញ្ញាតទៅបាន លុះត្រាតែគោលនយោបាយទាំងនោះមានពាក់ព័ន្ធនឹងការជម្លៀសដោយបង្ខំ ។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាគួរតែកម្រិតការបង្ហាញឯកសាររបស់ខ្លួនឲ្យស្ថិតនៅក្នុងដែនកំណត់ដែលអង្គជំនុំជម្រះបានណែនាំ ។

ក្រោយពីទទួលបានការណែនាំរបស់អង្គជំនុំជម្រះ តំណាងសហព្រះរាជអាជ្ញា វាំងសង់ បានបន្តដាក់ឯកសាររបស់ខ្លួនទាក់ទងនឹងសហករណ៍ ។ ឯកសារដែលបន្តដាក់បង្ហាញមាន ៖

សម្រង់កិច្ចសម្ភាសន៍រវាង ខៀវ សំផន ជាមួយនឹងលោក អៀ ម៉េងទ្រី និង លឿង សុភ័ក្ត នៅថ្ងៃទី៩ ដល់ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៦ ដែលនិយាយអំពីការបង្កើតសហករណ៍ ។

ទស្សនាវដ្តីយុវជន យុវនារីបដិវត្តន៍ ចុះខែតុលា ឆ្នាំ១៩៧៥ ត្រង់ផ្នែកដែលលើកឡើង អំពីវិធីសាស្ត្រសម្រាប់យុវជនកម្ពុជា និងរបៀបធ្វើការរបស់ពួកគេ ដើម្បីពង្រឹង និងពង្រីកផលិតផលនៅក្នុងនៅតាមសហករណ៍ ។

អត្ថបទរបស់បក្សកុម្មុយនីស្តកម្ពុជាដែលមានចំណងជើងថា “រំឭកខួបឆ្នាំទី៣នៃការចាត់តាំង សហករណ៍ កសិករ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៦” ។ ឯកសារនេះ បង្ហាញអំពីតួនាទីដ៏សំខាន់របស់សហករណ៍ក្នុងការតស៊ូប្រយុទ្ធប្រឆាំងនឹងខ្មាំងនៅក្នុងការត្រួតពិនិត្យរបស់របបទៅលើប្រជាជននៅក្នុងសហករណ៍ ។

ឯកសារដែលរៀបរៀងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ១៩៩៦ មានចំណងជើងថា “ការពិតអំពីរបបផ្តាច់ការរបស់ ប៉ុល ពត ឆ្នាំ១៩៧៥ ទៅដល់ឆ្នាំ១៩៧៨” ។ ឯកសារនេះផ្តោតសំខាន់លើសម្តីរបស់ អៀង សារី ដែលនិយាយ

អំពីការរស់នៅប្រជាជនថ្មី ដោយតម្រូវឲ្យទៅធ្វើការនៅតាមសហករណ៍ ។

កំណត់ហេតុកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍អំពីគម្រោងផែនការ៤ឆ្នាំ ការកសាងសង្គមនិយមគ្រប់ផ្នែករបស់បក្ស ពីថ្ងៃទី២១ ខែកក្កដា ដល់ថ្ងៃទី២ ខែសីហា ឆ្នាំ១៩៧៦ ។

កំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ ដែលនិយាយអំពីសេចក្តីសម្រេចសាងសង់ព្រលានយន្តហោះនៅខេត្តកំពង់ឆ្នាំង ។

របាយការណ៍របស់ ប៊ី.ប៊ី.ស៊ី ដែលលើកឡើងអំពីសុន្ទរកថារបស់ ខៀវ សំផន ធ្វើឡើងនៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៧ ដើម្បីប្រារព្ធខួបជោគជ័យ១៧ មេសា ។

ឯកសារ អេហ្វប៊ីអ៊ីស ដែលនិយាយអំពីដំណើរទស្សនកិច្ចរបស់ឧបនាយករដ្ឋមន្ត្រីចិន ជិន យុងគ្វី មកប្រទេសកម្ពុជានៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៧៧ ។

បន្ទាប់ពីតំណាងសហព្រះរាជអាជ្ញា វ៉ាំងសង់ អន្តដំនុំជម្រះបានប្រគប់វេទិកាជូនតំណាងសហព្រះរាជអាជ្ញាមួយរូបទៀត គឺលោក ឌេល លីសាក់ ដើម្បីបន្តដាក់បង្ហាញឯកសារគន្លឹះនៅចំពោះមុខអង្គជំនុំជម្រះ ។ ឯកសារដែលសហព្រះរាជអាជ្ញា លីសាក់ ដាក់បង្ហាញ គឺជាឯកសារទាក់ទងនឹងគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាលើបញ្ហាខ្មាំង និងការកំណត់គោលដៅក្រុមជាក់លាក់ ។ ជាដំបូង តំណាងសហព្រះរាជអាជ្ញា លីសាក់ បានបង្ហាញឯកសារពាក់ព័ន្ធនឹងគោលនយោបក្សទូទៅ និងសេចក្តីសម្រេចចូលរួមជាមួយនឹងសហគ្រាស និងការលុបបំបាត់អំពើហិង្សា ជាពិសេសការលុបបំបាត់ខ្មាំងបក្សកុម្មុយនីស្តកម្ពុជា ។ បន្ទាប់មក ឯកសារដែលបង្ហាញអំពីផែនការគោលនយោបាយបក្សកំណត់គោលដៅទៅលើមន្ត្រីរដ្ឋការ និងទាហាន លន់ នល់ និងការកំណត់គោលដៅទៅលើក្រុមជាក់លាក់ផ្សេងទៀត ដូចជាក្រុមជនជាតិចាម វៀតណាម និងក្រុមព្រះពុទ្ធសាសនា ។

ឯកសារដែលតំណាងសហព្រះរាជអាជ្ញា លីសាក់ ដាក់បង្ហាញរួមមាន ៖

សៀវភៅ "សុបិន្តអាក្រក់នៃប្រវត្តិសាស្ត្ររបស់ ប៉ុល ពត" និពន្ធដោយលោក ហ្វីលីព ស្សុត នៅត្រង់ផ្នែកដែលនិយាយអំពីដើមកំណើតនៃគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាពាក់ព័ន្ធនឹងខ្មាំងដែលមេដឹកនាំកម្ពុជាប្រជាធបិតេយ្យលើកឡើង ។

សៀវភៅ "នៅពីក្រោយវាលពិឃាដ" និពន្ធដោយ ថេត សម្បត្តិ នៅត្រង់ផ្នែកមួយដែល និយាយអំពីឥទ្ធិពលរបស់ ម៉ៅ សេទុង លើ ប៉ុល ពត និង នួន ជា ។ ជាពិសេសការបង្កើតនូវមាគ៌ាបក្ស ។

របាយការណ៍ ហ្វីប៊ីស ទាក់ទងនឹងការថ្លែងសុន្ទរកថារបស់ ប៉ុល ពត នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៧ ក្នុងការប្រជុំមហាជនសមាជិកបក្ស ហើយមានកម្មករជាង១០.០០០នាក់ ។ សុន្ទរកថានេះត្រូវបានផ្សព្វផ្សាយតាមរយៈវិទ្យុនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៧៧ ។

សេចក្តីណែនាំពីមន្ទីរ៨៧០ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៧៦ និយាយអំពីការទម្លាក់គ្រាប់បែកនៅខេត្តសៀមរាប ។

កំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ នៅថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ ។

របាយការណ៍ក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ មានចំណងជើងថា "ធ្វើការជាមួយគណៈកម្មាធិការ គ្រប់គណៈកម្មការទាំងអស់" ដែលផ្តោតសំខាន់លើខ្មាំង ។

របាយការណ៍ក្រសួងពាណិជ្ជកម្មដែលរាយការណ៍អំពីការចាប់ខ្លួនបុគ្គលិកដែលត្រូវបានអង្គការចាត់ទុកជាខ្មាំង ។

កំណត់ហេតុកិច្ចប្រជុំ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៦ ដែល សុន សេន បានចូលរួម និងមានវត្តមានលេខាកងពល៧០៣, ប្រធានស-២១ ឌុច និងប្រធានស-៧១ ប៉ង់ ។ ក្នុងកិច្ចប្រជុំនោះនិយាយអំពីការចែកវិតប័ណ្ណប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ។

របាយការណ៍របស់លេខាកងពល៨០១ ផ្ញើជូនបង៨៩ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៧៧ ដែលនិយាយអំពីស្ថានភាពខ្មាំងនៅដ្ឋាននៅភូមិភាគពាយ័ព្យ ។

លិខិតរបស់ ស្វូ ម៉េត លេខាកងពល៥០២ ផ្ញើជូន ឌុច ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៧៧ ។ នៅក្នុងលិខិតនោះ ស្វូ ម៉េត បាននិយាយអំពីការចាប់ខ្លួនជនក្បត់២៧នាក់នៅកងពល៣១០ និង៤៥០ ។

ចំណារនៅលើចម្លើយសារភាពរបស់ឈ្មោះ ម៉ៅ ដែលបានធ្វើឡើងនៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ១៩៧៧ ។

សារទូរលេខរបស់កងពលលេខ១៦៤ ឈ្មោះ មាស មុត ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ ផ្ញើជូនគណៈកម្មាការ៨៧០ ដែលមានសរសេរថា ផ្ញើជូនអ៊ំ អ៊ំនួន បងវ៉ាន់ បងវ៉ន បងខៀវ មន្ទីរ និងឯកសារ ។ ឯកសារនេះនិយាយទាក់ទងនឹងគោលនយោបាយប្រឆាំងនឹងវៀតណាម ។

ផែនទីដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបង្ហាញពីមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស ។

មានអត្ថបទសារព័តមានបរទេសជាច្រើនផ្សេងទៀត ក៏ត្រូវបានដាក់បង្ហាញដោយសហព្រះរាជអាជ្ញា លីសាក់ ដែរ ក្នុងនោះមានដូចជា អត្ថបទកាសែតបាងកកប៉ុស្តិ៍ អា.អេហ្វ.ប៉េ ។

ចំពោះគោលនយោបាយដែលពាក់ព័ន្ធនឹងការសម្លាប់អតីតមន្ត្រី និងទាហាននៃរបបសាធារណរដ្ឋ ក្នុងរដ្ឋការ លន់ នល់ ត្រូវបានលើកឡើងបង្ហាញដោយមានបញ្ជីអ្នកទោសនៅស-២១ និងឯកសារ ដែលបង្ហាញអំពីការសម្លាប់មន្ត្រី និងក្រុមគ្រួសារនៃមន្ត្រីទាំងអស់នោះក្នុងខែមីនា ឆ្នាំ១៩៧៦ ។ ឯកសារនោះមានចំណងជើងថា «បញ្ជីឈ្មោះអ្នកទោសដែលជាមន្ត្រីរដ្ឋបាល» ។

បន្ទាប់ពីតំណាងសហព្រះរាជអាជ្ញា លីសាក់ អង្គជំនុំជម្រះបានប្រគល់វេទិកាបន្តជូនសហព្រះរាជអាជ្ញារងជាតិ គឺលោក ច័ន្ទ តារាវស្នា ដើម្បីបន្តបង្ហាញឯកសារ ។ សហព្រះរាជអាជ្ញារង តារាវស្នា បានលើកបង្ហាញអំពីឯកសារគោលនយោបាយទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលជាគោលនយោបាយមួយក្នុងចំណោមគោលនយោបាយជាច្រើននៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាដំបូង លោកបានបង្ហាញឯកសារទាក់ទងនឹងគោលដៅខ្ពស់បំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យក្នុងការជំរុញឲ្យមានកំណើនប្រជាជន បន្ទាប់មក គឺឯកសារទាក់ទងនឹងគោលគំនិតនៃគ្រួសារបដិវត្តន៍ ។ ភាគច្រើននៃឯកសារដែលត្រូវបានដាក់បង្ហាញ មានដូចជាទស្សនាវដ្តីទង់បដិវត្ត សេចក្តីថ្លែងសុន្ទរកថារបស់មេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ និងកិច្ចសម្ភាសន៍នានាដែលមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យបានធ្វើជាមួយនឹងអ្នកសារព័ត៌មានបរទេស ។

## ៧) ឯកសារដាក់បង្ហាញដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីតំណាងសហព្រះរាជអាជ្ញាបញ្ចប់ការសួរដេញដោលរបស់ខ្លួន អង្គជំនុំជម្រះបានប្រគល់វេទិកាជូនសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីដាក់ឯកសារគន្លឹះទាក់ទងនឹងការអង្គហេតុនៃសំណុំរឿង០០២/០១ ។ មុនពេលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដាក់បង្ហាញឯកសារ ក្រុមមេធាវីការពារក្តី ខៀវ សំផន បានឡើងជំទាស់ទៅនឹងបញ្ជីឯកសារដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានបំណងចង់ដាក់បង្ហាញ ដោយកត់សម្គាល់ថា ឯកសារទាំងនោះលើកឡើងអំពីអង្គហេតុដែលពុំស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០១ និងថា ប្រសិនបើអង្គជំនុំជម្រះអនុញ្ញាតឲ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដាក់បង្ហាញឯកសារទាំងនោះ តើអង្គជំនុំជម្រះចាំបាច់អ៊ីត្រូវបំបែកកិច្ចដំណើរការនីតិវិធីឲ្យទៅជាផ្នែកតូចៗ ។ ក្រុមមេធាវី ខៀវ សំផន អះអាងទៀតថា ការជំនុំជម្រះក្តីនឹងក្លាយជារឿងអយុត្តិធម៌ ប្រសិនបើមានការដាក់បង្ហាញឯកសារដែលពុំជាប់ទាក់ទងនឹងអង្គហេតុដែលអង្គជំនុំជម្រះបានកំណត់ ព្រោះមេធាវីការពារក្តីជនជាប់ចោទពុំឳកាសក្នុងការឆ្លើយតបនឹងឯកសារទាំងនោះ ។ មេធាវីការពារក្តី នួន ជា ក៏មានជំហរដូចក្រុមមេធាវី ខៀវ សំផន ដែរ និងបានគាំទ្រការជំទាស់ចំពោះរបៀបបង្ហាញឯកសារដែលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនឹងធ្វើ ។

ឆ្លើយតបនឹងការជំទាស់របស់មេធាវីការពារក្តីជនជាប់ចោទទាំងពីរក្រុមសហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី អេលីហ្សាប៉ែត ស៊ីម៉ុនណូហ្វត បានបញ្ជាក់ថា ឯកសារ ដែលភាគីដើមបណ្តឹងរដ្ឋប្បវេណីគ្រោងនឹងធ្វើការបង្ហាញគ្រាន់តែជាទ្រឹស្តីដែលត្រូវបានបង្កើតឡើង ហើយនាំឈានទៅរកការអនុវត្តគោលនយោបាយរបបកម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះ ពុំមែនលើកឡើងអំពីការអនុវត្តគោលនយោបាយនោះទេ ។

អង្គជំនុំជម្រះបានដោះស្រាយការជំទាស់របស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ដោយប្រគល់វេទិកាជូនលោកស្រីចៅក្រម

ស៊ីលវៀ ខាតវ៉ាយត៍ ដើម្បីបញ្ជាក់អំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ។ លោកស្រីចៅក្រមបានពន្យល់ភាគីទាំងអស់ថា សំណុំរឿង០០២/០១មានរួមបញ្ចូលគោលនយោបាយ ដែលពាក់ព័ន្ធនឹងគោលនយោបាយដែលមានអត្ថិភាព ប៉ុន្តែការអនុវត្តគោលនយោបាយទាក់ទងនឹងការជម្លៀសប្រជាជនចេញពីទីក្រុងមិនពាក់ព័ន្ធនឹងសំណុំរឿងនេះឡើយ ។ បន្ទាប់មក ប្រធានអង្គជំនុំជម្រះបានប្រគល់វេទិកាជូនសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដាក់បង្ហាញឯកសារ ដែលខ្លួនមានបំណងចង់លើកឡើង ។

សហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស៊ីម៉ុនណូហ្វត បានចាប់ផ្តើមបង្ហាញឯកសារដោយផ្តោតសំខាន់លើគោលនយោបាយនៃការបង្កើតសហករណ៍ និងជំរំការងារ ដោយប្រើប្រាស់នូវឯកសារដែលជាចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន ដែលរៀបរាប់អំពីបទពិសោធន៍ និងការទទួលរងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

**បញ្ជាក់** ៖ បន្ទាប់ពីសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ចប់ការដាក់បង្ហាញឯកសាររបស់ខ្លួន អង្គជំនុំជម្រះបានប្រគល់វេទិកាជូនសហព្រះរាជអាជ្ញាសារជាថ្មីម្តងទៀត ដើម្បីដាក់បង្ហាញឯកសារទាក់ទងនឹងតួនាទីរបស់ជនជាប់ចោទទាំងពីររូប ។ តំណាងសហព្រះរាជអាជ្ញាជាតិ សេង ប៊ុនឃាង បានបន្តដាក់បង្ហាញឯកសារពាក់ព័ន្ធនឹងតួនាទីភារកិច្ច និងសិទ្ធិអំណាចរបស់ នួន ជា ។ ឯកសារទាំងនោះមានដូចជា ៖

កំណត់ហេតុកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៧៦ ដែលមានរបៀបវារៈស្តីពីលទ្ធផលនៃការចចារជាមួយប្រទេសវៀតណាម ទាក់ទងនឹងបញ្ហាព្រំដែនខាងកើត ។ នៅក្នុងកំណត់នេះ មានបង្ហាញអំពីសមាសភាពអ្នកដឹកនាំអង្គប្រជុំ ដែលមាន នួន ជា ជាប្រធាន ក្នុងឋានៈជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជាជំនួសឲ្យ ប៉ុល ពត ជាលេខាបក្ស ដែលអវត្តមាន ។ អ្នកចូលរួមក្នុងអង្គប្រជុំនោះមាន សុន សេន ហៅ ខៀវ, ខៀវ សំផន ហៅ ហែម, លេខាភូមិភាគឦសាន ឈ្មោះ យ៉ា, អនុសេនាធិការ ឈ្មោះ សៀត ឆែ ហៅ ទុំ និង សឿ វ៉ាស៊ី ហៅ ឌឿន ។

កំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ ដែលនិយាយអំពីការបែកចែកការងារ និងកិច្ចដំណើរការ ។

កំណត់ហេតុនៃការចូលខ្លួនលើកដំបូងរបស់ នួន ជា ចំពោះមុខសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ។ នៅក្នុងកំណត់ហេតុនោះ នួន ជា បានទទួលស្គាល់អំពីតួនាទីរបស់ខ្លួននៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ នួន ជា បានលើកឡើងថា «ខ្ញុំជាអនុលេខាបក្ស ជាប្រធានសភា និងក្រៅពីនេះ ខ្ញុំទទួលបន្ទុកអប់រំកម្មាភិបាល និងបក្ខជន» ។

កំណត់ត្រានៃកិច្ចប្រជុំសន្និបាតលើកទី១របស់សភាតំណាងប្រជាជន ចុះថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៦ ។

សុន្ទរកថារបស់ នួន ជា កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៧៨ ក្នុងពិធីជប់លៀងស្វាគមន៍ ដល់គណៈប្រតិភូនៃសាធារណរដ្ឋប្រជាមានិតចិន ដែលត្រូវបានចុះផ្សាយដោយទស្សនាវដ្តីនូវែល ឌុយកម្ពុជា ដេម៉ូក្រាទិក, លេខ៣ ។

សេចក្តីថ្លែងការណ៍របស់ នួន ជា ជូនបក្សកុម្មុយនីស្តដាណឺម៉ាក់ ចុះថ្ងៃទី៣០ និង៣១ ខែកក្កដា ឆ្នាំ១៩៧៨ ដែលនិយាយអំពីប្រវត្តិតស៊ូរបស់បក្ស ។

បទសម្ភាសន៍រវាងលោក អៀ ម៉េងទ្រី ជាមួយនឹង នួន ជា ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៦ នៅផ្ទះរបស់ នួន ជា ក្នុងខេត្តប៉ៃលិន ។ នៅក្នុងកិច្ចសម្ភាសន៍នោះ នួន ជា បានរៀបរាប់អំពីតួនាទី និងភារកិច្ចរបស់គាត់ទាក់ទងនឹងការអប់រំកម្មាភិបាល ។

តំណាងសហព្រះរាជអាជ្ញាបានព្យាយាមដាក់បង្ហាញឯកសារជាច្រើនផ្សេងទៀតទាក់ទងនឹងតួនាទី និងភារកិច្ចរបស់ជនជាប់ចោទ នួន ជា ដូចជា ឯកសារជាវីដេអូ និងកិច្ចសម្ភាសន៍នានា ដែល នួន ជា បានជួបជាមួយអ្នកកាសែត ។ តំណាងសហព្រះរាជអាជ្ញាបានបញ្ចប់ការដាក់បង្ហាញឯកសាររបស់ខ្លួននៅរសៀលថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៣ ។

អង្គជំនុំជម្រះបានបញ្ជាក់ថា អង្គជំនុំជម្រះនឹងធ្វើការសម្រេចលើបញ្ហាតម្លៃនៃភស្តុតាងដែលភាគី បានដាក់ជូនអង្គជំនុំជម្រះក្នុងពេលរៀបចំសាលក្រម ។

# សវនាការស្តាប់សក្ខីកម្មសាក្សី ពេជ ជឹម
## ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៣

នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៣ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកសវនាការស្តាប់សក្ខីកម្មសាក្សីមួយរូបទៀត ឈ្មោះ ពេជ ជឹម ដែលធ្វើឡើងបន្ទាប់ពីសវនាការដាក់ឯកសារ ដោយតំណាងសហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ចប់ ។ អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឲ្យភាគីនៃរឿងក្តីពិភាក្សាដេញដោលអំពីតួនាទីរបស់សាក្សីក្នុងនាមជាអនុលេខាស្រុក១០៥ និងមន្ទីរសន្តិសុខក្រាំងតាចាន់ ។ ការសួរដេញដោលសាក្សី ពេជ ជឹម ធ្វើឡើងក្នុងរយៈពេលពេញមួយថ្ងៃ ដែលចាប់ផ្តើមពីសហព្រះរាជអាជ្ញា, មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តីទាំងពីរក្រុម រួមមាន នួន ជា និងខៀវ សំផន ។

### ១) ប្រវត្តិសាវតារ

សាក្សី ពេជ ជឹម ភេទប្រុស មានអាយុ៧៧ឆ្នាំ ទីលំនៅបច្ចុប្បន្នរស់នៅភូមិផ្អាវ ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។ សព្វថ្ងៃសាក្សីប្រកបរបរធ្វើស្រែចម្ការ ។ ឪពុករបស់សាក្សី ឈ្មោះ ព្រាប ពេជ (ស្លាប់) និងម្តាយឈ្មោះ អ៊ុន អន (ស្លាប់) ។ សាក្សីមានប្រពន្ធឈ្មោះ ច្រឹប ពេជណោង និងមានកូន៩នាក់ ។ មុនពេលចូលខ្លួនមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ សាលាដំបូង សាក្សីធ្លាប់ផ្តល់បទសម្ភាសន៍ជូនសហចៅក្រមស៊ើបអង្កេត ។ សាក្សីបានពិនិត្យផ្ទៀងផ្ទាត់ ឯកសារកំណត់ហេតុស្តាប់ចម្លើយ ហើយយល់ឃើញថា មានលក្ខណៈស៊ីសង្វាក់គ្នានឹងអ្វី ដែលខ្លួនបានផ្តល់ជូនសហចៅក្រមស៊ើបអង្កេតកាលពីពេលកន្លងមក ។

### ២) ការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ឃីត រ៉េន័រ បានចាប់ផ្តើមសំណួរទាក់ទងនឹងពេលចូលបដិវត្តដំបូងរបស់សាក្សី ។ សាក្សីបានឆ្លើយតបថា ខ្លួនបានចូលបដិវត្តនៅថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៧០ ។ ពេលចូលបម្រើបដិវត្តដំបូង សាក្សីទទួលតំណែងជាអនុប្រធានរណៈសិរ្សស្រុក នៅក្នុងការប្រជុំដែលមានសមាជិកច្រើនរូប ហើយមានមិត្ត ខុម (ស្រី) ជាប្រធាន និងជាលេខាស្រុក ១០៥ និង សោម ជាលេខាតំបន់នៅពេលនោះ ។ តំណាងសហព្រះរាជអាជ្ញា បានបន្តសំណួរទាក់ទងនឹងមន្ទីរសន្តិសុខ ក្រាំងតាចាន់ដែលត្រូវបង្កើតឡើងក្នុងឆ្នាំ១៩៧២ ដោយបក្សតំបន់ និងបក្សស្រុក ។ សាក្សីឆ្លើយថា មន្ទីរសន្តិសុខនេះ ត្រូវបង្កើតឡើងក្នុងគោលបំណងអប់រំកែប្រែមនុស្សឲ្យក្លាយជាមនុស្សល្អឡើងវិញ ។ ព្រះរាជអាជ្ញាបានលើកយកក្រុមមនុស្សមួយចំនួន ដែលត្រូវបញ្ជូនទៅក្រាំងតាចាន់ ដើម្បីសួរដេញដោល ។ សាក្សីឆ្លើយថា ក្រុមមនុស្ស ដែលមិនព្រមចូលបម្រើកងទ័ព ពុំបានបញ្ជូនទៅមន្ទីរសន្តិសុខក្រាំងតាចាន់ទេ ប៉ុន្តែក្រុមមនុស្សដែលប្រឆាំងបក្ស ត្រូវបញ្ជូនទៅមន្ទីរសន្តិសុខនេះ ។ ក្រុមមនុស្សដែលប្រឆាំង ឬវាយប្រហារបក្សមានន័យថា ចលនាច្បាំងយកឈ្នះចលនាដែលមិនឲ្យមនុស្សទៅច្បាំង ឬមិនឲ្យមនុស្សចូលរួមជាអ្នកមិនគាំទ្របក្ស ។ ចំណែកអ្នកគាំទ្របក្ស ជាអ្នកដែលចូលរួមការពារជាតិ ទោះបីជានៅក្នុង ឬក្រៅប្រទេសក្តី ។ សាក្សីអះអាងថា មនុស្សដែលត្រូវបញ្ជូនទៅមន្ទីរសន្តិសុខក្រាំងតាចាន់ តែងតែមានរឿងរបស់គេរៀងៗខ្លួន ។ សាក្សីពុំសូវដឹងច្បាស់ពីបញ្ហានេះទេ ដោយនិយាយជារួមថា អ្នកដែលមិនស្របនឹងចលនារំដោះជាតិ ជាសត្រូវរបស់បដិវត្ត និងជាបុគ្គលដែលត្រូវបញ្ជូនទៅមន្ទីរសន្តិសុខ ។ សាក្សីបន្តថា មនុស្សអាក្រក់ដែលបញ្ជូនទៅមន្ទីរសន្តិសុខក្រាំងតាចាន់ពុំមែនសុទ្ធតែជាខ្មាំងនោះទេ ។ មនុស្សល្អ និងអាក្រក់ អាស្រ័យលើការវិនិច្ឆ័យ ក្រោយពេលមានការស្រាវជ្រាវបន្ថែម ទើបជាការត្រឹមត្រូវ ។ បើមិនដូច្នេះទេ សូម្បីតែបងប្អូនខ្លួនឯង ក៏សុទ្ធតែជាខ្មាំងទាំងអស់ ។ តំណាងសហព្រះរាជអាជ្ញា បានលើកយកអត្ថបទដកស្រង់ស្តីពីទាហាន លន់ នល់ ដែលចុះចូលនឹងខ្មែរក្រហម ហើយក្រោយមកត្រូវបញ្ជូនទៅមន្ទីរសន្តិសុខក្រាំងតាចាន់ ។ សាក្សីឆ្លើយថា សាក្សីបានដឹងពីការចាប់ខ្លួនទាហាន លន់ នល់

នៅពេលក្រោយក្នុងអំឡុងឆ្នាំ១៩៧៣-៧៤ ។ ពីដំបូងសាក្សីគិតថាមានអង្គការនៅខាងលើលុះដល់ឆ្នាំ១៩៧៣-៧៤ ទើបដឹងថាអង្គការដែលនៅខាងលើការពិតនៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់ទៅវិញ ។ ទាក់ទងនឹងតួនាទីនៅក្នុងនាមជាអនុលេខាស្រុក សាក្សីបានជម្រាបជូនអង្គជំនុំជម្រះថា សាក្សីទទួលបន្ទុកខាងឃោសនា, អប់រំ និងដឹកនាំប្រជាជនធ្វើស្រែជាដើម ។ សហព្រះរាជអាជ្ញាបានអានអត្ថបទដកស្រង់នៅក្នុងទស្សនាវដ្តីទង់បដិវត្តលេខពិសេសក្នុងខែកញ្ញា ឆ្នាំ១៩៧៧ ស្តីពីបដិវត្តប្រជាជាតិប្រជាធិបតេយ្យ ។ អត្ថបទនោះសរសេរថា “បក្សបានបែងចែក ខ្មាំងជា៣ ប្រភេទៈ ទី១-ខ្មាំងដែលបក្សអាចយកឈ្នះបាន ទី២-បង្រួបបង្រួមខ្មាំងដែលបក្សអាចមានលទ្ធភាព និងទី៣-ដាក់ឲ្យនៅឯកោចំពោះខ្មាំងណាដែលមិនអាចបង្រួបបង្រួមបាន ដើម្បីវាយប្រយុទ្ធជាមួយខ្មាំងប្រភេទនេះ” ។ សាក្សីបានឆ្លើយតបចំពោះការដកស្រង់ខាងលើថា ការយល់ឃើញចំពោះខ្មាំងមានសភាពមិនដូចគ្នាទេ ខ្មាំងដែលសហព្រះរាជអាជ្ញាលើកឡើងនេះ ជាខ្មាំងទស្សនៈ សតិអារម្មណ៍ ហើយខ្មាំងនេះនៅមិនទាន់ជម្រះបាននៅឡើយ ។ សាក្សីបានតាមដានសកម្មភាពខ្មាំង និងស្គាល់ច្បាស់ថា បុគ្គលណាជាខ្មាំង ហើយបុគ្គលណាមិនមែនខ្មាំង ។ សាក្សីបានទទួលស្គាល់តាមអត្ថបទដកស្រង់ដែលសាក្សីបានប្រាប់ទៅចៅក្រមស៊ើបអង្កេតកាលពីពេលសម្ភាសន៍លើកមុនថា “ប្រសិនបើពួកគេនៅតែមិនគោរពវិន័យបន្ទាប់ពីធ្វើការអប់រំហើយនោះ ថ្នាក់ឃុំនឹងសុំយោបល់មកគណៈស្រុក ដែលមាន ខុម គៀវ ញ៉ែវ និងខ្ញុំ (សាក្សី ពេជ ដឹម) ហើយនឹងគណៈឃុំដែលពាក់ព័ន្ធ ។ យើងតែង តែរៀបចំប្រជុំដើម្បីពិភាក្សាបញ្ហានេះ និងធ្វើសេចក្តីសម្រេច” ។ នៅឆ្នាំ១៩៧៥ សាក្សីទទួលបន្ទុករៀបចំប្រជាជនមកពីភ្នំពេញចូលក្នុងសហករណ៍ ។ ទាក់ទងនឹងឯកសារទង់បដិវត្ត ដែលជាទង់កិត្តិយសពណ៌ក្រហមសម្រាប់ ស្រុកត្រាំកក់ក្នុងឆ្នាំ១៩៧៦ សាក្សីបានបញ្ជាក់ថា ការផ្តល់នូវទង់កិត្តិយសនេះ គឺប្រគល់ជូនស្រុកចំនួន៣ គឺស្រុកត្រាំកក់,ស្រុកប្រសូត្រថ្មី និងស្រុកសំឡូត សម្រាប់លើកទឹកចិត្តចំពោះការទទួលបានសមិទ្ធិផលស្រូវច្រើនជាងគេនៅទូទាំងប្រទេស ។ តាម៉ុក គឺជាថ្នាក់លើដែលបានមកប្រគល់ទង់កិត្តិយសនេះ ក្នុងឱកាសប្រជុំថ្នាក់តំបន់ ហើយទង់នេះមានតម្លៃស្មើនឹងមេដាយមាស ។ សាក្សីបានបញ្ជាក់ថា ខ្មាំងផ្ទៃក្នុង គឺជាខ្មាំងក្នុងបដិវត្តស្ថិតក្នុងតំបន់រំដោះ ចំណែកខ្មាំងខាងក្រៅ គឺជាខ្មាំងដែលនៅក្រៅ ដូចជាពីភ្នំពេញជាដើម ។ សាក្សីបានបន្តថា ទាក់ទងនឹងការវាយតម្លៃ ការតាមដាន ចាប់ និងកម្ទេចខ្មាំង ខ្លួនទទួលការណែនាំតាមរយៈការរៀនសូត្រ និងការផ្សាយពីថ្នាក់តំបន់ឲ្យអនុវត្ត ។ សាក្សីបន្តថា ការកម្ទេចពុំមែនមានន័យថា សម្លាប់ចោលទាំងអស់នោះទេ គឺបោសសម្អាតរបបចាស់ចោល ហើយចាប់យករបបថ្មីក្នុងន័យស្រលាញ់ស្នេហាជាតិ ។ សាក្សីធ្លាប់ទទួលការបណ្តុះបណ្តាលពី នួន ជា នៅបូរីកីឡា ដែលមានលេខាស្រុក អនុលេខាតំបន់ សមាជិកស្រុកជាដើម ចូលរួមប្រហែល៨០០នាក់ ក្នុងរយៈពេលជិត១ខែ ។ នៅក្នុងវគ្គនេះ សាក្សីបានទទួលការបណ្តុះបណ្តាលប្រហែល២០ថ្ងៃ ដែលបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៥ ហើយបន្តធ្វើទស្សនៈកិច្ចប្រហែល១០ថ្ងៃ ដែលមានតែនួន ជា ម្នាក់ប៉ុណ្ណោះ ជាអ្នកបង្រៀន និងដឹកនាំធ្វើទស្សនៈកិច្ច ។ ចំពោះចម្លើយសារភាព ដែលបញ្ជូនពីមន្ទីរសន្តិសុខក្រាំងតាចាន់ សាក្សីឆ្លើយថា ចម្លើយសារភាព និងរបាយការណ៍ត្រូវដាក់នៅក្នុងស្រោមសំបុត្របិទជិត រួចផ្ញើមកថ្នាក់តំបន់ ដែលបានឆ្លងកាត់ថ្នាក់ស្រុកជាមុនសិន ។ សាក្សី ពេជ ដឹម ក៏បានរំឭកពីប្រវត្តិការងាររបស់ខ្លួនដែរថា នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៧៦ សាក្សីបានធ្វើការនៅក្នុងចម្ការកៅស៊ូ ។

### ៣) ការសួរដេញដោលដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

មេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហុង គឹមសួន បានសួរឲ្យសាក្សី ពេជ ដឹម បញ្ជាក់អំពីពាក្យថា “ខ្មាំង” ។ សាក្សីបានបញ្ជាក់ថា ចំពោះសាក្សីផ្ទាល់ ពាក្យថា“ខ្មាំង” សាក្សីពុំបានទោរទន់ទៅតាមការយល់ឃើញរបស់នរណាម្នាក់ ដែលចោទគ្នាទៅវិញទៅមកនោះទេ ។ សាក្សីបានធ្វើការពិនិត្យដល់ទីកន្លែង ។ សាក្សីបន្តថា ខ្មាំង គឺបច្ចាមិត្រ ដែលជាសត្រូវនឹងខ្លួនយើង, សត្រូវនឹង អង្គភាពយើង និងជាសត្រូវរបស់ប្រទេសយើង ។ សាក្សីបន្តថា មនុស្សជាប់ឃុំនៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់ ដែលស្ថិតនៅក្នុងស្រុក១០៥ ក្រៅពីអ្នកដែលសាក្សីស្នើសុំឲ្យដោះលែង ភាគច្រើនត្រូវសម្លាប់ ។ សាក្សី ពេជ ដឹម បានឃើញប្រជាជន ដែលត្រូវជម្លៀសពីភ្នំពេញទៅកាន់ស្រុកត្រាំកក់ ។

ឃើញដូច្នេះ សាក្សីក៏មានចិត្តសប្បាយរីករាយ ដោយសារបានប្រជាជនមកចូលរួមកម្លាំងគ្នា ហើយសាក្សីបានរៀបចំចាត់ចែងប្រជាជនទៅតាមសហករណ៍មួយចំនួន។ នៅចុងឆ្នាំ១៩៧៥ ឬដើមឆ្នាំ១៩៧៦ សាក្សីដឹងថា មានការជម្លៀសប្រជាជនពីស្រុកត្រាំកក់ទៅភូមិភាគពាយ័ព្យ។ សាក្សីបានបញ្ជាក់ថា មន្ទីរសន្តិសុខក្រាំងតាចាន់ ស្ថិតក្រោមការគ្រប់គ្រងរបស់តំបន់។ សំណួរចុងក្រោយមេធាវី បានសួរបញ្ជាក់សាក្សីថា តើក្រោយឆ្នាំ១៩៧៩ សាក្សីជឿថា មានការសម្លាប់មនុស្សនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ? សាក្សីបានឆ្លើយថា ខ្លួនពិតជាជឿថាមានការសម្លាប់ប្រជាជនប្រាកដមែន។

## ៨) ការសួរដេញដោលដោយមេធាវីការពារក្តី

### ក) មេធាវីការពារ នួន ជា

មេធាវីអន្តរជាតិ វិចទ័រ កុបប៉េ បានសួរទាក់ទងនឹងការបាត់ខ្លួនទាហាន លន់ នល់ នៅពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ សាក្សីបានបញ្ជាក់ថា ប្រពន្ធទាហានខ្លះបានប្រាប់សាក្សីថា នៅពេលចេញពីភ្នំពេញ ប្តីរបស់គាត់មកជាមួយគ្នា ប៉ុន្តែបានបាត់ខ្លួននៅតាមផ្លូវ។ សាក្សីបានរៀបចំ ស្ត្រីទាំងនោះឲ្យរស់នៅក្នុងសហករណ៍។ សាក្សីបានឆ្លើយថា ចម្លើយសារភាពរបស់ជនស៊ីវិល គឺជាកំហុសតូចតាចប៉ុណ្ណោះ។ មេធាវីបានសួរឲ្យសាក្សីបញ្ជាក់ឡើងវិញទាក់ទងនឹងពាក្យខ្មាំងខាងក្រៅ ដោយផ្តោតលើនិយមន័យនៅក្នុងទស្សនាវដ្តីទង់បដិវត្ត ប៉ុន្តែសាក្សីពុំអាចរំឭកនូវចំណុចនេះបានទេ ប៉ុន្តែនិយាយថា ពាក្យខ្មាំងខាងក្រៅ ត្រូវគេប្រើភ្ជាប់នឹងជនជាតិវៀតណាម។ នៅពេលសាក្សីអានចម្លើយសារភាពរបស់ជនស៊ីវិល ពុំមានការសារភាពណាដែលនិយាយពីវៀតណាមទេ។ មេធាវីបានសួរពីភាពខុសគ្នា រវាងការកសាងជនស៊ីវិល និងការកសាងអតីតទាហាន លន់ នល់។ ប៉ុន្តែសាក្សីពុំអាចស្វែងរកនូវចំណុចខុសគ្នាជាក់លាក់ណាមួយដើម្បីឆ្លើយតបនឹងសំណួរនេះទេ ប៉ុន្តែនិយាយថា ទាហាន លន់ នល់ ដែលបានកសាងខ្លួនហើយ អាចចូលរួមបន្តកិច្ចការទៀតបាន។

មេធាវី បានសួរឲ្យសាក្សីបំភ្លឺពីវគ្គរៀនសូត្រជាមួយ នួន ជា ថាតើ នួន ជា ហេតុអ្វីបានជាសាក្សីស្គាល់ថា អ្នកបង្រៀនឈ្មោះនួនជា? សាក្សីបញ្ជាក់ថា ខ្លួនបានស្គាល់ នួនជា ស្រាប់។ សាក្សីបានបំភ្លឺថា ការបោសសម្អាតតាមការបញ្ជាពីថ្នាក់លើថ្នាក់ស្រុកត្រូវណែនាំដោយថ្នាក់តំបន់ ហើយថ្នាក់តំបន់មានថ្នាក់ភូមិភាគជាអ្នកណែនាំ។

### ខ) មេធាវីការពារ ខៀវ សំផន

មេធាវី គង់ សំអុន បានចាប់ផ្តើមសំណួរទាក់ទងនឹងការចូលបដិវត្តរបស់សាក្សី។ សាក្សី បានជម្រាបថា សកម្មភាពបដិវត្តចាប់ផ្តើមបន្ទាប់ពីរដ្ឋប្រហារនៅឆ្នាំ១៩៧០ បានកើតឡើងភ្លាម។ សាក្សីក៏ បានចូលព្រៃម៉ាគី ក្នុងគោលបំណងតស៊ូជួយសម្តេចឪ ដើម្បីអាចចូលគ្រប់គ្រងប្រទេសឡើងវិញ។ មេធាវីបានលើកយកអត្ថបទសម្រង់ ដែលសាក្សីបានផ្តល់សក្ខីកម្មជាមួយចៅក្រមស៊ើបអង្កេតថា "ពេលខ្ញុំចូលធ្វើបដិវត្តលើកដំបូង គេប្រមូលគ្រូមកពីតំបន់រំដោះ ដើម្បីបង្កើតចលនារណសិរ្សឆ្នាំ១៩៧០-៧១។ កាលពីដំបូង ខ្ញុំគ្មានមុខតំណែងអ្វីទេ គឺនៅជាគ្រូបង្រៀនធម្មតាក្នុងភូមិកំណើតរបស់ខ្ញុំ។ ពេលនោះ គេមានហៅគ្រូឲ្យទៅចូលរៀនជាមួយអង្គការនៅក្នុងព្រៃ ហើយ៣-៤ ខែក្រោយមកទើបអង្គការគេចុះមករៀបចំរណសិរ្សនៅក្នុងខេត្តតាកែវ។ អង្គការនៅទីនេះ គឺគេសំដៅទៅឈ្មោះ សោម (ប្រុស) និង មាស មុត ដែលជាប្រធាន និងអនុប្រធានខេត្តតាកែវ។ ក្នុងចលនារណសិរ្ស នោះខ្ញុំមានស្គាល់គ្រូសាន (ភេទប្រុស នៅរស់) និងគ្រូអឿន (នៅរស់) ព្រមទាំងគ្រូច្រើនទៀត ប៉ុន្តែខ្ញុំមិនចាំឈ្មោះអស់ទេ។ ឈ្មោះសោម និង មាស មុត ចេញមកពីព្រៃ គេហៅពួកគាត់ថា "អង្គការ"។ មេធាវីបានសួរឲ្យសាក្សីឆ្លើយបញ្ជាក់ពាក្យថា "អង្គការ" ថាតើមានន័យយ៉ាងណា? សាក្សីបានបញ្ជាក់ខ្លីៗថា កាលនោះ គេថាអង្គការមិនដឹងជានរណាឲ្យប្រាកដនោះទេ។ សាក្សីបន្តថា ពាក្យថាអង្គការនេះ ដូចជាពិបាក ប៉ុន្តែដូចជាស្រួលថា។ វាជាតួអង្គនៃការងាររបស់ក្រុម ឬបក្សមួយ។ សហករណ៍ក៏ជាអង្គការនៅក្នុងរបបនោះ។ ការងារដែលរៀបចំឡើងមានក្បាល កន្ទុយ និងមេកើយត្រឹមត្រូវ ក៏ជាអង្គការដែរ។ សាក្សីបន្ថែមទៀតថា គណៈឃុំមិនអាចហៅថាអង្គការបានទេ ដោយសារមិនទាន់ពេញលេញ ប៉ុន្តែបើមានស្រុក មានខេត្តទៀត ទើបមានរូបរាងជាអង្គការ។ ឆ្លើយតបនឹងសំណួរបន្ទាប់របស់មេធាវី សាក្សីពេជ ដឹម បានជម្រាបជូនអង្គជំនុំជម្រះថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនក៏ធ្លាប់ហៅសាក្សីថា ជាអង្គការដែរ

ប៉ុន្តែសាក្សីប្រាប់ប្រជាជនវិញថា អង្គការនៅខាងលើ ហើយសាក្សីគ្រាន់តែជាតំណាងរបស់អង្គការប៉ុណ្ណោះ ។ មេធាវីបានដកយកអត្ថបទដកស្រង់ស្តីពីការយល់ដឹងរបស់សាក្សីលើអាទិភាពនៃមន្ទីរ សន្តិសុខក្រាំងតាចាន់ថា "ខ្ញុំឮថា មានមន្ទីរសន្តិសុខក្រាំងតាចាន់ នៅក្រោយវៀតណាមចូលក្នុងឆ្នាំ១៩៧៩" ។ សាក្សីបានទទួលស្គាល់ការដកស្រង់នេះថា ជាចម្លើយត្រឹមត្រូវ ។



ប៉ុល ពត (ដើរមុខ) ពេលត្រឡប់មកពីធ្វើទស្សនកិច្ចនៅប្រទេសចិន ។ អ្នកដើរពីក្រោយ ប៉ុល ពត គឺ ស៊ិន ជា អនុប្រធានផ្នែកទំនាក់ទំនងការបរទេសនៃបក្សកុម្មុយនីស្តចិន ។ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សវនាការស្តាប់សក្ខីកម្មសាក្សី ឡេង ឡាំ

## ថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៣

នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបន្តបើកសវនាការស្តាប់សក្ខីកម្មសាក្សី ឡេង ឡាំ ពាក់ព័ន្ធនឹងការសម្លាប់ប្រជាជន១៧មេសា អតីតទាហាន និងមន្ត្រីរដ្ឋការនៃរបប លន់ នល់ បន្ទាប់ពីខ្មែរក្រហមដណ្តើមកាន់កាប់បានទីក្រុងភ្នំពេញ ។ សវនាការប្រព្រឹត្តទៅអស់រយៈពេលមួយថ្ងៃពេញ ដោយមានវត្តមានជនជាប់ចោទ ខៀវ សំផន ។ ដោយឡែក ជនជាប់ចោទ នួន ជា ចូលរួមសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍នៅក្រោមសាលសវនាការ ពីព្រោះមានបញ្ហាសុខភាពមិនអាចចូលរួមដោយផ្ទាល់បាន ។

ដូចធ្លាប់បានអនុវត្តរួចមក មុននឹងប្រគល់វេទិកាជូនភាគីទាំងអស់សួរដេញដោលសាក្សី ឡេង ឡាំ ប្រធានអង្គជំនុំជម្រះបានប្រាប់អំពីសិទ្ធិ និងករណីកិច្ចរបស់ ឡេង ឡាំ នៅចំពោះមុខភាគីនិងសាធារណជនទូទៅថា ក្នុងនាមជាសាក្សី ឡេង ឡាំ មានសិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតបរាល់សំណួរ ឬការស្នើសុំឲ្យធ្វើអត្ថាធិប្បាយណាមួយដែលអាចដាក់បន្ទុកនាំឲ្យមានពិរុទ្ធភាពលើខ្លួនឯង ។ ដើម្បីសម្រួលដល់ការអនុវត្តសិទ្ធិនេះ ប្រធានអង្គជំនុំជម្រះបានផ្តល់មេធាវី ម៉ម រិទ្ធា ជូនសាក្សី ឡេង ឡាំ ប្រឹក្សាយោបល់មុននឹងសម្រេចឆ្លើយតបសំណួរទាំងឡាយណាដែលនាំឲ្យដាក់បន្ទុកលើខ្លួនឯង ។ ប៉ុន្តែ ឡេង ឡាំ មានករណីកិច្ចឆ្លើយគ្រប់សំណួរទាំងអស់ (លើកលែងតែសំណួរទាំងឡាយណា ដែលចម្លើយនៃសំណួរនោះនាំឲ្យដាក់បន្ទុកលើខ្លួនឯង) របស់ភាគី នូវអង្គហេតុទាំងឡាយណាដែលខ្លួនបានដឹង បានឮ ឬបានឃើញផ្ទាល់ភ្នែក ពោលពុំត្រូវឆ្លើយដោយធ្វើការស្មានៗឡើយ ។ បន្ទាប់មក ប្រធានអង្គជំនុំជម្រះសួរបញ្ជាក់អំពីភាពត្រឹមត្រូវនៃកំណត់ហេតុដែលការិយាល័យសហចៅក្រមស៊ើបអង្កេត បានធ្វើក្នុងអំឡុងពេលកិច្ចសម្ភាសន៍ជាមួយ ឡេង ឡាំ ក្នុងឆ្នាំ២០០៨ ។ ឡេង ឡាំ បញ្ជាក់ថា ភាគច្រើននៃកំណត់ហេតុនេះ មានភាពត្រឹមត្រូវដូចអ្វីដែលគាត់បានឆ្លើយ ។ ប៉ុន្តែមានផ្នែកខ្លះពុំត្រឹមត្រូវឡើយ ។ នៅក្នុងកំណត់ហេតុនោះបានបញ្ជាក់ថា ឡេង ឡាំ បានឃើញគេយកសាកសពមកកប់នៅគុកដំរីស្រុត ចំនួនពីរដង ប៉ុន្តែ ឡេង ឡាំ បញ្ជាក់ថា គាត់បានឃើញតែម្តងប៉ុណ្ណោះ ។

នីតិវិធីសួរដេញដោលសាក្សី ឡេង ឡាំ បានចាប់ផ្តើមដំបូងដោយក្រុមតំណាងសហព្រះរាជអាជ្ញា បន្ទាប់មក ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងក្រុមមេធាវីការពារក្តីជនជាប់ចោទទាំងពីរក្រុម ។ ក្នុងការសួរដេញដោល ឡេង ឡាំ ភាគីទាំងអស់បានផ្តោតសំខាន់ពាក់ព័ន្ធនឹងការសម្លាប់អតីតទាហាន និងមន្ត្រីរដ្ឋការនៃរបប លន់ នល់ និងប្រជាជន១៧មេសា នៅស្រុកសាមគ្គីមានជ័យ (ពីមុនហៅស្រុកកំពង់ត្រឡាចលើ ឬស្រុក១២) ខេត្តកំពង់ឆ្នាំង ដែលត្រូវបានធ្វើបន្ទាប់ពីខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ ។

ឡេង ឡាំ មានអាយុ ៥៨ឆ្នាំ ប្រកបរបរធ្វើស្រែចម្ការបច្ចុប្បន្នរស់នៅភូមិច្រកសង្កែ ឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ។ ឪពុកឈ្មោះ ព្រីង ឡេង ម្តាយឈ្មោះ នួន សែម ប្រពន្ធឈ្មោះ នូ រ៉េម មានកូនចំនួន១០នាក់ ។ នៅចន្លោះឆ្នាំ ១៩៧២-១៩៧៥ ឡេង ឡាំ ធ្វើជាកងឈ្លបនៅភូមិច្រកសង្កែ ឃុំស្វាយជុក ស្រុកកំពង់ត្រឡាច ។ ក្នុងអំឡុងពេលនោះ ក្រៅពីធ្វើកងឈ្លប ឡេង ឡាំ ចូលរួមបង្កបង្កើនផលនៅសមរភូមិក្រោយ ពោលគឺពុំដែលទៅសមរភូមិមុខប្រយុទ្ធជាមួយកងទ័ពរបស់ លន់ នល់ ឡើយ ។ គណៈឃុំឈ្មោះ ណាន (តាមការបង្ហាញឯកសាររបស់ ឌេល លីសាក់ ស្រ្តីម្នាក់នេះត្រូវជាសាច់ញាតិរបស់ នួន ជា) គណៈស្រុកឈ្មោះ ស្រ៊ន និងគណៈតំបន់ឈ្មោះ សារ៉ុន ។ ចំណែកឈ្មោះគណៈភូមិភាគ ឡេង ឡាំ ពុំស្គាល់ឡើយ ។

ឡេង ឡាំ បញ្ជាក់ថា នៅឆ្នាំ១៩៧៥ ប្រជាជនប្រមាណ ៣០០គ្រួសារត្រូវបានខ្មែរក្រហមជម្លៀសឲ្យមករស់នៅក្នុងឃុំស្វាយជុក ។ ប្រជាជនទាំងនោះមកពីទីក្រុងភ្នំពេញ និងទីរួមខេត្តកំពង់ឆ្នាំង ។ ប្រជាជនទាំងនោះធ្វើដំណើរដោយថ្មើរជើង មាន

ជីវភាពខ្វះខាត ខ្វះមានជំងឺដោយគ្មានថ្នាំព្យាបាល រស់នៅយ៉ាងរប៉ាត់រប៉ាយ ខ្លះនៅក្រោមម្លប់ឈើ និងខ្លះទៀតនៅក្រោមផ្ទះរបស់ប្រជាជនមូលដ្ឋាន ។ មករស់នៅក្នុងឃុំស្វាយជុកបានចំនួន ៣ថ្ងៃ ប្រជាជនទាំងអស់ត្រូវបានបង្គាប់ឲ្យធ្វើប្រវត្តិរូបដើម្បីបញ្ជាក់អំពីសមាសភាពរបស់ខ្លួន ។ ឡេវ ឡាំ បញ្ជាក់ថា ណាន ដែលជាគណៈឃុំ បានប្រាប់មេភូមិទាំងអស់ឲ្យកត់ត្រា និងប្រមូលប្រវត្តិរបស់ប្រជាជនដែលជម្លៀសមកពីភ្នំពេញ និងកំពង់ឆ្នាំងទាំងអស់ ។ នៅពេលធ្វើប្រវត្តិរូប ប្រធានភូមិ ណែនាំប្រជាជនទាំងអស់ឲ្យប្រាប់ការពិតមិនត្រូវកុហក បើពុំនោះសោតមិនឲ្យរួចខ្លួនឡើយ ។ ទោះបីជាយ៉ាងណាក្តី ប្រធានភូមិទាំងនោះពុំបានចាត់តាំងឲ្យមានអ្នកពិនិត្យតាមដានអំពីភាពត្រឹមត្រូវនៃប្រវត្តិរូបទាំងនោះឡើយ ។ បន្ទាប់ពីបានធ្វើរួចប្រធានភូមិបានបញ្ជូនប្រវត្តិរូបទាំងនោះឲ្យ ណាន ដែលជាគណៈឃុំ ហើយ ណាន បញ្ជូនបន្តទៅ ស្រ៊ិន ដែលជាគណៈស្រុក ។ ក្រោយពីធ្វើប្រវត្តិរូបរួច ប្រជាជនត្រូវបានបែងចែកជាពីរប្រភេទ គឺប្រជាជនធម្មតា និងប្រជាជនមិនធម្មតា ។ ប្រជាជនធម្មតា សំដៅប្រជាជនដែលជាកសិករ ។ ប្រជាជនប្រភេទនេះត្រូវបានអនុញ្ញាតឲ្យនៅធ្វើស្រែ និងបន្តរស់នៅក្នុងឃុំស្វាយជុកដដែល ។ ប្រជាជនមិនធម្មតា ឬហៅម្យ៉ាងទៀតថា ប្រជាជនស្វាយត្រាន សំដៅទៅដល់អ្នកដែលធ្លាប់ធ្វើជាឈ្លបភូមិ ឬជាអតីតទាហាន លន់ នល់ ត្រូវបានបញ្ជូនចេញពីឃុំស្វាយជុក ដោយប្រាប់ថា ឲ្យទៅរស់នៅភូមិផ្សេង ។ ត្រង់ចំណុចនេះ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ឌេល លីសាក់ ដាក់បង្ហាញឯកសារកំណត់ហេតុដែល ឡេវ ឡាំ បានឆ្លើយនៅចំពោះមុខចៅក្រមស៊ើបអង្កេតថា ប្រជាជនមិនធម្មតាត្រូវបាន ស្រ៊ិន បញ្ជាឲ្យ ណាន យកទៅសម្លាប់ចោល ដែលក្នុងចំណោមនោះមានឪពុកមារបស់គាត់ម្នាក់ដែរ ។ ពីមុនឪពុកមារបស់ ឡេវ ឡាំ ធ្វើជាទាហានក្នុងរបប លន់ នល់ ឈរជើងនៅលង្វែក ។ ឡេវ ឡាំ បញ្ជាក់បន្ថែមថា គាត់បានឃើញ ស្រ៊ិន, ណាន និងមេភូមិទាំងអស់ជួបប្រជុំគ្នា នៅក្នុងមន្ទីរកងឈ្លបមួយនៅជិតភូមិប្រកសង្កែ ។ ក្រោយពីកិច្ចប្រជុំនោះមក ប្រជាជនដែលត្រូវបានចាត់ទុកថាជាប្រជាជនមិនធម្មតា ត្រូវបាននាំចេញពីភូមិ និងមួយចំនួនទៀតបាត់ខ្លួនជាបណ្តើរៗ ។ ឡេវ ឡាំ ធ្លាប់នាំប្រជាជនទាំងនោះយកទៅទីតាំងសម្លាប់មនុស្សនៅភូមិប្រកសង្កែ តាមការបញ្ជារបស់ អួន ប្រធានភូមិ ។ ប្រជាជនដែល ឡេវ ឡាំ នាំទៅនោះមានចំនួន២០នាក់ មានទាំងកូនក្មេង និងមនុស្សចាស់ ។ ឡេវ ឡាំ រួមជាមួយយោធាខ្មែរក្រហម ៣នាក់ផ្សេងទៀត បានបណ្តើរប្រជាជនទាំងនោះទៅ ហើយប្រគល់បន្តឲ្យយោធាស្រុកដែលកំពុងរង់ចាំទទួលជាស្រេច ។ យោធាស្រុកមានគ្នា ១២នាក់ បានបញ្ជូនប្រជាជនទាំងនោះទៅដល់កន្លែងសម្លាប់តែម្តង ។ មុននឹងនាំទៅយោធាស្រុកបានប្រាប់ប្រជាជនទាំងនោះថា «ទៅជួបអង្គការថ្នាក់លើដើម្បីបើកអង្ករ ប៉ុន្តែត្រូវចងមុខសិនទើបអាចទៅយកអង្ករបាន» ។ ប្រជាជនទាំង នោះត្រូវបានយោធាស្រុកនាំទៅម្តង១០នាក់ៗ ដោយចងបិទមុខ និងដៃទាំងពីរត្រូវបានចងស្ទាបសេកមកក្រោយ ។ ឡេវ ឡាំ បានអះអាងថា គាត់នៅចម្ងាយប្រហែល៣០ម៉ែត្រពីកន្លែងសម្លាប់ប្រជាជនទាំងនោះ ។ មុនពេលសម្លាប់ យោធាស្រុកបានរាប់ពីមួយទៅដល់បីទើបវាយសម្លាប់ ។ ឧបករណ៍ដែលត្រូវបានប្រើដើម្បីសម្លាប់ រួមមាន ដំបងគល់ឫស្សី និងដែកគ្វៀរទេះ ។ ពេជ្ឈឃាតមិនប្រើកាំភ្លើងដើម្បីសម្លាប់មនុស្សឡើយ ព្រោះខ្លាចឮសូរសំឡេងនាំឲ្យបែកការណ៍ ។ គួរបញ្ជាក់ថា ហេតុការណ៍នៃការសម្លាប់នេះ មេធាវីអន្តរជាតិ វិចទ័រ កូបប៉េ បានដកស្រង់ចម្លើយរបស់ ឡេវ ឡាំ ដែលបានផ្តល់ជូនចៅក្រមស៊ើបអង្កេតថា គាត់បានឃើញការសម្លាប់នេះដោយផ្ទាល់ភ្នែក ។ ប្រជាជនទាំងនោះ ត្រូវបានដាក់ឲ្យអង្គុយនៅជិតមាត់រណ្តៅ បន្ទាប់មកត្រូវបានវាយសម្លាប់ ដោយរុញទម្លាក់ចូលទៅក្នុងរណ្តៅតែម្តង ។ បន្ទាប់មកមេធាវីសួរបញ្ជាក់ ឡេវ ឡាំ ឲ្យបានច្បាស់ថា គាត់បានឃើញការសម្លាប់នោះដោយផ្ទាល់ដូចបានបញ្ជាក់ជូនចៅក្រមស៊ើបអង្កេត ឬពេលសម្លាប់នោះគាត់នៅពីចម្ងាយដូចបានបញ្ជាក់ជូនអង្គជំនុំជម្រះ ។ មកដល់ចំណុចនេះ យើងសង្កេតឃើញភាពមិនច្បាស់លាស់បានកើតឡើង គឺសាក្សីចាប់ផ្តើមមានការភាន់ច្រឡំ និងមិនអាចឆ្លើយបានឡើយ ។

ក្រៅពីទីតាំងសម្លាប់មនុស្សនៅភូមិប្រកសង្កែ តំណាងសហព្រះរាជអាជ្ញាបានដាក់បង្ហាញចម្លើយរបស់សាក្សីមួយចំនួនទៀត (មិនបញ្ចេញឈ្មោះ) ដែលបានផ្តល់សក្ខីកម្មទាក់ទងនឹងទីតាំងសម្លាប់មនុស្សជាច្រើនទៀតនៅក្នុងឃុំស្វាយជុក ។ សាក្សីទាំង

នោះបានបញ្ជាក់ថា ប្រជាជន១៧មេសា ចំនួន ៣០ គ្រួសារត្រូវបាននាំយកទៅសម្លាប់នៅភូមិថ្មីខ្មែរ និងភូមិស្រែវាល់ ។ ឡេវ ឡាំ បញ្ជាក់បន្ថែមថា ភូមិថ្មីខ្មែរ ស្ថិតនៅក្នុងឃុំស្វាយជុកខាងត្បូង ។ ខេល លីសាក់ បានបង្ហាញឯកសារសាក្សីពីររូបផ្សេងទៀត ដែលថា ប្រជាជន១៧មេសា ត្រូវបានជម្លៀសមកទុកនៅវត្តត្បែងខ្ពស់ ក្រោយមកត្រូវបាននាំយកទៅសម្លាប់នៅកុករនាម ត្រពាំងអណ្តូង និងត្រពាំងខ្ពុង ។ ទោះបីជាយ៉ាងណាក្តី ឡេវ ឡាំ ពុំបានដឹងអំពីការសម្លាប់មនុស្សនៅទីតាំងទាំងបីនេះឡើយ ។

នៅក្រោយឆ្នាំ១៩៧៩ ឡេវ ឡាំ បានធ្វើដំណើរទៅព្រៃទទឹងនៅខាងលិចគុកដីស្រុត ។ នៅទីនោះ ឡេវ ឡាំ បានឃើញរណ្តៅសាកសពប្រមាណជាង២០ត្រូវបានប្រជាជនគាស់ដើម្បីរកមាស និងវត្ថុមានតម្លៃផ្សេងៗ ។ រណ្តៅនីមួយៗមានលលាក្បាលមនុស្សពី ២០ ទៅ ៣០នាក់ ហើយនៅមានរណ្តៅជាច្រើនទៀតមិនទាន់ត្រូវបានគាស់ ។



ពិធីសម្ពោធអាងទំនប់ទឹកកំពីងពួយក្នុងរបបខ្មែរក្រហម ដោយមានការចូលរួមពីសំណាក់កម្មាភិបាលខ្មែរក្រហមជាន់ខ្ពស់ ។
(បណ្ណសារ : មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សវនាការស្តាប់សក្ខីកម្មសាក្សី ឯក ហេន

## ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៣

នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តីខ្មែរក្រហម បានបន្តបើកសវនាការស្តាប់សក្ខីកម្មសាក្សី ឯក ហេន ដែលជាអតីតបុគ្គលិកនៅក្នុងមន្ទីរកាត់ដេរមជ្ឈិម ក-៩ ដែលជាសាខានៃមន្ទីរ៨៧០ ។ សក្ខីកម្មរបស់សាក្សី ឯក ហេន បានផ្តោតជាសំខាន់លើការបាត់ខ្លួនកម្មាភិបាលជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងបុគ្គលិកនៅក្នុងមន្ទីរក-៩ ។



នីតិវិធីក្នុងការសួរដេញដោលសាក្សី ឯក ហេន គឺចាប់ផ្តើម ដោយតំណាងសហព្រះរាជអាជ្ញា បន្ទាប់មក មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងចុងក្រោយ គឺក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា និង ខៀវ សំផន ។

### ១) ប្រវត្តិសាវតាររបស់សាក្សី ឯក ហេន

នៅមុនពេលប្រគល់វេទិកាសួរដេញដោលសាក្សីជូនភាគីប្រធានអង្គជំនុំជម្រះ គឺចៅក្រម និល ណុន បានសាកសួរសាក្សីអំពីប្រវត្តិសាវតារ និងជូនដំណឹងអំពីសិទ្ធិ និងកាតព្វកិច្ចដែលសាក្សីមាន ។ ឆ្លើយតបនឹងសំណួររបស់ប្រធានអង្គជំនុំជម្រះ សាក្សី ឯក ហេន បានបញ្ជាក់ថា សព្វថ្ងៃលោកស្រីមានអាយុ ៥៦ឆ្នាំ រស់នៅអន្លង់ជ័យក្រោម ឃុំមហាខ្ញូង ស្រុកកោះសូទិន ខេត្តកំពង់ចាម ។ មានមុខរបរជាអ្នកធ្វើស្រែចម្ការ ។ ឪពុកឈ្មោះ ជន ម្តាយ លន់ និងមានប្តី សុង ផល និងមានកូន៤នាក់ ។

បន្ទាប់មក អង្គជំនុំជម្រះបានជម្រាបសាក្សីអំពីសិទ្ធិក្នុងការមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង ប៉ុន្តែសាក្សីមានករណីកិច្ចត្រូវឆ្លើយតបនឹងសំណួររបស់ភាគី លើកលែងតែសំណួរនោះនាំឲ្យដាក់បន្ទុកលើខ្លួនឯង ។ សាក្សី ឯក ហេន បានបញ្ជាក់ថា គាត់ធ្លាប់ផ្តល់សម្ភាសន៍ជូនមន្ត្រីស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងឆ្នាំ២០០៣ និងធ្លាប់បានផ្តល់បទសម្ភាសន៍ជូនការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងឆ្នាំ២០០៨ ។

### ២) ការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា

តំណាងសហព្រះរាជអាជ្ញាជាតិ សុង ឆវិន្ទ ត្រូវបានអង្គជំនុំជម្រះផ្តល់វេទិកាជូនដើម្បីចោទសួរសាក្សី ឯក ហេន ។ សំណួររបស់តំណាងសហព្រះរាជអាជ្ញា ឆវិន្ទ បានផ្តោតជាសំខាន់លើបទពិសោធន៍ផ្ទាល់របស់សាក្សីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

សាក្សី ឯក ហេន បានថ្លែងរៀបរាប់អំពីបទពិសោធន៍របស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យថា នៅក្នុងឆ្នាំ១៩៧៥ គាត់បានសម្រេចចិត្តចូលធ្វើជាយុទ្ធនារី និងបានចូលរួមប្រយុទ្ធនៅក្នុងសមរភូមិ នៅស្រុកកញ្ជ្រៀច ។ នៅក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សាក្សីត្រូវបានបញ្ជូនឲ្យទៅជួយដកស្ទូងប្រជាជន និងធ្វើការនៅកំពង់សោម ដើម្បីបោសសម្អាត និងប្រមូលរៀបចំរបស់របរចាស់ៗឲ្យមានសណ្តាប់ធ្នាប់ដើម្បីត្រៀមទទួលភ្ញៀវ ។ បន្ទាប់ពីការងារបោសសម្អាតបានបញ្ចប់ សាក្សីត្រូវបានបញ្ជូនទៅប្រមូលក្តារ និងឈើនៅស្រែអំបិលរយៈពេលបីខែបន្ថែមទៀត នៅមុនពេលត្រូវបានបញ្ជូនមកទីក្រុងភ្នំពេញនៅចុងឆ្នាំ១៩៧៦ ។ សាក្សីបន្តថា នៅពេលមកដល់ទីក្រុងភ្នំពេញ សាក្សីឃើញទីក្រុងភ្នំពេញមានសភាពស្ងាត់ជ្រងំ ។ សាក្សីបានបន្តថា បន្ទាប់ពីមកដល់ទីក្រុងភ្នំពេញ គាត់ត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅកន្លែងកាត់ដេរមជ្ឈិម ដែលមានទីតាំងនៅជិតផ្សារអូរឫស្សី រហូតដល់ពេលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំតែម្តង ។ កន្លែងកាត់ដេរមជ្ឈិមនេះ ត្រូវបានស្គាល់ថាជា មន្ទីរក-៩ ដែលជាសាខានៃមន្ទីរ៨៧០ ។ សាក្សី ឯក ហេន បានថ្លែងបន្តថា ការងារនៅក្នុងមន្ទីរនោះត្រូវបានបែងចែកចេញជាពីរ ។ ទី១ ការងារសន្តមនិយម ដែលត្រូវក្រោកពីព្រលឹម ដើម្បីស្រោចបន្លែ និង

ទី២ ជាការងាររស្តូល ដែលត្រូវចាប់ផ្តើមពីម៉ោង៧ព្រឹក នៅក្រោយពេលបញ្ចប់ការងារសន្តមនិយម ។

បន្ទាប់មក តំណាងសហព្រះរាជអាជ្ញា សុង ឆវីន្ត បានលើកយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ដែលធ្លាប់បានផ្តល់ជូនការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីស្នើឲ្យសាក្សីធ្វើការបញ្ជាក់ឡើងវិញ ។ ឃ្លាដែលសាក្សីឆ្លើយជូនបុគ្គលិកការិយាល័យសហចៅក្រមស៊ើបអង្កេតនៅពេលនោះ មានអត្ថន័យដូច្នេះថា «ខ្ញុំឃើញមានការចាប់ខ្លួនមនុស្សឡើងឡានឃុបបិទជិត ដោយកងទ័ពមានអាវុធ ។ មុនដំបូងគេចាប់មេៗ បន្ទាប់មក ចាប់អនុនិងសមាជិកណាដែលមានការពាក់ព័ន្ធនឹងខ្សែខ្មៅ និងបូព៌ា ដែលគេចោទថាក្បត់ ។ កែវ ជាប្រធានរោងចក្រត្រូវគេចាប់យកទៅបាត់នៅឆ្នាំ១៩៧៧ ដោយជាប់ខ្សែបូព៌ា» ។ បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាបានសួរសាក្សីថា តើសាក្សីឃើញមានការចាប់ខ្លួនឈ្មោះ កែវ ដោយផ្ទាល់ភ្នែកដែរឬយ៉ាងណា? សាក្សីបានបញ្ជាក់ថា នៅពេលនោះគាត់បានឃើញឡានមកដឹកឈ្មោះ កែវ ដែលជាប្រធានរោងចក្រយកទៅបាត់ ហើយការចាប់ខ្លួននេះ គឺធ្វើឡើងម្តងមួយៗ ។ រីឯឈ្មោះ គន្ធ ដែលធ្វើការនៅក្នុងកន្លែងគាត់ដែរជាមួយសាក្សី ក៏បានបាត់ខ្លួននៅពេលនោះដែរ បន្ទាប់ពីការបាត់ខ្លួនរបស់ឈ្មោះ កែវ ។ សាក្សីបន្តថា អ្នកធ្វើការជាមួយគ្នាចំនួន៤នាក់បានបាត់ខ្លួន ។

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ឃីត រ៉េន័រ បានបន្តពីសហការីរបស់ខ្លួន ដោយផ្តើមចោទសួរសាក្សីទាក់ទងនឹងសម្តីរបស់សាក្សីដែលធ្លាប់បានអះអាងប្រាប់បុគ្គលិកនៃការិយាល័យសហចៅក្រមស៊ើបអង្កេតថា ខៀវ សំផន ធ្លាប់បានដឹកនាំវគ្គសិក្សារៀនសូត្រមួយ នៅក្នុងបុរីកីឡា ។ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ រ៉េន័រ បានស្នើឲ្យសាក្សីធ្វើការបញ្ជាក់ឡើងវិញចំពោះពាក្យសម្តីដែលសាក្សីធ្លាប់បានផ្តល់ជូនការិយាល័យសហចៅក្រមស៊ើបអង្កេត ។ សាក្សី ឯក ហេន បានទទួលស្គាល់ចំពោះអ្វីដែលតំណាងសហព្រះរាជអាជ្ញាបានលើកឡើង និងរៀបរាប់ថា នៅក្នុងវគ្គសិក្សារៀនសូត្រក្នុងបុរីកីឡានៅពេលនោះ មានអ្នកចូលរួមប្រមាណ៤០០នាក់ ដោយមាន ខៀវ សំផន ជាអ្នកធ្វើបទបង្ហាញ ។ ខៀវ សំផន បានស្នើឲ្យអ្នកចូលរួមទាំងអស់ខិតខំប្រឹងធ្វើការដើម្បីអភិវឌ្ឍន៍ប្រទេស និងបាននិយាយអំពីការតស៊ូ ការសាមគ្គីគ្នា ដើម្បីស្តារសេដ្ឋកិច្ចប្រទេសជាតិ ដែលទើបតែងើបចេញពីសង្គ្រាម ។ សាក្សី ឯក ហេន បន្តថា ក្នុងអំឡុងពេលនៃវគ្គសិក្សារៀនសូត្រនោះ ខៀវ សំផន ពុំបានលើកឡើងអំពីបញ្ហាខ្មាំងទេ ។ ប៉ុន្តែបាននិយាយអំពីការចាប់ ប៉ង់ ដែលត្រូវបានអះអាងថា ជាប្រធានមន្ទីរ៨៧០ ។

ទាក់ទងនឹងជនជាប់ចោទ នួន ជា សាក្សីបានបញ្ជាក់ថា គាត់ក៏ធ្លាប់បានចូលរួមវគ្គរៀនសូត្រសិក្សានយោបាយ ដែលមាន នួន ជា ជាអ្នកធ្វើបទបង្ហាញដែរ ។ សាក្សីបន្តថា នៅក្នុងអំឡុងនៃវគ្គសិក្សារៀនសូត្រ នួន ជា បានលើកឡើងអំពីការចាប់ខ្លួន កុយ ធួន ដែលត្រូវបានចោទប្រកាន់ថាជាជនក្បត់ ហើយកម្មាភិបាលមួយចំនួនក្នុងភូមិភាគឧត្តរក៏ត្រូវបានចោទប្រកាន់ថាក្បត់ដែរ ។ នួន ជា បានប្រាប់អ្នកចូលរួមនៅពេលនោះ ឲ្យចេះសាមគ្គីគ្នា និងត្រូវកែខ្លួន ប្រសិនបើមានជាប់ពាក់ព័ន្ធនឹងខ្សែរយៈណាមួយ ។

### ៣) ការសួរដេញដោលដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

មេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី ស៊ីន ស៊ីវ៉ន ត្រូវបានអង្គជំនុំជម្រះផ្តល់វេទិកាដើម្បីចោទសួរសាក្សី ឯក ហេន ពីព្រឹត្តិការណ៍ដែលសាក្សីបានឃើញ បានដឹង និងបានឮទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ។ មេធាវី ស៊ីវ៉ន បានចោទសួរសំណួរជាច្រើនទាក់ទងនឹងប្រវត្តិសាវតាររបស់សាក្សីសារជាថ្មីឡើងវិញ ប៉ុន្តែសំណួរទាំងនោះត្រូវបានអង្គជំនុំជម្រះចាត់ទុកថា ជាសំណួរដែលមានលក្ខណៈច្រំដែល និងពុំមានប្រយោជន៍ដែលអាចឲ្យអង្គជំនុំជម្រះយកទៅវិភាគពិចារណា និងផ្ទៀងផ្ទាត់ជាមួយភ័ស្តុតាង ។ អង្គជំនុំជម្រះបានណែនាំឲ្យមេធាវីជ្រើសរើសយកសំណួរណាដែលមានជាប់ពាក់ព័ន្ធនឹងអង្គហេតុ ដើម្បីចោទសួរសាក្សី ។ បន្ទាប់មក មេធាវី ស៊ីវ៉ន បានបន្តសួរទាក់ទងនឹងប្រវត្តិការងាររបស់សាក្សីនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ប៉ុន្តែសំណួរដែលមេធាវីបានចោទសួរ ហាក់បីដូចជាពុំមានភាពជាប់ពាក់ព័ន្ធនឹងអង្គហេតុដែលអង្គជំនុំជម្រះមានបំណងចង់ស្តាប់ ដែលជាហេតុធ្វើឲ្យមេធាវីការពារក្តី ខៀវ សំផន ក្រោកឡើងជំទាស់ជាញឹកញាប់ថា សំណួរភាគច្រើនដែលមេធាវី

ស៊ីវ៉ន ចោទសួរគឺពុំជាប់ ទាក់ទងនឹងអង្គហេតុនៃសំណុំរឿង០០២/០១ និងជាសំណួរពុំបានចូលរួមចំណែកដល់ការស្វែងរកការពិត ។ អង្គជំនុំជម្រះយល់ស្របចំពោះការលើកឡើងរបស់មេធាវីការពារក្តី ខៀវ សំផន និងបានបង្គាប់ឲ្យមេធាវី រៀបចំសំណួររបស់ខ្លួនឡើងវិញ ។ បន្ទាប់មក ដោយសារអស់សំណួរសម្រាប់សួរសាក្សី មេធាវីតំណាង ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ចប់ការសួរដេញដោលរបស់ខ្លួន ។

អង្គជំនុំជម្រះបានប្រគល់វេទិកាជូនក្រុមមេធាវីការពារក្តីជនជាប់ចោទដើម្បីសួរដេញដោលសាក្សី ឯក ហេន ។

## ៤) ការសួរដេញដោលដោយមេធាវីការពារក្តីជនជាប់ចោទ

### ក) ក្រុមមេធាវីការពារក្តី នួន ជា

មេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ នួន ជា គឺលោក វ៉ិចទ័រ កូបប៉េ បានចោទសួរសាក្សី ឯក ហេន ដោយផ្តោតជាសំខាន់លើមូលហេតុនៃការចូលរួមធ្វើបដិវត្តន៍ប្រឆាំងនឹងរបប លន់ នល់ និងតួនាទីរបស់សាក្សីនៅក្នុងកងទ័ពបដិវត្តន៍ ។ សាក្សី ឯក ហេន ពុំបានឆ្លើយបញ្ជាក់អំពីមូលហេតុដែលនាំឲ្យគាត់ ចូលក្នុងចលនាបដិវត្តន៍ទេ និងបានបញ្ជាក់ថា នៅក្នុងចលនាបដិវត្តន៍នោះគាត់ពុំមានតួនាទីអ្វីទេ គឺគ្រាន់តែជាយុទ្ធនារីធម្មតា ស្ថិតនៅក្នុងកងវរយតែប៉ុណ្ណោះ ។ សាក្សីបន្តថា ថ្វីត្បិតតែគាត់ជាយុទ្ធនារីក៏ពិតមែន ប៉ុន្តែ ពុំធ្លាប់បានចូលក្នុងសមរភូមិប្រយុទ្ធជាមួយនឹងទាហាន លន់ នល់ ទេ ដោយសារនៅជាប់រវល់ហ៊ឹកហ្វាត់ ។ ក្រោយពេលហ៊ឹកហ្វាត់ចប់យោធាខ្មែរក្រហមដណ្តើមបានទីក្រុងភ្នំពេញតែម្តង ។ ឆ្លើយតបនឹងសំណួររបស់មេធាវីការពារក្តី នួន ជា ថាតើខ្មែរក្រហមប្រព្រឹត្តដូចម្តេចលើទាហាន លន់ នល់ ដែលបានចុះចាញ់? សាក្សីបានអះអាងថា ពុំបានដឹងថាតើខ្មែរក្រហមប្រព្រឹត្តបែបណាចំពោះទាហាន លន់ នល់ នោះទេ ដោយសារសាក្សីគ្រាន់តែជាយុទ្ធនារី និងពុំបានចូលប្រយុទ្ធដោយផ្ទាល់នៅក្នុងសមរភូមិ ។ សូម្បីតែក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ក៏ពុំមានព័ត៌មានអ្វីទាក់ទងនឹងការធ្វើទារុណកម្មចំពោះទាហានរបស់ លន់ នល់ ដែរ ព្រោះនៅពេលនោះ ពុំមាននរណាម្នាក់អាចដើរ និងនិយាយគ្នាដោយសេរីបាន ។

### ខ) ក្រុមមេធាវីការពារក្តី ខៀវ សំផន

បន្ទាប់ពីមេធាវីការពារក្តី នួន ជា អង្គជំនុំជម្រះបានប្រគល់វេទិកាជូនក្រុមមេធាវីការពារក្តី ខៀវ សំផន ដើម្បីចោទសួរសាក្សី ។ សំណួរដំបូងរបស់មេធាវីការពារក្តី ខៀវ សំផន ផ្តោតលើវគ្គសិក្សារៀនសូត្រដែលសាក្សីបានចូលរួម ។ លោក អាកទួរ វ៉ែកកែន មេធាវីអន្តរជាតិការពារក្តី ខៀវ សំផន បានស្នើសាក្សីឲ្យបញ្ជាក់សារជាថ្មីឡើងវិញអំពីកាលបរិច្ឆេទនៃវគ្គសិក្សារៀនសូត្រដែលគាត់បានចូលរួមនៅបុរីកីឡា ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ឆ្លើយតបនឹងសំណើនេះ សាក្សី ឯក ហេន បានបញ្ជាក់ថា សាក្សីធ្លាប់បានចូលរួមក្នុងវគ្គសិក្សារៀនសូត្រនយោបាយពីរលើក ។ លើកទី១ នៅចុងឆ្នាំ១៩៧៦ ដែលអ្នកធ្វើបទបង្ហាញនៃវគ្គសិក្សារៀនសូត្រនេះចង់ឲ្យមានការរួបរួមសាមគ្គីគ្នាដើម្បីអភិវឌ្ឍន៍ប្រទេសដែលទើបនឹងងើបចេញពីសង្គ្រាម និងលើកទី២ នៅក្នុងឆ្នាំ១៩៧៨ ផ្តោតសំខាន់លើការចាប់ខ្លួន កុយ ធួយ និងខ្សែក្បត់ ។ មេធាវី វ៉ែកកែន ស្នើឲ្យសាក្សីបញ្ជាក់ថា តើនរណាជាអ្នកដឹកនាំវគ្គសិក្សារៀនសូត្រលើកទី១ និងនរណាជាអ្នកដឹកនាំវគ្គសិក្សារៀនសូត្រលើកទី២ដែលសាក្សីបានចូលរួម ។ មកដល់ចំណុចនេះ សាក្សីហាក់បីដូចជាមានការភាន់ច្រឡំ និងបានទទួលស្គាល់ថា គាត់មានការភ្លេចភ្លាំងអំពីអ្នកដែលបានដឹកនាំវគ្គរៀនសូត្រនៅពេលនោះ ។ ប៉ុន្តែបើយោងតាមការលើកឡើងរបស់សាក្សីនៅអំឡុងពេលនៃការផ្តល់បទសម្ភាសន៍ជាមួយ ការិយាល័យសហចៅក្រមស៊ើបអង្កេត សាក្សី ឯក ហេន បានអះអាងថា ខៀវ សំផន គឺជាអ្នកដឹកនាំវគ្គសិក្សារៀនសូត្រលើកទី១នៅចុងឆ្នាំ១៩៧៦ និង នួន ជា ជាអ្នកដឹកនាំវគ្គសិក្សារៀនសូត្រលើកទី២នៅក្នុង ឆ្នាំ១៩៧៨ ។

ការស្នើរបស់មេធាវីការពារក្តី ខៀវ សំផន ឲ្យសាក្សីបញ្ជាក់អំពីអ្នកដឹកនាំវគ្គរៀនសូត្រនយោបាយ ត្រង់ផ្នែកនេះ គឺដើម្បីបង្ហាញថា ខៀវ សំផន ពុំបានដឹកនាំវគ្គសិក្សារៀនសូត្រដែលនិយាយអំពីការចាប់ខ្លួន និងខ្សែរយៈក្បត់ ។

បន្ទាប់មកអង្គជំនុំជម្រះបានបញ្ចប់ការស្តាប់សក្ខីកម្មរបស់សាក្សី ឯក ហេន នៅត្រឹមរសៀលថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៣ ហើយបន្តស្តាប់សក្ខីកម្មរបស់សាក្សីមួយរូបផ្សេងទៀត ដែលមានឈ្មោះ ស៊ុម អាឡាត់ នៅរសៀលថ្ងៃដដែល ។

# សវនាការស្តាប់សក្ខីកម្មរបស់សាក្សី ស៊ុំ អាឡាត់

## ថ្ងៃទី៣-៤ ខែកក្កដា ឆ្នាំ២០១៣

នៅថ្ងៃទី៣-៤ ខែកក្កដា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបន្តបើកសវនាការស្តាប់សក្ខីកម្មសាក្សី ស៊ុំ អាឡាត់ ដែលជាអតីតទាហាននៅក្នុងរបប លន់ នល់ ។ សវនាការស្តាប់សក្ខីកម្មសាក្សីរូបនេះបានផ្តោតសំខាន់ទៅលើស្ថានភាពក្រោយពេលខ្មែរក្រហមឡើងកាន់អំណាចនៅខេត្តពោធិ៍សាត់ កិច្ចប្រជុំផ្សេងៗទាក់ទងនឹងការសម្លាប់ទាហាន លន់ នល់ និងការដឹកជញ្ជូនទាហានទាំងនោះយកទៅសម្លាប់នៅមន្ទីរទួលពោធិ៍ជ្រៃ ។ នីតិវិធីនៃការសួរដេញដោលសាក្សី ស៊ុំ អាឡាត់ បានចាប់ផ្តើមដោយប្រធានអង្គជំនុំជម្រះទាក់ទងនឹងប្រវត្តិសាវតាររបស់សាក្សី និងជាបន្តបន្ទាប់មានតំណាងសហព្រះរាជអាជ្ញា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តីទាំងពីរក្រុម ។

សាក្សី ស៊ុំ អាឡាត់ មានអាយុ៦០ឆ្នាំ រស់នៅភូមិកញ្ជើបាយដាច ឃុំវាល ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ សព្វថ្ងៃជាមន្ត្រីចូលនិវត្តន៍ ។ សាក្សីមានឪពុកឈ្មោះ សុង ស៊ុំ ម្តាយឈ្មោះ ស៊ីង អឿង និងប្រពន្ធឈ្មោះ លី គន្ធា មានកូន៧នាក់ ។ សាក្សីធ្លាប់បានផ្តល់បទសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេតកាលពីឆ្នាំ២០០៨ នៅការិយាល័យនៃមន្ទីរវិចិត្រសិល្បៈ ខេត្តពោធិ៍សាត់ ។

### ១) ការសួរដេញដោលដោយតំណាងសហរាជអាជ្ញា

ទាក់ទងនឹងប្រវត្តិសាវតាររបស់សាក្សី សហព្រះរាជអាជ្ញារងអន្តរជាតិ វីល្លៀម ស្មីត បានចោទសួរសាក្សីអំពីតួនាទីក្រោយពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ សាក្សីបញ្ជាក់ថា សព្វថ្ងៃខ្លួនបានចូលនិវត្តន៍ ប៉ុន្តែបានបញ្ជាក់ថា ពីមុនធ្លាប់បានទទួលតួនាទីជាអនុប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ចាប់តាំងពីឆ្នាំ១៩៨៤ មកម្ល៉េះ ។

តំណាងសហព្រះរាជអាជ្ញាបានលើកយកកំណត់ហេតុស្តាប់ចម្លើយ ដែលសាក្សីបានឆ្លើយតបទៅកាន់អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតទាក់ទងនឹងការប្រមូលឯកសារ និងភស្តុតាងអំពីរបបខ្មែរក្រហម ដើម្បីយកមកចងក្រងធ្វើជាឯកសារអប់រំប្រចាំខេត្តពោធិ៍សាត់ ។ សាក្សី ស៊ុំ អាឡាត់ បានបញ្ជាក់ថា នៅពេលនោះសាក្សីពិតជាបានចូលរួមនៅក្នុងវគ្គរៀនសូត្រ ដែលរៀបចំដោយក្រសួងអប់រំស្តីអំពីការប្រមូលយកព័ត៌មានទាក់ទងនឹងទីកន្លែង និងចំនួនអ្នកស្លាប់នៅក្នុងខេត្តពោធិ៍សាត់ ដើម្បីចងក្រងសម្រាប់ធ្វើការអប់រំ ។ ក្រោយមកមានការចងក្រងចេញជាសៀវភៅមួយដែលនិយាយអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដោយស្ថាប័នអប់រំ ហើយសាក្សីជាបុគ្គលមួយរូបក្នុងចំណោម៥រូប ដែលបានចងក្រងសៀវភៅនោះ ។ សាក្សីថែមទាំងបានបញ្ជាក់ថា សាក្សីស្គាល់ភូមិសាស្ត្រខេត្តពោធិ៍សាត់យ៉ាងច្បាស់ ដោយសារសាក្សីបានរស់នៅទីនោះចាប់តាំងពីកុមារមកម្ល៉េះ ។ ក្រៅពីការកិច្ចជាគ្រូបង្រៀន សាក្សីធ្លាប់ទៅធ្វើកម្មសិក្សាផ្នែកវប្បធម៌ រយៈពេលមួយខែនៅសហភាពសូវៀត ។

តំណាងសហព្រះរាជអាជ្ញាបានលើកយកចម្លើយរបស់សាក្សីទាក់ទងនឹងអាយុ និងការងារដែលសាក្សី បានធ្វើកាលពីឆ្នាំ១៩៧០ ។ សាក្សីបានបញ្ជាក់ថា នៅឆ្នាំ១៩៧០ ខ្លួនមានអាយុ២០ឆ្នាំ ហើយបានចូលធ្វើទាហានផ្នែកសឹករងខេត្តពោធិ៍សាត់ និងត្រូវជ្រើសតាំងជា "អេតា ម៉ាហ្ស័រ" ជាអគ្គសេនាធិការនៅសាលាខេត្ត ។ នៅឆ្នាំ១៩៧៣ ប្រជាជននៅស្រុកលាច (បច្ចុប្បន្នស្រុកភ្នំក្រវាញ) ទាំងអស់ត្រូវបានជម្លៀសមកនៅខេត្តពោធិ៍សាត់ក្រោមបញ្ជាពីថ្នាក់លើរបស់ទាហាន លន់ នល់ ។ ក្នុងអំឡុងពេលនោះ មានការដកទ័ពជាបន្ត បន្ទាប់ពីស្រុកភ្នំក្រវាញ ពីបំណក់ក្នុងស្រុកក្រគររហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដោយសារតែមានការប្រយុទ្ធគ្នាគ្រប់សមរភូមិទាំងអស់ ។ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ បានបន្តសួរទាក់ទងនឹងការអំពាវនាវរបស់លោក ម៉ី ស៊ីចន ជាឧត្តមសេនីយ៍ត្រីនៅអគ្គសេនាធិការភ្នំពេញអំពីការទម្លាក់អាវុធចុះចាញ់សង្គ្រាម ។ សាក្សីបានបញ្ជាក់ថា នៅពេលនោះ លោក ម៉ី ស៊ីចន បានប្រកាសតាមវិទ្យុថា "យើង

តំណាងឲ្យអគ្គសេនាធិការភ្នំពេញ ម៉ី ស៊ីចន សូមជម្រាបអំពីកង យុទ្ធពលខេមរៈជាតិទាំងអស់ចង់បាច់អាវុធ លើកទង់ជ័យស ចុះ ចូល និងរកសន្តិភាព» ដូច្នេះគ្រប់អង្គភាពត្រូវតែគោរពតាម ។ នៅពេលនោះសាក្សីស្ថិតនៅទីតាំងស្វាយដូនកែវ មានចម្ងាយ ប្រហែល៣០គីឡូម៉ែត្រពីទីរួមខេត្ត ។ បន្ទាប់ពីមានការប្រកាសរួច មកទាហាន លន់ នល់ បានដាក់អាវុធចុះនៅពេលល្ងាចដោយ ពុំ មានការច្បាំងគ្នាទៀតទេ ហើយទាំងទាហាន លន់ នល់ និងយោធា ខ្មែរក្រហមបានរាំរែកជាមួយគ្នាយ៉ាងសប្បាយ ។ ប៉ុន្តែនៅពេល ព្រឹកខណៈពេលដែលទាហាន លន់ នល់ កំពុងតែកាន់ទង់ជ័យស ដើរនៅតាមផ្លូវពីស្វាយដូនកែវ ដើម្បីទៅប្រជុំនៅក្នុងស្រុកបាកាន ដែលស្ថិតនៅចម្ងាយប្រហែល២០គីឡូម៉ែត្រពីទីរួមខេត្តពោធិ៍ សាត់ យោធាខ្មែរក្រហមបានបាញ់កាំភ្លើងទៅលើទាហានដែល កំពុងតែដើរនោះ ។ ការប្រជុំនៅស្រុកបាកាន គឺខ្មែរក្រហមបាន ប្រកាសឲ្យជម្លៀសប្រជាជនចេញពីខេត្តពោធិ៍សាត់ទៅតាមទីជន បទ ដោយសារខ្លាចមានការទម្លាក់គ្រាប់បែកពីសហរដ្ឋអាមេរិក ។ ប្រហែល នៅថ្ងៃទី២៥ ខែមករា សាក្សីបានធ្វើដំណើរមកទីរួមខេត្ត ដើម្បីចូលរួមប្រជុំម្តងទៀត ប៉ុន្តែពេលនោះ ប្រជាជននៅក្នុងខេត្ត ត្រូវបានជម្លៀសស្ទើរតែទាំងអស់ ប៉ុន្តែមិនដឹងទៅទីណាទេ ។ នៅ ពេលនោះ ការធ្វើទំនាក់ទំនងផ្សេងៗខាងរដ្ឋបាល លន់ នល់ នៅតែ ដំណើរការនៅឡើយ ដូច្នេះទាហានទាំងអស់នៅតែចាំទទួលបញ្ជា ពីថ្នាក់លើដដែល និងបានទៅប្រជុំនៅសាលាខេត្តដែលមានចំនួន ប្រហែលពីររយនាក់ក្នុងចំណោមអ្នកចូលរួមទាំងអស់ ។ ពេលមក ដល់សាលាខេត្ត សាក្សីបានឃើញអ្នកដែលចូលរួមប្រជុំនោះ មាន ឧត្តមសេនីយ៍ ព្រំ លីហួន ជាចៅហ្វាយខេត្ត និងមន្ត្រី ទាហាន គ្រូបង្រៀន និងកូនសិស្សទាំងអស់ ប្រហែលប្រាំរយនាក់ ដែល បានចូលរួមនោះ ។ ចំណែកខាងខ្មែរក្រហមវិញមាន តាសុត ជាប្រធានភូមិភាគ និងមានកម្មាភិបាល ប្រហែលប្រាំពីរនាក់ទៀត បានមកចូលរួម ។ ក្រៅពីនោះ មានយោធាខ្មែរក្រហមប្រហែលពី ៥០-៦០នាក់ បានការពារនៅខាងក្រៅបន្ទប់ប្រជុំ ។

សាក្សីបានរៀបរាប់បន្តថា បន្ទាប់ពីមានការកោះប្រជុំហើយ ទាហាន លន់ នល់ ទាំងអស់ត្រូវបានបញ្ជូនឲ្យទៅទទួលអង្គការ ក្នុងគោលបំណងរួបរួមគ្នាកសាងជាតិនៅទួលពោធិ៍ជ្រៃ ដែលស្ថិត នៅក្នុងស្រុក កណ្តៀងចម្ងាយប្រហែល ២០គីឡូម៉ែត្រពីទីរួម ខេត្ត ។ នៅពេលធ្វើដំណើទៅទួលពោធិ៍ជ្រៃនោះ មានទាហាន ជាច្រើននាក់ ដូច្នេះខ្មែរក្រហមបានប្រាប់ឲ្យសាក្សីជិះឡានបន្ទាប់ ប៉ុន្តែឡាននីមួយៗសុទ្ធតែមានមនុស្សច្រើន ប្រហែលពី៥០ទៅ ៦០នាក់ ។ ក្នុងចំណោមទាហានដែលបានទៅចូលរួមប្រជុំនៅ សាលាខេត្តពោធិ៍សាត់នោះ មានទាហានដែលឈរជើងនៅទួល ពោធិ៍ជ្រៃប្រហែល៣០នាក់ដែរ ។ បន្ទាប់មក តំណាងសហព្រះ រាជអាជ្ញាអន្តរជាតិបានបន្តសួរទាក់ទងនឹងពាក្យអង្គការដើម្បីឲ្យ សាក្សីបញ្ជាក់ ។ សាក្សី ស៊ុំ អាឡាត់ បានពន្យល់ថា ជា ធម្មតា មន្ត្រីរាជការនៅក្នុងរបប លន់ នល់ ពុំដែលយល់ទាល់តែសោះអំពី អង្គការ ហើយពាក្យនេះទើបតែបានឮនៅពេលដែលខ្មែរក្រហម ចូលមកប៉ុណ្ណោះ ។ ដូច្នេះ សាក្សីផ្ទាល់ ក៏ដូចជាទាហានទាំងអស់ចង់ ដឹង និងចង់ឃើញអង្គការជាខ្លាំង ទើបទាហានទាំងនោះដណ្តើម និង ប្រតាយគ្នាឡើងឡានបន្ទាប់ពីមានការប្រជុំនោះរួចមក ហើយ លោក លី ហួន ក៏បានឡើងឡានទៅជាមួយទាហានទាំងអស់នោះ ដែរ ។ សាក្សីបានបញ្ជាក់បន្តថា ឡាន ដែលដឹកទាហាននោះ ជា ប្រភេទឡានយោធាធំៗពណ៌ស ដែលអាចផ្ទុកមនុស្សបានច្រើន និងជាអំណោយពីប្រទេសអូស្ត្រាលី ។ ទាក់ទងនឹងការធ្វើដំណើរ ទៅទួលពោធិ៍ជ្រៃ សាក្សីបានរៀបរាប់ថា ខ្លួនបានរង់ចាំឡានដែល មកតាមក្រោយជាបន្តបន្ទាប់រហូតដល់ឡានទី៨ ជាឡានចុងក្រោយ ប៉ុន្តែឡានទាំងនោះពុំបានឈប់ឲ្យខ្លួនជិះទៅជាមួយឡើយ ។ នៅ ពេលនោះដែរ មានទាហានប្រហែលជា៥០នាក់ទៀតដែលនៅ រង់ចាំជាមួយសាក្សី ។ ដូច្នេះ សាក្សី និងទាហាន ៦ទៀតបាននាំគ្នា ត្រឡប់ទៅផ្ទះវិញ ។ ចំពោះជោគវាសនារបស់ទាហាន លន់ នល់ ដែលបានដឹកទៅដល់ទួលពោធិ៍ជ្រៃវិញ សាក្សីបានទទួលដំណឹងថា ទាហានទាំងនោះត្រូវបានយកទៅសម្លាប់ ។ ព័ត៌មាននេះ សាក្សី បានទទួលពីឈ្មោះ ជាត និង ជោរ ជាទាហាន លន់ នល់ ដែលបាន រួចខ្លួនពីការសម្លាប់នោះបីថ្ងៃក្រោយមក ។ ប៉ុន្តែរយៈពេលពីរ សប្តាហ៍ក្រោយមកទៀត អ្នកទាំងពីរនោះត្រូវបានខ្មែរក្រហមតាម ចាប់ខ្លួន និងសម្លាប់ចោល ។ ទាក់ទងនឹងចំនួនទាហាន លន់ នល់ ដែលបានស្លាប់នៅទួលពោធិ៍ជ្រៃ សាក្សីបានបញ្ជាក់ថា ខ្លួនទទួល បានចំនួនតួរលេខពីឈ្មោះ សេង ឈន ជាប្រធានឃុំស្វាយហ្លួង

ស្រុកកណ្ដៀង ដែលបញ្ជាក់ថា មានទាហាន លន់ នល់ ដល់ទៅពីរពាន់នាក់ដែលត្រូវបានសម្លាប់នៅក្នុងរបបខ្មែរក្រហម ។

## ២) ការសួរដេញដោលដោយមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី

សហមេធាវីជាតិ ជេត វ៉ាន់លី បានផ្ដើមសំណួរទាក់ទងនឹងព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងខេត្តពោធិ៍សាត់ ។ សាក្សី ស៊ុំ អាឡាត់ បានរៀបរាប់ថា ខ្មែរក្រហមបានចូលមកកាន់កាប់ខេត្តពោធិ៍សាត់ នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ។ បន្ទាប់ពីបានរំដោះរួចហើយ មានកិច្ចប្រជុំជាច្រើនលើករវាងខ្មែរក្រហម និងទាហាន លន់ នល់ ដែលមានការចូលរួមពីសិស្សសាលា និងមន្ត្រីរដ្ឋការផ្សេងៗក្នុងរយៈពេលប្រហែលមួយសប្ដាហ៍មុនពេលមានការសម្លាប់ទាហាននៅទួលពោធិ៍ជ្រៃ ។ សាក្សីបានបញ្ជាក់ថា ក្នុងចំណោមមន្ត្រីរដ្ឋការ លន់ នល់ ទាំងនោះរួមមានមន្ត្រីធំៗមួយចំនួនដូចជា នាង ឈុំ, ឆោម ឈុំ, ឆុង វ៉ាន់, ហួត វ៉ន, ឈិន តាក់, ម៉ី ស៊ីចួន (ត្រូវជាប្អូនរបស់លោក ម៉ី ស៊ីចន) និងលោក ម៉ែន ដេន ។ ទាក់ទងនឹងឈ្មោះ ប៊ិល និង វុន វិញ សាក្សីបានបញ្ជាក់ថា អ្នកទាំងពីរអាចជាទាហានស័ក្តិ១ ប៉ុន្តែសាក្សីពុំបានទទួលដំណឹងពីជោគវាសនារបស់អ្នកទាំងនោះឡើយ ។ មេធាវីបានបន្តសួរទាក់ទងនឹងព្រឹត្តិការណ៍បោសសម្អាតដើម្បីឲ្យសាក្សីពន្យល់ ។ សាក្សីគ្រាន់តែបានបញ្ជាក់ថា ព្រឹត្តិការណ៍នោះសំដៅទៅលើការចម្រាញ់ប្រជាជនចាស់ និងប្រជាជនថ្មីនៅតាមសហករណ៍នីមួយៗ ។ ទាក់ទងនឹងកិច្ចប្រជុំរៀនសូត្រវិញ សាក្សី ស៊ុំ អាឡាត់ បានបញ្ជាក់ថា ក្រោយព្រឹត្តិការណ៍សម្លាប់នៅទួលពោធិ៍ជ្រៃ មានការប្រជុំបើកវគ្គមួយហៅថា "មន្ទីរតំបន់" នៅស្រុកកណ្ដៀងដែលមានការចូលរួមពីសិស្ស និងគ្រូបង្រៀន ព្រមទាំងមានការចូលរួមពីគណៈតំបន់ឈ្មោះ សុត ។ ក្រៅពីនោះ សាក្សីបានចូលរួមក្នុងការប្រជុំស្វ័យទិតៀន ដែលធ្វើឡើងជាប្រចាំថ្ងៃដែរ ។ នៅឆ្នាំ១៩៧៧ សាក្សីបានឃើញឈ្មោះរបស់ តាសុត នៅគុកទួលស្លែង ។ សំណួរចុងក្រោយ មេធាវីបានផ្ដោតទៅលើការរៀបការរបស់សាក្សីថា តើជាការបង្ខំ ឬយ៉ាងណា ប៉ុន្តែសំណួរត្រូវបានមេធាវីការពារក្ដី វ៉ិចទ័រ កុបប៉េ បដិសេធដោយអះអាងថា សំណួរនេះមិនស្ថិតនៅក្នុងវិសាលភាពនៃសវនាការនេះទេ ។

បន្ទាប់មក សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី អេលីហ្សាប៊ែត ស៊ីម៉ូណូហ្គត បានបន្តសួរទាក់ទងនឹងទីកន្លែងដែលសាក្សីរស់នៅក្រោយពេលមានការសម្លាប់ទាហាន លន់ នល់ ។ សាក្សីបានរៀបរាប់ថា នៅពេលនោះ សាក្សីបានទៅធ្វើការនៅក្នុងកងចល័ត ជីកទំនប់ និងលើកប្រឡាយ ។ នៅកន្លែង ដែលសាក្សីរស់នៅនោះ មានប្រជាជន១៧មេសាជាច្រើននាក់ ដែលត្រូវបានជម្លៀសពីភ្នំពេញនៅឆ្នាំ១៩៧៦ ដល់១៩៧៧ ។ នៅពេលនោះ ប្រជាជន១៧មេសាបានរស់នៅដោយមានការលំបាក ហើយគ្រួសារខ្លះស្លាប់ទាំងពូជដោយសារជំងឺ និងអត់អាហារជាដើម ។ សាក្សីបានបញ្ជាក់ថា នៅក្នុងរបបខ្មែរក្រហម សាក្សីបានរស់នៅទាំងមានការភ័យខ្លាច និងគិតថា ខ្លួនបានស្លាប់បាត់ទៅហើយ ។ ហេតុការណ៍ដែលធ្វើឲ្យសាក្សីមានការរន្ធត់ជាលើកទីពីរនោះ គឺការសម្លាប់មនុស្សនៅឃុំរំលេចនៅឆ្នាំ១៩៧៩ ពេលដែលមានការចូលមកដល់នៃកងទ័ពវៀតណាម ដោយសារខ្មែរក្រហមបានសម្លាប់ប្រជាជនស្លូតត្រង់ជាច្រើនាក់ ។ ម្យ៉ាងទៀតរបាយការណ៍នេះ សាក្សីបានទទួលពីមេឃុំរំលេចឈ្មោះ ឌួង សូ ។

## ៣) ការសួរដេញដោលដោយមេធាវីការពារក្ដីទាំងពីរក្រុម

### ក) ក្រុមមេធាវីការពារក្ដី នួន ជា

មេធាវីជាតិ សុន អរុណ បានចាប់ផ្ដើមដោយសួរដេញដោលពីអាយុរបស់សាក្សីក្នុងពេលចូលរួមធ្វើជាទាហាននៅក្នុងរបប លន់ នល់ ។ សាក្សីបានបញ្ជាក់ថា នៅពេលនោះខ្លួនអាយុ ១៩ឆ្នាំ និងមានតួនាទីជាបុគ្គលិកនៅការិយាល័យផ្នែកប្រតិបត្តការណ៍សឹករបស់អគ្គសេនាធិការផ្នែកសឹករងខេត្តពោធិ៍សាត់ ។ សាក្សីបានបញ្ជាក់ថា ក្នុងតួនាទីនេះ សាក្សីបានចុះទៅសមរភូមិផ្ទាល់នៅស្រុកភ្នំក្រវាញដើម្បីរំដោះប្រជាជននៅទីនោះ ។ ក្រៅពីនោះ សាក្សីបានបន្តថា ខ្លួនក៏មានតួនាទីជាអ្នករៀបចំកាំភ្លើងបាញ់ក្រោយពេលមានការហាត់រៀនអស់រយៈពេលបីខែនៅមណ្ឌលផ្នែកសឹករងថ្មើរជើងដែលមានទីតាំងនៅកំបូល ។ ទាក់ទងនឹងការអំពាវនាវរបស់ឧត្តមសេនីយ៍ ម៉ី ស៊ីចន ដែលបានផ្សព្វផ្សាយអំពីការបញ្ចប់សង្គ្រាមនោះ សាក្សីបានបញ្ជាក់ជាថ្មីថា សាក្សីពិតជាបានឮការផ្សព្វផ្សាយនោះដោយផ្ទាល់ខណៈពេលដែលខ្លួនស្ថិតនៅក្នុងសមរភូមិស្វាយដូនកែវ ។ អំពីការស្លាប់របស់ តាសុត នៅ

ទួលស្លែងវិញ សាក្សីបានបញ្ជាក់ថា នៅឆ្នាំ១៩៧៧ សាក្សីបានមករៀនសូត្រផ្នែកគ្រូបង្រៀននៅភ្នំពេញ ហើយបានមកធ្វើទស្សនៈកិច្ចនៅទួលស្លែង ទើបបានឃើញឈ្មោះ កែ គឹមហួត ហៅ សុត នៅទីនោះដោយបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់ទៀតផង ។

បន្ទាប់មក សហមេធាវីអន្តរជាតិ វ៉ិចទ័រ កុបប៉េ បានបន្តសំណួរទាក់ទងនឹងការប្រជុំទាំងពីរលើកនៅសាលាខេត្តពោធិ៍សាត់ ។ សាក្សីបានបញ្ជាក់ថា នៅពេលនោះទាហាន លន់ នល់ ពុំទាន់ចាកចេញទៅណានៅឡើយទេ ហើយទាហានទាំងនោះមានស្លៀកឯកសណ្ឋានរបស់ទ័ពខ្លះ និងស៊ីវិលខ្លះ ។ ចំពោះអនុសេនីយត្រី ឈ្មោះ ប៊ុល និង រុន វិញ សាក្សី ពុំបានដឹងអំពីតួនាទីរបស់អ្នកទាំងពីរនៅមុនឆ្នាំ១៩៧៥នោះទេ ។ ចំណែកការបែកចែកតួនាទីរបស់រដ្ឋការ លន់ នល់ វិញក៏មិនមានភាពច្បាស់លាស់ដែរ ក្រោយពេលមានការមកដល់នៃយោធាខ្មែរក្រហមភ្លាមៗនោះ ។ មេធាវីការពារក្តីបានបង្ហាញរូបថតនៃអគារជាសណ្ឋាគារដែលអភិបាលខេត្តពោធិ៍សាត់ស្នាក់នៅ ដើម្បីឲ្យសាក្សីពន្យល់លម្អិតអំពីអគារសាលាខេត្តដែលជាកន្លែងប្រជុំនៅក្បែរសណ្ឋាគារនោះ ។ ប៉ុន្តែ ការសួររបស់មេធាវីបានយោងទៅលើសក្ខីកម្មរបស់សាក្សីពីមុន ដែលនាំឲ្យមានការជំទាស់ពីសំណាក់សហព្រះរាជអាជ្ញា និងអង្គជំនុំជម្រះ ។

បន្ទាប់មក មេធាវី វ៉ិចទ័រ កុបប៉េ បានបន្តសួរទាក់ទងនឹងចំនួនទាហាន លន់ នល់ ដែលបានមកចូលរួមប្រជុំលើកទី១នៅស្រុកបាកាន និងលើកទី២នៅសាលាខេត្តពោធិ៍សាត់ ព្រមទាំងស្នើឲ្យសាក្សីបញ្ជាក់អំពីឈ្មោះបុគ្គលមួយចំនួនដែលបានចូលរួមប្រជុំ ។ ក្រៅពីនោះ មេធាវីបានសួរសំណួរមួយចំនួនទាក់ទងនឹង ចំនួនទាហាន និងអ្នករដ្ឋការ លន់ នល់ ដែលត្រូវបានដឹកយកទៅសម្លាប់នៅទួលពោធិ៍ជ្រៃ ប៉ុន្តែសំណួរទាំងនោះមានការបញ្ជាក់ជាច្រើនដងពីមេធាវី ដែលហាក់ធ្វើឲ្យសាក្សីមានការយល់ច្រឡំ និងមិនចង់សហការណ៍ក្នុងការឆ្លើយតប ។ ទោះជាយ៉ាងណា សាក្សីនៅតែព្យាយាមឆ្លើយគ្រប់សំណួររបស់មេធាវីការពារក្តី ។ សាក្សីបានបញ្ជាក់ជាថ្មីអំពីស្ថានភាពដឹកជញ្ជូនទាហាន លន់ នល់ ទៅកាន់មន្ទីរទួលពោធិ៍ជ្រៃ ដោយរៀបរាប់ថា ខ្លួនបានរត់ចាំឡើងឡានទៅជាមួយទាហានផ្សេងទៀត ប៉ុន្តែមិនអាចទៅបានដោយសារមានមនុស្សច្រើនចង្អៀត នៅក្នុងឡានទីមួយៗ ។

### ៣) ក្រុមមេធាវីការពារក្តី ខៀវ សំផន

បន្ទាប់បញ្ចប់ការសួរដោយក្រុមមេធាវីការពារក្តី នួន ជា មេធាវីអន្តរជាតិ អាកទួរ វ៉ែកកែន បានបន្តសំណួរទាក់ទងនឹងការប្រជុំលើកទី១ បន្ទាប់ពីខ្មែរក្រហមបានចូលមកដល់ខេត្តពោធិ៍សាត់ ។ ករណីនេះ សាក្សីបានរៀបរាប់ថា កិច្ចប្រជុំលើកទី១ ធ្វើឡើងនៅស្រុកបាកាន ហើយទាហានទាំងអស់ស្ថិតក្នុងឯកសណ្ឋានជាទាហាននៅឡើយ ។ ប៉ុន្តែ នៅពេលទៅដល់កន្លែងប្រជុំ ខ្លួនពុំបាននៅចូលរួមដល់ចប់កិច្ចប្រជុំនោះទេដោយបានគេចចេញដើម្បីទៅជួបជុំគ្រួសារនៅភូមិស្វាយហ្លួង ឃុំបាក់នឹម ស្រុកបាកាន ខេត្តពោធិ៍សាត់ ។ នៅពេលធ្វើដំណើរនោះ សាក្សីបានដោះឯកសណ្ឋានទាហានចោលទៅក្នុងស្ទឹងដើម្បីកុំឲ្យខ្មែរក្រហមចាប់ខ្លួន ឬសម្លាប់ ។

ទាក់ទងនឹងការស្រាវជ្រាវអំពីឧក្រិដ្ឋកម្មនៅទួលពោធិ៍ជ្រៃវិញ សាក្សីបានរៀបរាប់ថា ក្រោយឆ្នាំ១៩៧៩ សាក្សីធ្វើជាគ្រូបង្រៀន ហើយបានទៅរៀននៅភ្នំពេញទាក់ទងនឹងការប្រមូលឯកសារនៃរបបខ្មែរក្រហមប្រចាំខេត្តនីមួយៗ ។ ដូច្នេះ សាក្សីបានក្លាយជាសមាជិកម្នាក់ក្នុងចំណោម៩នាក់ដើម្បីធ្វើជាសាក្សីសម្រាប់ការសម្លាប់នៅខេត្តពោធិ៍សាត់ ។ មេធាវីបានបន្តសួរទាក់ទងនឹងការបំផ្លាញភស្តុតាងដែលមានការបញ្ជាពីរដ្ឋាភិបាល ។ ទាក់ទងនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា នៅឆ្នាំ១៩៧៩ រដ្ឋាភិបាលបានឯកភាពឲ្យមានការបំផ្លាញរាល់ភស្តុតាងទាំងអស់ដែលទាក់ទងនឹងការសម្លាប់នៅក្នុងរបបខ្មែរក្រហម ដែលសំដៅទៅលើការបំផ្លាញអដ្ឋិធាតុនៅក្នុងស្តូបដែលនៅតាមភូមិឃុំជាដើម ។ មូលហេតុនៃការបំផ្លាញនេះ គឺដោយសារតែភស្តុតាងទាំងនោះបានបន្សល់ទុកនូវការឈឺចាប់សម្រាប់ប្រជាជនខ្មែរ ។ មុនពេលបញ្ចប់ការសួរដេញដោលមេធាវីមានសំណួរជាច្រើនទៀតដើម្បីសួរសាក្សី ប៉ុន្តែអង្គជំនុំជម្រះបានបង្អាក់ដោយសារមេធាវីបានចំណាយពេលវេលាច្រើនលើសពីការកំណត់ក្នុងការសួរដេញដោលសាក្សី ដូច្នេះសវនាការស្តាប់សក្ខីកម្មសាក្សី ស៊ុំ អាឡាត់ ត្រូវបានបញ្ចប់ ។

# អង្គជំនុំជម្រះសាលាដំបូងព្រមានអាកប្បកិរិយាក្រអើតក្រទម របស់មេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ ខៀវ សំផន

ចាន់ ប្រាថ្នា

នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចេញសេចក្តីព្រមានដល់លោក អាកទូ វែកកែន ជាសហមេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ ខៀវ សំផន។ សេចក្តីព្រមាននេះធ្វើឡើងបន្ទាប់ពីមេធាវី អាកទូ វែកកែន បានស្រែកទាំងកំហឹង នៅចំពោះមុខអង្គជំនុំជម្រះក្នុងអំឡុងពេលសវនាការស្តាប់សក្ខីកម្មសាក្សី ស៊ុំ អាឡាត់ នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៣ ។ បន្ថែមលើនេះទៀត បន្ទាប់ពីអង្គជំនុំជម្រះប្រកាសបិទសវនាការ និងធ្វើដំណើរចាកចេញពីបន្ទប់សវនាការ មេធាវី អាកទូ វែកកែន នៅតែបន្តអង្គុយដោយពុំព្រមក្រោកឈរនៅខណៈពេលដែលភាគីផ្សេងៗទៀត និងសារធារណជនទូទៅនៅក្នុងបន្ទប់នោះឡើងក្រោកឈរទាំងអស់គ្នា ។ គួរបញ្ជាក់ថា តាមការអនុវត្តកន្លងមករាល់ពេលចៅក្រមនៃអង្គជំនុំជម្រះធ្វើដំណើរចូល និងចេញពីបន្ទប់សវនាការ គ្រប់បុគ្គលទាំងអស់នៅក្នុងបន្ទប់សវនាការ (លើកលែងតែព្រះសង្ឃ) ត្រូវ ក្រោកឈរ ។ ការអនុវត្តនេះគឺអនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់តុលាការដែលចែងថា សាធារណជន និងភាគីទាំងអស់ ត្រូវក្រោកឈរនៅពេលដែលក្រឡាបញ្ជីបញ្ជាក់ថា «ក្រោកឈរ» ។[១]

តាមរយៈសកម្មភាពទាំងនេះ អង្គជំនុំជម្រះធ្វើការកត់សម្គាល់ជាសាធារណៈថា មេធាវី អាកទូ វែកកែន មានអាកប្បកិរិយាក្រអើតក្រទម និងមានចរិតរំខានដល់កិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះមុខភាគីផ្សេងៗទៀតដែលជាសហសេវិករួមវិជ្ជាជីវៈជាមួយគ្នា សាក្សី និងសាធារណជន ។ វិធាន២២(៤) នៃវិធានផ្ទៃក្នុងចែងថា «នៅក្នុងការបំពេញការងាររបស់ខ្លួន មេធាវីត្រូវគោរពតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុងសេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលរបស់អង្គជំនុំជម្រះវិសាមញ្ញ ក៏ដូចជាច្បាប់ស្តីពីលក្ខន្តិកៈមេធាវីរបស់កម្ពុជា និងបទដ្ឋាន និងក្រមសីលធម៌វិជ្ជាជីវៈដែលបានទទួលស្គាល់ ។ ពួកគេមានកាតព្វកិច្ចក្នុងការលើកកម្ពស់យុត្តិធម៌ និងដំណើរការនីតិវិធីប្រកបដោយប្រសិទ្ធិភាព និងត្រឹមត្រូវ» ។[២]

អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់បន្ថែមថា អាកប្បកិរិយារបស់មេធាវី អាកទូ វែកកែន គឺធ្លាក់ចុះក្រោមបទដ្ឋានគំរូនៃការគោរពវិជ្ជាជីវៈដែលមេធាវីនានាត្រូវប្រកាន់យកនៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ឬតុលាការផ្សេងៗទៀត ។ ជាងនេះទៅទៀត អាកប្បកិរិយាបែបនេះ គឺជាឧទាហរណ៍មិនល្អមួយសម្រាប់បណ្តាមេធាវីជំនាន់ក្រោយផ្សេងៗទៀត ។ ទោះបីមានការកត់សម្គាល់ ដូច្នេះក្តីអង្គជំនុំជម្រះពុំបានសម្រេចចាត់វិធានការណាមួយប្រឆាំងនឹងមេធាវី អាកទូ វែកកែន ឡើយ គឺគ្រាន់តែចេញសេចក្តីព្រមានអនុលោមតាមវិធាន ៣៧(១) តែប៉ុណ្ណោះ ។ ប៉ុន្តែក្នុងករណីមេធាវីរូបនេះនៅតែបន្តអនុវត្តដូច្នេះនោះអាចប្រឈមនឹងការបណ្តេញចេញពីបន្ទប់សវនាការជាដើម ។ វិធាន ៣៧(១) នៃវិធានផ្ទៃក្នុងចែងថា «នៅពេលណាដែលអង្គជំនុំជម្រះយល់ឃើញថា ជនណាម្នាក់អុកឡុករំខានដល់កិច្ចដំណើរការនីតិវិធីអង្គជំនុំជម្រះជាដំបូងត្រូវចេញសេចក្តីព្រមានមួយ ។ ក្នុងករណីមានការបន្តរំខានទៀត អង្គជំនុំជម្រះអាចបង្គាប់ឲ្យជនដែលរំខាននោះចាកចេញ ឬបណ្តេញចេញពីបន្ទប់សវនាការ ឬអគាររបស់អង្គជំនុំជម្រះវិសាមញ្ញ ហើយក្នុងករណីនៅតែប្រព្រឹត្តកំហុសឆ្គងទៀត អាចបង្គាប់មិនឲ្យជននោះចូលរួមក្នុងកិច្ចដំណើរការនីតិវិធីទាំងអស់» ។

## កំណត់សម្គាល់

១ បទបញ្ជាផ្ទៃក្នុងគ្រប់គ្រងសាលសវនាការក្នុងថ្ងៃសវនាការ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១១ ។

២ វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះក្នុងតុលាការកម្ពុជា (វិសោធនកម្មលើកទី៨) ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១១ ។

# ខៀវ សំផន នឹងនៅតែបន្តជាប់ឃុំ ទោះបីរកពុំឃើញពិរុទ្ធភាពក្នុងសំណុំរឿង០០២/០១

**លឹម ជ័យទ័ត្ត**

ខៀវ សំផន គឺជាជនជាប់ចោទមួយរូបក្នុងចំណោមជនជាប់ចោទបួនរូបក្នុងសំណុំរឿង០០២ ដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ។ បទចោទប្រកាន់ទាំងអស់នេះ សុទ្ធសឹងជាបទឧក្រិដ្ឋធ្ងន់ធ្ងរនៅក្នុងរឿងក្តីព្រហ្មទណ្ឌអន្តរជាតិ ។

នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ខៀវ សំផន ត្រូវបានចាប់ខ្លួន និងបញ្ជូនមកឃុំខ្លួនបណ្តោះអាសន្ននៅមន្ទីរឃុំឃាំងរបស់សាលាក្តីខ្មែរក្រហមសម្រាប់រយៈពេល១ឆ្នាំ តាមអំណាចនៃដីកាឃុំខ្លួនបណ្តោះអាសន្នដែលចេញដោយសហចៅក្រមស៊ើបអង្កេត ។ នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចពន្យារពេលឃុំខ្លួន ខៀវ សំផន ជាបណ្តោះអាសន្ន សម្រាប់រយៈពេល១ឆ្នាំទៀត ដើម្បីបន្តធ្វើការស៊ើបអង្កេត ។ នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ដោយសារតែការស៊ើបអង្កេតនៅពុំទាន់បានបញ្ចប់ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចពន្យារពេលឃុំខ្លួនជាលើកទី២ សម្រាប់រយៈពេល១ឆ្នាំបន្តទៀត ។ ដូច្នេះ ការឃុំខ្លួនជនជាប់ចោទ ខៀវ សំផន នៅក្នុងដំណាក់កាលស៊ើបអង្កេតមានរយៈពេល៣ឆ្នាំ ។

នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយក្នុងសំណុំរឿង០០២ ដោយធ្វើការបង្គាប់ថា ជនជាប់ចោទត្រូវរក្សាទុកក្នុងមន្ទីរឃុំឃាំងជាបណ្តោះអាសន្នរហូតដល់ពេលនាំខ្លួនទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[១] ។ ដូច្នេះ ខៀវ សំផន ត្រូវបន្តស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្នក្នុងមន្ទីរឃុំឃាំងរហូតដល់មានការជំនុំជម្រះក្តីដោយអង្គជំនុំជម្រះសាលាដំបូង ។

ក្នុងដំណាក់កាលនៃការជំនុំជម្រះលើអង្គសេចក្តី អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យបន្តឃុំខ្លួន ជនជាប់ចោទ ខៀវ សំផន ដោយអនុលោមតាមវិធាន៨២(១) នៃវិធានផ្ទៃក្នុង ដែលចែងថា ៖ «នៅក្នុងករណីដែលជនជាប់ចោទត្រូវបានឃុំខ្លួន នៅពេលចូលខ្លួនលើកដំបូងនៅចំពោះមុខអង្គជំនុំជម្រះសាលា ដំបូង ជនជាប់ចោទត្រូវស្ថិតនៅក្នុងឃុំដដែលរហូតដល់ពេលសាលក្រមនៃអង្គជំនុំជម្រះសាលាដំបូង ត្រូវបានសម្រេចសេចក្តី» ។ ទោះបីជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងនៅតែមានឆន្ទានុសិទ្ធិក្នុងការបង្គាប់ឲ្យដោះលែងជនជាប់ចោទ ខៀវ សំផន ឬដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ តាមការស្នើសុំរបស់ជនជាប់ចោទ ឬមេធាវីរបស់ជនជាប់ចោទ នៅក្នុងករណីចាំបាច់ ។

មុនពេលនៃការចាប់ផ្តើមសវនាការលើអង្គសេចក្តី អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចមួយ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១[២] ដោយធ្វើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ ឲ្យទៅជាផ្នែកតូចៗ ដែលអនុញ្ញាតឲ្យអង្គជំនុំជម្រះអាចជ្រើសរើសយកអង្គហេតុ ឬបទចោទប្រកាន់ត្រង់ផ្នែកណាមួយក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីយកមកបើកសវនាការ ។ ផ្នែកដំបូងដែល អង្គជំនុំជម្រះលើកយកមកបើកសវនាការនោះត្រូវបានកំណត់ថាជាសំណុំរឿង០០២/០១ ។ នៅក្នុងសំណុំរឿង០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានលើកយក បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មកធ្វើការវិនិច្ឆ័យ ។ រីឯបទចោទប្រកាន់ផ្សេងទៀតដែលទាក់ទងនឹងបទប្រល័យពូជសាសន៍ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ត្រូវបានទុកមួយអន្លើរសម្រាប់ដំណាក់កាលបន្ទាប់នៃកិច្ចដំណើរការនីតិវិធី ។

ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការក្នុងសំណុំរឿង០០២/០១ ខៀវ សំផន បានបដិសេធរាល់ការចោទប្រកាន់ទាំងអស់ និងថា ពុំបានដឹងអំពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើង

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ ហើយនៅក្នុងរបបនោះ ខ្លួនក៏ពុំមានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចអ្វីទាំងអស់ ។[៣]

ប្រសិនបើ នៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿង០០២/០១ ដែលគ្រោងនឹងចេញនៅក្នុងត្រីមាសទី១ ឆ្នាំ២០១៤[៤] រកឃើញថា ខៀវ សំផន ពិតជាមានពិរុទ្ធភាព អង្គជំនុំជម្រះនឹងផ្តន្ទាទោស ខៀវ សំផន នៅក្នុងកម្រិតណាមួយ ដែលស្របទៅនឹងកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងវិធានផ្ទៃក្នុង ។[៥] ផ្ទុយទៅវិញ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ថាអំពើដែលកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនមានភស្តុតាងបង្ហាញពិតប្រាកដ ឬយល់ឃើញថា ខៀវ សំផន មិនមានពិរុទ្ធភាពក្នុងអំពីទាំងនោះទេ ខៀវ សំផន នឹងរួចផុតពីបទចោទ ។[៦]

ទោះបីជា ផ្អែកតាមការបង្ហាញពីខាងលើ ខៀវ សំផន ត្រូវបានរកឃើញថា មានពិរុទ្ធភាព ឬពុំមានពិរុទ្ធភាព សម្រាប់សំណុំរឿង០០២/០១ ក៏ដោយ ខៀវ សំផន នឹងនៅតែបន្តស្ថិតនៅក្នុងមន្ទីរឃុំឃាំងដដែល ។

មានហេតុផលពីរយ៉ាង ដែល ខៀវ សំផន មិនអាចត្រូវបានដោះលែង ។ ហេតុផលទី១ គឺករណី ដែលសហព្រះរាជអាជ្ញាបន្តប្តឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល ។ ហេតុផលទី២ គឺដោយសារ ខៀវ សំផន នៅពុំទាន់រួចផុតពីការចោទប្រកាន់ផ្សេងៗទៀតនៅឡើយ ។

សម្រាប់ហេតុផលទី១ តាមផ្លូវច្បាប់ សហព្រះរាជអាជ្ញានឹងប្តឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល ក្នុងករណីដែលជនជាប់ចោទ ខៀវ សំផន ត្រូវបានអង្គជំនុំជម្រះសាលាដំបូងសម្រេចថា មិនមានទោស ។ ក្នុងករណីនេះ ខៀវ សំផន នឹងត្រូវបន្តស្ថិតនៅក្នុងមន្ទីរឃុំឃាំងរង់ចាំសេចក្តីសម្រេច លើបណ្តឹងសាទុក្ខរបស់អង្គជំនុំជម្រះតុលាការកំពូល ។ យោងតាមការវាយតម្លៃរបស់អង្គជំនុំជម្រះ សាលាដំបូង សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១ របស់អង្គជំនុំជម្រះតុលាការកំពូល អាចនឹងចេញក្នុងនៅចុងឆ្នាំ២០១៥[៧] ។ អនុលោមតាមវិធាន១១១(៤) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងករណីដែលអង្គជំនុំជម្រះតុលាការកំពូលសម្រេចឲ្យរួចផុតពីបទចោទនោះ ខៀវ សំផន នឹងត្រូវបានដោះលែងឲ្យមានសេរីភាពភ្លាម[៨] ។ ប៉ុន្តែ វិធាននេះ ក៏បានចែងបន្ថែមដែរថា ជនជាប់ចោទអាចនឹងត្រូវបន្តស្ថិតនៅក្នុងឃុំក្នុងករណីដែលជននោះត្រូវបានឃុំខ្លួនពីបទល្មើសផ្សេងទៀត ។ ឃ្លាចុងក្រោយនេះហើយ ជាហេតុផលទី២ ដែល ខៀវ សំផន មិនអាចត្រូវបានដោះលែង ទោះបីជារកពុំឃើញមានពិរុទ្ធភាពក្នុងសំណុំរឿង០០២/០១ ដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក៏ដោយ ។ ដូចបានបញ្ជាក់ពីខាងលើ ខៀវ សំផន ត្រូវបានចោទប្រកាន់លើបទឧក្រិដ្ឋកម្មអន្តរជាតិចំនួនបី គឺបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ។ ដោយសារការបំបែកសំណុំរឿង០០២ ទៅជាផ្នែកតូចៗ ហើយជ្រើសរើសយកតែបទចោទប្រកាន់មួយមកធ្វើការជំនុំជម្រះ ដូច្នេះ ខៀវ សំផន នៅពុំទាន់រួចផុតពីបទចោទប្រកាន់ពីរផ្សេងទៀត ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតនៅឡើយទេ ។ បើយោងតាមវិធាន១១១(៤) ខៀវ សំផន ទំនងជានឹងត្រូវបន្តដាក់ឲ្យស្ថិតនៅក្នុងមន្ទីរឃុំឃាំងរង់ចាំការកាត់សេចក្តីលើបទចោទប្រកាន់ផ្សេងទៀត ដែលនៅសេសសល់សម្រាប់ដំណាក់កាលបន្ទាប់ក្នុងសំណុំរឿង០០២/០២ ឬសំណុំរឿង ០០២/០៣ ។

បើពិនិត្យមើលលើរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នលើរូប ខៀវ សំផន ចាប់តាំងពីឆ្នាំ២០០៧ រហូតដល់បច្ចុប្បន្ន គឺមានរយៈពេលប្រមាណ៥ឆ្នាំ និង៧ខែ ហើយការឃុំខ្លួននេះអាចនឹងបន្តរហូតដល់សំណុំរឿង០០២ទាំងមូលត្រូវបានបញ្ចប់ ។ ខៀវ សំផន មានសិទ្ធិក្នុងការស្នើសុំអង្គជំនុំជម្រះឲ្យដោះលែងខ្លួនដោយដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ហើយ ខៀវ សំផន ក៏ធ្លាប់បានប្រើប្រាស់សិទ្ធិនេះរួចហើយដែរ[៩] ។ ក្នុងអំឡុងពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ខៀវ សំផន ធ្លាប់បានដាក់សំណើសុំឲ្យមានការដោះលែងខ្លួនចំនួន៥ដងរួចមកហើយ ប៉ុន្តែសំណើទាំងនោះ គឺត្រូវបានបដិសេធទាំងអស់ ។ មូលហេតុដែលនាំឲ្យអង្គជំនុំជម្រះបដិសេធចំពោះការស្នើសុំដោះលែងរបស់ ខៀវ សំផន គឺការព្រួយបារម្ភចំពោះការរត់គេចខ្លួនរបស់

ខៀវ សំផន[10] ។

ហេតុដូច្នេះ ខៀវ សំផន ទំនងជានឹងត្រូវស្ថិតនៅក្នុងមន្ទីរឃុំឃាំងរហូតដល់ពេលមានសាលក្រម ឬសាលដីកាសម្រេចអំពីពិរុទ្ធភាពរបស់ខ្លួនក្នុងសំណុំរឿង០០២/០១ និងរង់ចាំការជំនុំជម្រះបទចោទប្រកាន់ផ្សេងៗទៀតដែលនៅសេសសល់ ។ បើពិនិត្យមើលទៅលើវ័យរបស់ ខៀវ សំផន នាពេលបច្ចុប្បន្ន ដែលមានអាយុ៨២ឆ្នាំ ប្រៀបធៀបនឹងរយៈពេលដែលអង្គជំនុំជម្រះត្រូវចំណាយដើម្បីសម្រេចនិងសម្រេចឲ្យបាននូវសាលដីកាស្ថាពរក្នុងសំណុំរឿង០០២/០១ទាំងមូល រួមជាមួយនឹងសំណុំរឿង០០២/០២ ឬសំណុំរឿង០០២/០៣ (ប្រសិនជាកើតមាន) ឃើញថា លទ្ធភាពដើម្បីនៅក្រៅឃុំរបស់ ខៀវ សំផន ស្ទើរតែពុំអាចកើតមាន ។

ទោះបីជាយ៉ាងណាក្តី ការបន្តឃុំខ្លួនជនជាប់ចោទក្នុងមន្ទីរឃុំឃាំងក្នុងរយៈពេលយូរ ដោយពុំមានការកំណត់ច្បាស់លាស់អំពីកាលបរិច្ឆេទនៃគម្រោងចេញសេចក្តីសម្រេចស្ថាពរ ពុំមែនជាជម្រើសល្អ សម្រាប់អង្គជំនុំជម្រះឡើយ ព្រោះអាចនឹងធ្វើឲ្យប៉ះពាល់ដល់គោលការណ៍នៃការជំនុំជម្រះក្តីក្នុងថិរវេលាមួយសមស្រប ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងគប្បីត្រូវបង្កើតផែនការទាក់ទងនឹងសំណុំរឿងដែលនៅសេសសល់ឲ្យបានច្បាស់លាស់តាមសំណើរបស់អង្គជំនុំជម្រះតុលាការកំពូលដើម្បីជៀសវាងការតវ៉ាពីសំណាក់មេធាវីការពារក្តីរបស់ជនជាប់ចោទ ។

## កំណត់សម្គាល់

[1] ដីកាដំណោះស្រាយ, ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០, ឯកសារ D៤២៧, កថាខណ្ឌទី១៦២៤ ។

[2] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ ស្ទួនពីរនៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១, ឯកសារ E124 ។ សូមបញ្ជាក់ថា សេចក្តីសម្រេចនេះត្រូវបានប្រកាសមោឃភាពដោយអង្គជំនុំជម្រះតុលាការកំពូលនៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ បន្ទាប់ពីមានសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យមានការពង្រីកវិសាលភាពនៃសំណុំរឿង០០២/០១ ។ បច្ចុប្បន្នអង្គជំនុំជម្រះសាលាដំបូងបានចេញដីកាបំបែកសំណុំរឿងថ្មីមួយទៀតនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ បន្ទាប់មានការណែនាំពីអង្គជំនុំជម្រះតុលាការកំពូល ។

[3] សូមមើលប្រតិចារិកសវនាការចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១១ សេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ ខៀវ សំផន ឆ្លើយតបនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញា, និងប្រតិចារិកចុះថ្ងៃទី២៧-២៩-៣០ ខែឧសភា និងថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៣ សេចក្តីថ្លែងការណ៍ផ្ទាល់មាត់របស់ជនជាប់ចោទ ខៀវ សំផន ឆ្លើយតបនឹងសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅអំឡុងពេលសវនាការ ។

[4] «សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣», អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ ឯកសារE284, ទំព័រ១១៩, កំណត់សម្គាល់ជើងទំព័រ២៧០ ។ សូមមើលផងដែរ «បណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន ប្រឆាំងទៅនឹងសេចក្តីសម្រេចលើសំណើសុំដោះលែងឲ្យនៅក្រៅឃុំជាបន្ទាន់ ដោយដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ» ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៣, ឯកសារ E275/2/1, កថាខណ្ឌទី៦៦ ។

[5] វិធាន៩៨(៥) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

[6] វិធាន៩៨(៦) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

[7] «សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣», អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ ឯកសារE284, ទំព័រ១១៩, កំណត់សម្គាល់ជើងទំព័រ២៧០ ។ សូមមើលផងដែរ «បណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន ប្រឆាំងទៅនឹងសេចក្តីសម្រេចលើសំណើសុំដោះលែងឲ្យនៅក្រៅឃុំជាបន្ទាន់ ដោយដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ» ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៣, ឯកសារ E275/2/1,

កថាខណ្ឌទី៦៦ ។

៨ វិធាន១១១(៤) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ វិធាននេះបានបញ្ញត្តិថា “ក្នុងករណីបណ្តឹងសាទុក្ខ ដែលអង្គជំនុំជម្រះតុលាការកំពូលសម្រេចឲ្យរួចផុតពីបទចោទ នោះជនជាប់ចោទត្រូវបានដោះលែងឲ្យមានសេរីភាពភ្លាម លើកលែងតែជននោះត្រូវបានឃុំខ្លួនពីបទល្មើសផ្សេងទៀត” ។

៩ វិធាន៨២(៣) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

១០ សេចក្តីសម្រេចលើសំណើសុំដោះលែងលោក ខៀវ សំផន ឲ្យនៅក្រៅឃុំជាបន្ទាន់, អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣, ឯកសារ E275/1, កថាខណ្ឌទី២១ ។



នួន ជា (ស្តាំ) ក្នុងពិធីលាងសាយភោជន៍ ដើម្បីទទួលគណៈប្រតិភូបរទេស ។ វ៉ន វ៉េត ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកសេដ្ឋកិច្ច អង្គុយនៅខាងឆ្វេងបង្អស់ ។ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ហេតុអ្វីខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ?

## ចាន់ ប្រាថ្នា

នៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៣ នួន ជា បានថ្លែងថា មូលហេតុដែលថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញកាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ព្រោះខ្លាចមានការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកមកលើប្រជាជននៅក្នុងទីក្រុងបន្ទាប់ពីរបប លន់ នល់ ត្រូវបានផ្តួលរំលំ ។ ហេតុផលមួយទៀត គឺដើម្បីឲ្យប្រជាជននៅក្នុងទីក្រុងចូលរួមបង្កបង្កើនផលនៅតាមជនបទ ។[១] ពិតប្រាកដណាស់ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីជាច្រើនរូបបានផ្តល់សក្ខីកម្មដូចៗគ្នានៅ ចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមថា បន្ទាប់ពីយោធាខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញភ្លាម ខ្មែរក្រហមបានប្រកាសឲ្យប្រជាជនចេញពីទីក្រុង ដោយផ្តល់ហេតុផលថា ដើម្បីគេចពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក និងរៀបចំទីក្រុងឲ្យមានរបៀបរៀបរយ ហើយបីថ្ងៃក្រោយទើបអនុញ្ញាតឲ្យចូលទីក្រុងភ្នំពេញវិញ ។

តើមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាពិតជាមានការភ័យខ្លាចថាមានការទម្លាក់គ្រាប់បែកពីសំណាក់សហរដ្ឋអាមេរិក ដូចបានប្រកាសនៅក្នុងអំឡុងពេលជម្លៀសប្រជាជនរាប់លាននាក់ចេញពីទីក្រុង (ដែលជាព្រឹត្តិការណ៍ដ៏គួរឲ្យរន្ធត់ និងរងទុក្ខយ៉ាងធ្ងន់ធ្ងរសម្រាប់ប្រជាជនកម្ពុជា) ឬទេ? ប្រជាជនដែលបានរត់ចូលស្ថានទូតបារាំង អ្នកជំងឺកំពុងសម្រាកក្នុងមន្ទីរពេទ្យជាច្រើន ត្រូវបានបង្ខំឲ្យចាកចេញដោយគ្មានការសណ្តោសប្រណី ។

បើរំឭកទៅដល់សក្ខីកម្មរបស់ នួន ជា ក្នុងសវនាការកាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ បានបង្ហាញឲ្យឃើញថា ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានដឹងយ៉ាងច្បាស់ថា សភាសហរដ្ឋអាមេរិកបានអនុម័តច្បាប់មួយ ដោយហាមឃាត់រដ្ឋាភិបាលរបស់ខ្លួនដែលដឹកនាំដោយប្រធានាធិបតី រីឆាត និចសុន ឲ្យបញ្ចប់ការទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៣ ។[២] គណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាបានវិភាគឃើញថា បើគ្មានជំនួយយោធាផ្នែកកងទ័ពជើងអាកាសរបស់សហរដ្ឋអាមេរិក នោះចលនាតស៊ូរបស់ខ្លួននឹងទទួលបានជ័យជំនះក្នុងពេលឆាប់ៗជាក់ជាមិនខាន ព្រោះទាហានរបស់ លន់ នល់ កាន់តែចុះខ្សោយទៅៗជាលំដាប់ ។[៣] ច្បាស់ជាងនេះទៀត ក្នុងសវនាការថ្ងៃដដែលនោះ នួន ជា បានបញ្ជាក់ថា នៅក្នុងកិច្ចប្រជុំពាក់កណ្តាលឆ្នាំ១៩៧៤ (កិច្ចប្រជុំរួមរវាងគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា ដែលបានសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងតាមទីរួមខេត្ត) អង្គប្រជុំបានឯកភាពគ្នាថា *«បើបក្សកុម្មុយនីស្តកម្ពុជាដឹកនាំចលនាតស៊ូរំដោះជាតិរំដោះប្រជាជនបាន គឺយើងសម្រេចបានភារកិច្ចធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ[៤] បានមួយចំនួនសំខាន់ហើយ គឺយើងបានដោះស្រាយទំនាស់បដិបក្ខ គឺទំនាស់ស្លាប់រស់ជាមួយសហរដ្ឋអាមេរិក និងរបប លន់ នល់ បានជាដំបូង ។ សហរដ្ឋអាមេរិកមិននៅជាគូអង្គបដិបក្ខទៀតទេ»* ។[៥]

ដូច្នេះ តើអ្វីជាហេតុផលពិតប្រាកដនៃការសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ?

សេចក្តីសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺពុំមែនជារឿងដែលកើតឡើងភ្លាមៗ ឬដោយចៃដន្យឡើយ ។ តាមរយៈសក្ខីកម្មរបស់ នួន ជា សេចក្តីសម្រេចនេះត្រូវបានអនុម័តជាឯកច្ឆន្ទនៅក្នុងកិច្ចប្រជុំរួមរវាងគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា (ហៅកាត់ថា អង្គប្រជុំ) ក្នុងឆ្នាំ១៩៧៤ ។[៦] ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានសម្រេចជាឯកច្ឆន្ទថា *«ក្នុងករណីរំដោះបានទីក្រុងភ្នំពេញនោះត្រូវជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ និងទីរួមខេត្តជាបណ្តោះអាសន្ន ដើម្បីពិនិត្យតាមដានសភាពការណ៍មួយរយៈសិន ជាពិសេសសកម្មភាពរបស់វៀតណាម»* ។[៧] ហេតុផលទីមួយថ្នាក់ដឹកនាំ បក្សកុម្មុយនីស្តកម្ពុជាវិភាគឃើញថា នៅពេលរំដោះបានទីក្រុងភ្នំពេញ ទាហាន លន់ នល់ មួយចំនួននឹងសម្ងំលាក់ខ្លួននៅក្នុងទីក្រុង ដែល

អាចបង្កការរំខាន ឬវាយឆ្មក់មកលើកម្លាំងទ័ព និងប្រជាជនរបស់ខ្លួន ។[៨] ហេតុផលទីពីរពាក់ព័ន្ធនឹងការពិនិត្យតាមដានសកម្មភាពរបស់វៀតណាម ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា មានការព្រួយបារម្ភថា វៀតណាមអាចនឹងវាយដណ្តើមកាន់កាប់ទីក្រុងភ្នំពេញ បន្ទាប់ពីវៀតណាមខាងជើងរំដោះបានវៀតណាមខាងត្បូង ។[៩] ថ្នាក់ដឹកនាំខ្មែរក្រហមបានវិភាគថា បន្ទាប់ពីចលនាតស៊ូរំដោះជាតិ រំដោះប្រជាជនទទួលបានជោគជ័យ វៀតណាមនឹងក្លាយទៅជាគូបដិបក្ខ (ទំនាស់ស្លាប់រស់) របស់ខ្លួន គឺពុំមែនសហរដ្ឋអាមេរិកទៀតឡើយ ។[១០]

ហេតុផលមួយទៀតនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺដើម្បីអនុវត្តផែនការពង្រីកសហករណ៍នៅតាមមូលដ្ឋាន ។ តាមរយៈសេចក្តីសម្រេចនៅក្នុងកិច្ចប្រជុំពាក់កណ្តាលឆ្នាំ ១៩៧៤ បានបង្ហាញថា បន្ទាប់ពីវាយដណ្តើមកាន់កាប់បានទីក្រុងភ្នំពេញនោះបក្សកុម្មុយនីស្តកម្ពុជានឹងជម្លៀសប្រជាជនទៅតាមភូមិភាគនីមួយៗ ដែលភូមិភាគទាំងនោះត្រូវបានណែនាំឲ្យត្រៀមខ្លួនរួចជាស្រេចក្នុងការទទួលយកកម្លាំងបន្ថែមដើម្បីបង្កបង្កើនផល ។ ក្នុងកិច្ចប្រជុំនោះ ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានណែនាំដល់កម្មាភិបាលដែលបានចូលរួមប្រជុំទាំងអស់ ឲ្យទៅពិភាក្សាជាមួយ គណៈភូមិភាគ គណៈតំបន់ គណៈស្រុក អំពីលទ្ធភាពក្នុងការទទួលយកប្រជាជនដែលនឹងត្រូវជម្លៀសចេញពីទីក្រុងភ្នំពេញ ។[១១]

ហេតុផលខាងលើនេះ មានភាពស៊ីសង្វាក់គ្នាយ៉ាងខ្លាំងទៅនឹងបទខុទ្ទេសនាមរបស់ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដែលត្រូវបានចុះផ្សាយក្នុងទស្សនាវដ្តីទង់បដិវត្ត ។ យោងតាមទស្សនាវដ្តីទង់បដិវត្តលេខពិសេសបោះពុម្ពផ្សាយសម្រាប់ខែធ្នូ-មករា ឆ្នាំ ១៩៧៦-១៩៧៧ (ចុះផ្សាយបទខុទ្ទេសនាមរបស់ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា[១២] ដែលបានផ្ញើនៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៧៧ ក្នុងឱកាសថ្ងៃបុណ្យរំឭកខួបលើកទី៩ នៃកំណើតកងទ័ពបដិវត្តកម្ពុជា) បានបង្ហាញថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺជាការអនុវត្ត«មាគ៌ាពង្រីងប្រជាជនពីខ្មាំង» ដែលបក្សកុម្មុយនីស្តកម្ពុជាធ្លាប់បានអនុវត្តកន្លងមក ។ ក្នុងបទខុទ្ទេសនាមនោះបានលើកឡើងថា «...មាគ៌ាយើង គឺដណ្តើមប្រជាជន មួយនាក់ក៏យក ពីរនាក់ក៏យក មួយរយនាក់ក៏យក មួយពាន់នាក់ក៏យក រហូតដល់ដណ្តើមប្រជាជនពីទីក្រុងភ្នំពេញទៀត...» ។ បក្សកុម្មុយនីស្តកម្ពុជាយល់ឃើញថា ប្រសិនបើខ្មាំងមានប្រជាជន ខ្មាំងនឹងមានយោធា និងសេដ្ឋកិច្ច ។ ផ្ទុយទៅវិញ ប្រសិនបើខ្មាំងពុំមានប្រជាជនទេ ខ្មាំងក៏ពុំមានយោធា និងសេដ្ឋកិច្ចដែរ ។[១៣] ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាលើកយកបទពិសោធយ៉ាងល្អពាក់ព័ន្ធនឹងការជម្លៀសយកប្រជាជនចេញពីទីក្រុងខេត្តនានាៗ បន្ទាប់ពីវាយឈ្នះទាហាន លន់ នល់ ក្នុងអំឡុងឆ្នាំ១៩៧៤ ដោយបានលើកឡើងថា «[...] ឧទាហរណ៍ ៖ យើងរំដោះខេត្តក្នុងឆ្នាំ១៩៧៤ ។ យើងដកយកប្រជាជនទាំងអស់ ។ ដល់វាដណ្តើមវិញ វាគ្មានកម្លាំង ។ គ្មានកម្លាំងប្រជាជន គ្មានកម្លាំងសេដ្ឋកិច្ច គ្មានកម្លាំងយោធា» ។[១៤]

គួរបញ្ជាក់ថា ខ្លឹមសារនៃមាគ៌ាពង្រីងប្រជាជនពីខ្មាំង ដែលថា «...មាគ៌ាយើង គឺដណ្តើមប្រជាជនមួយនាក់ក៏យក ពីរនាក់ក៏យក មួយរយនាក់ក៏យក មួយពាន់នាក់ក៏យក រហូតដល់ដណ្តើមប្រជាជនពីទីក្រុងភ្នំពេញទៀត...») ត្រូវបានចៅក្រម ហ្សង់ម៉ាក ឡាវែង ដកស្រង់មកសួរ នួន ជា នៅក្នុងសវនាការថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ ២០១២ ។ នួន ជា បានពន្យល់ថា «គោលការណ៍សង្គ្រាមឈ្លបប្រជាជននៅខាងណា ខាងហ្នឹងឈ្នះ ។ យើងត្រូវពង្រីងប្រជាជនពីខ្មាំង ។ ដូច្នោះប្រជាជននៅខាងយើងឧបត្ថម្ភយើង ប្រជាជននៅខាងខ្មាំងឧបត្ថម្ភខ្មាំង ។ [...]ដូច្នេះត្រូវប្រមូលប្រជាជនឲ្យបានច្រើនជាអតិបរមា ពង្រីងប្រជាជនពីខ្មាំង» ។[១៥]

សរុបសេចក្តីមក យោងតាមសក្ខីកម្មរបស់ នួន ជា នៅថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១១ បានបង្ហាញថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺត្រូវបានសម្រេចតាំងពីពាក់កណ្តាលឆ្នាំ ១៩៧៤ មកម្លេះ ហើយនៅតាមភូមិភាគនីមួយៗត្រូវបានណែនាំរួចជាស្រេចក្នុងការទទួលយកប្រជាជនទាំងនោះ ។ មានហេតុផលពីរយ៉ាងដែលនាំឲ្យមានការសម្រេចនេះ ៖ ទី១ គឺដើម្បីជៀសវាងមិនឲ្យទាហាន លន់ នល់ នៅសម្ងំលាក់ខ្លួនក្នុងទីក្រុង ដែលអាចបង្កការរំខាន ឬវាយឆ្មក់មកលើកម្លាំងរបស់ខ្លួន និងដើម្បីពិនិត្យមើលសកម្មភាពរបស់វៀតណាម ដោយសារមានការព្រួយបារម្ភថា វៀតណាមអាចនឹងវាយដណ្តើមកាន់កាប់ទីក្រុងភ្នំពេញ បន្ទាប់

ពីវៀតណាមខាងជើងរំដោះបានវៀតណាមខាងត្បូង ។ ទី២ គឺដើម្បីពង្រឹង និងពង្រីកសហករណ៍បង្កបង្កើនផលនៅតាមមូលដ្ឋាន ដែលថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានសម្រេចនៅក្នុងកិច្ចប្រជុំពាក់កណ្តាលឆ្នាំ១៩៧៤ ។

បន្ថែមលើនេះទៀត យោងតាមបទឧទ្ទេសនាមរបស់ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដែលត្រូវបានចុះផ្សាយក្នុងទស្សនាវដ្តីទង់បដិវត្តលេខពិសេសនោះ ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺជាការអនុវត្តមាគ៌ាយុទ្ធសាស្ត្រក្នុងការដណ្តើមយកកម្លាំងប្រជាជនពីខ្មាំង ឬនិយាយម្យ៉ាងទៀតថា គឺដើម្បីការពារមិនឲ្យមានការដណ្តើមយកប្រជាជនវិញ ក្នុងករណីមានខ្មាំងវាយចូលកាន់កាប់ទីក្រុងភ្នំពេញ ។


ខៀវ សំផន នៅក្នុងបន្ទប់សវនាការ

## កំណត់សម្គាល់

១ សេចក្តីថ្លែងការណ៍របស់ នួន ជា នៅក្នុងសវនាការថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៣ ។ អាចរកបាននៅ ៖ http://www.eccc.gov.kh/blog/2013/07/10/26785

២ សូមមើលប្រតិចារិកសវនាការថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារលេខ E1/14.1 ត្រង់ទំព័រ ៧៣ ។ អាចរកបានក្នុងគេហទំព័រ ៖ http://www.eccc.gov.kh/document/court/16108

៣ ឯកសារលេខ E1/41.1 ត្រង់ទំព័រ៧៣ ។

៤ អ្វីទៅដែលហៅថា «បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ» សូមមើល ៖ http://d.dccam.org/Projects/ECCC_Trial_Observation/pdf/Policy_of_Democracy_Nation.pdf

៥ ឯកសារលេខ E1/14.1 ត្រង់ទំព័រ៧៥ បន្ទាត់ទី១១-១៤ ។

៦ សូមមើលប្រតិចារិកសវនាការថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១ ឯកសារលេខ E1/22.1 ត្រង់ទំព័រ២ បន្ទាត់ ទី២-៥ ។ អាចរកបានក្នុងគេហទំព័រ ៖ http://www.eccc.gov.kh/document/court/16381

៧ ឯកសារលេខ E1/14.1 ត្រង់ទំព័រ៧៧ បន្ទាត់ទី១៨-២០ ។

៨ ឯកសារលេខ E1/14.1 ត្រង់ទំព័រ៧៦ បន្ទាត់ទី១-៧ ។

៩ ឯកសារលេខ E1/14.1 ត្រង់ទំព័រ៦៤ (បន្ទាត់ទី២-៥) ទំព័រ៧៤ (បន្ទាត់ទី១០-១៩) និងទំព័រ៧៥ (បន្ទាត់ ១៦-២០) ។

១០ ឯកសារលេខ E1/14.1 ត្រង់ទំព័រ៧៥ បន្ទាត់ទី១០-២២ ។

១១ ឯកសារលេខ E1/14.1 ត្រង់ទំព័រ៧៨ បន្ទាត់ទី៤-៩ ។

១២ យោងតាមការលើកឡើងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អេនឌ្រូ ខេលី បទឧទ្ទេសនាមនេះ គឺត្រូវបានថ្លែងដោយ នួន ជា ។ ឯកសារលេខ E1/14.1 ទំព័រ១៤

១៣ «ទស្សនាវដ្តីទង់បដិវត្តលេខពិសេស ធ្នូ-មករា ១៩៧៦-៧៧» ត្រង់ទំព័រទី៧០ ។

១៤ «ទស្សនាវដ្តីទង់បដិវត្តលេខពិសេស ធ្នូ-មករា ១៩៧៦-៧៧» ត្រង់ទំព័រទី៧១ ។

១៥ កំណត់ហេតុសវនាការលើសំណុំរឿង០០២ ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារលេខ E1/40.1 ត្រង់ទំព័រ ១៨-១៩ ។ អាចរកបានក្នុងគេហទំព័រ ៖ http://www.eccc.gov.kh/document/court/16788

# តើចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីមានទម្ងន់ និងតម្លៃជាភស្តុតាង ដើម្បីចោទប្រកាន់លើជនជាប់ចោទដែរឬទេ?

**លីម ជ័យទ័ត្ត**

នៅក្នុងបរិបទនៃសាលាក្តីខ្មែរក្រហម ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយគាំទ្រការចោទប្រកាន់ ។[១] ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម អាចឲ្យជនរងគ្រោះចូលរួមជាភាគីនៅក្នុងដំណើរការជំនុំជម្រះក្តីព្រហ្មទណ្ឌលើជនជាប់ចោទ ដើម្បីគាំទ្រសហព្រះរាជអាជ្ញា និងដើម្បីទាមទារសំណងផ្លូវចិត្ត និងសមូហភាពចំពោះព្យសនកម្មដែលបង្កឡើងដោយផ្ទាល់ពីឧក្រិដ្ឋកម្មនានា ដែលជនជាប់ចោទត្រូវបានរកឃើញថា មានពិរុទ្ធភាព ។[២] សិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធីខាងលើរួមបញ្ចូលទាំងសិទ្ធិបង្ហាញភស្តុតាងដែរ ។[៣]

ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនធំ ត្រូវបានជ្រើសរើសដោយអង្គជំនុំជម្រះសាលាដំបូង ដើម្បីឲ្យមកផ្តល់សក្ខីកម្មជាសំខាន់នៅក្នុងផ្នែកនៃការជម្លៀសប្រជាជនដោយបង្ខំនៃសំណុំរឿង០០២/០១ ។ នៅក្នុងផ្នែកនៃសវនាការនេះ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់ជូននូវភស្តុតាងសំខាន់ៗដែលនឹងមានប្រយោជន៍ក្នុងការបង្ហាញអំពីឧក្រិដ្ឋកម្មនៃការជម្លៀសប្រជាជនដោយបង្ខំ និងអំពីបរិបទដែលឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្តឡើង ។ សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីផ្តល់នូវសេចក្តីបន្ថែមដ៏សំខាន់មួយទៅលើភស្តុតាងផ្សេងៗទៀតដែលបានបង្ហាញនៅក្នុងអំឡុងពេលនៃសវនាការ ។[៤] ដោយមានឋានៈជាភាគីនៃរឿងក្តី ដើមបណ្តឹងរដ្ឋប្បវេណីមិនចាំបាច់ធ្វើសម្បថមុននឹងផ្តល់សក្ខីកម្មទេ ។[៥] ប៉ុន្តែ កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១១ ក្រុមមេធាវីការពារក្តីរបស់ អៀង សារី បានដាក់ញត្តិមួយស្នើសុំឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើការផ្តល់សក្ខីកម្មនៅក្រោមសម្បថ បើកាលណាត្រូវបានជ្រើសរើសឲ្យមកផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងអង្គហេតុសំខាន់ៗ ។ ញត្តិនេះសំអាងថា សេចក្តីថ្លែងណាមួយរបស់ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានប្រើប្រាស់តែនៅក្នុងការកំណត់ពីការអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនោះលើបញ្ហាសំណងតែប៉ុណ្ណោះ ហើយបើមានការកោះហៅដើមបណ្តឹងរដ្ឋប្បវេណីរូបណាមួយឲ្យមក ផ្តល់សក្ខីកម្មលើបញ្ហានានាពាក់ព័ន្ធនឹងសំណុំរឿងព្រហ្មទណ្ឌ ដើមបណ្តឹងរដ្ឋប្បវេណីរូបនោះត្រូវតែផ្តល់សក្ខីកម្មនៅក្រោមសម្បថ ។[៦] ដូច្នេះ សក្ខីកម្មដែលមិនបានធ្វើសម្បថ គួរត្រូវបានផ្តល់នូវទម្ងន់ និងតម្លៃជាភស្តុតាង ទាបជាងសក្ខីកម្មដែលបានធ្វើសម្បថ ។[៧]

ឆ្លើយតបនឹងញត្តិរបស់ក្រុមមេធាវីការពារក្តី អៀង សារី សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានសង្កត់ធ្ងន់ថា ដើមបណ្តឹងរដ្ឋប្បវេណី គឺជាភាគីស្មើគ្នាទាំងស្រុងនៅក្នុងកិច្ចដំណើរការនីតិវិធី និងអាចនឹងផ្តល់ភស្តុតាងនៅក្រោមលក្ខខណ្ឌតែមួយដូចគ្នានឹងជនត្រូវចោទដែរ ។ ការតម្រូវឲ្យដើមបណ្តឹងរដ្ឋប្បវេណីផ្តល់សក្ខីកម្មនៅក្រោមសម្បថ នៅពេលធ្វើការផ្តល់ភស្តុតាង គឺជាការកែប្រែដ៏ធំមួយទៅលើវិធានផ្ទៃក្នុង ។[៨] វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ពុំបានតម្រូវឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសម្បថមុនពេលចូលមកផ្តល់សក្ខីកម្ម ដូចជាសាក្សីទេ ។[៩]

សហព្រះរាជអាជ្ញា បានអះអាងនៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួន ពាក់ព័ន្ធនឹងការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានធ្វើតាមបែបបទច្បាប់ស៊ីវិល ហើយម្យ៉ាងទៀត បានធ្វើឲ្យខុសគ្នារវាងសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ជនជាប់ចោទ និងសាច់ញាតិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬជនជាប់ចោទ ។ ដូចគ្នានឹងភាគីដទៃទៀតនៃកិច្ចដំណើរការនីតិវិធីដែរ ដើមបណ្តឹងរដ្ឋប្បវេណីពុំត្រូវបានតម្រូវឲ្យ

ធ្វើការផ្តល់សក្ខីកម្មនៅក្រោមសម្បថទេ ។[១០] សហព្រះរាជអាជ្ញាបានលើកឡើងបន្ថែមថា អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានថ្លែងពីមុនថា សក្ខីកម្មដែលមិនបានធ្វើសម្បថ ដែលធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាជនជាប់ចោទដែរ គឺជាភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងត្រូវធ្វើការវាយតម្លៃទៅលើទម្ងន់ និងតម្លៃជាភវនីយភាពនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្រោមបទដ្ឋានតែមួយដូចគ្នានឹងសក្ខីកម្មដែលបានផ្តល់ដោយសាក្សីដូច្នោះដែរ ។[១១] ប្រសិនបើទម្ងន់ ឬតម្លៃភ័ស្តុតាងនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានសន្មតជាស្វ័យប្រវត្តិថា មានតម្លៃទាបជាង ដោយសារតែដើមបណ្តឹងរដ្ឋប្បវេណីមិនបានស្បថពេលផ្តល់សក្ខីកម្ម នឹងអាចក្លាយទៅជាការរំលោភលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួម និងផ្តល់ភស្តុតាង ។[១២] ជំនួសឲ្យការវាយតម្លៃលើទម្ងន់ និងតម្លៃជាភ័ស្តុតាងតាមរយៈការធ្វើសម្បថ អង្គជំនុំជម្រះសាលាដំបូងគួរតែពិចារណាលើទម្ងន់ និងតម្លៃជាភ័ស្តុតាងនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្អែកលើករណីនីមួយៗតាមរយៈការសួរដេញដោលដោយចៅក្រម និងមេធាវី ។[១៣]

ការអនុវត្តនាពេលកន្លងមកក្នុងសំណុំរឿង០០១ មានដើមបណ្តឹងរដ្ឋប្បវេណីចំនួន២២នាក់ បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដោយពុំចាំបាច់ធ្វើសម្បថ ។ អង្គជំនុំជម្រះបានធ្វើការវាយតម្លៃទៅលើសេចក្តីថ្លែងនានារបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ថាមានតម្លៃជាភ័ស្តុតាង នៅចំពោះមុខអង្គជំនុំជម្រះ ហើយបានធ្វើការពិចារណា និងប្រើប្រាស់សក្ខីកម្មទាំងនោះ ដើម្បីគាំទ្រ ការសម្រេចមួយចំនួននៅក្នុងសាលក្រមនៃសំណុំរឿង០០១ ។[១៤] ប៉ុន្តែទម្ងន់ និងតម្លៃជាភស្តុតាងនៃសក្ខីកម្មទាំងនោះ គឺប្រែប្រួលទៅតាមការវាយតម្លៃរបស់អង្គជំនុំជម្រះដោយផ្អែកលើវិធីសាស្ត្ររួម មួយដែលបានវាយតម្លៃនៅក្នុងគ្រប់កាលៈទេសៈទាំងអស់អំពីភាពគ្រប់គ្រាន់នៃភស្តុតាង ហើយតាមការវាយតម្លៃដែលមានសំអាងហេតុអំពីភ័ស្តុតាង ។ ការសង្ស័យណាមួយអំពីពិរុទ្ធភាព ត្រូវបានបកស្រាយជាប្រយោជន៍ដល់ជនជាប់ចោទ ។[១៥]

ដូចគ្នានេះដែរ សម្រាប់សំណុំរឿង០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ទម្ងន់ដែលត្រូវផ្តល់ទៅឲ្យសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី នឹងត្រូវបានវាយតម្លៃទៅតាមករណីនីមួយៗ ដោយពិនិត្យទៅលើភាពអាចជឿជាក់បាននៃសក្ខីកម្មនោះ ។ បន្ទាប់ពីការវាយតម្លៃដែលមានសំអាងហេតុ អំពីភ័ស្តុតាង វិមតិសង្ស័យអំពីពិរុទ្ធភាព នឹងត្រូវបកស្រាយជាប្រយោជន៍ដល់ជនជាប់ចោទ ។[១៦]

ជារួម ដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមផ្តល់សក្ខីកម្មនៅក្នុងសវនាការដោយពុំចាំបាច់ធ្វើសម្បថ ហើយសក្ខីកម្មនោះនៅតែមានទម្ងន់ និងតម្លៃជាភស្តុតាង ដើម្បីគាំទ្រការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ ។ ប៉ុន្តែសក្ខីកម្មទាំងនោះ មានទម្ងន់ និងតម្លៃប៉ុណ្ណា គឺអាស្រ័យទៅលើភាពគួរឲ្យជឿជាក់បាននៃសក្ខីកម្ម ដែលដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់នៅចំពោះមុខអង្គជំនុំជម្រះ ។

---

## កំណត់សម្គាល់

១ សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្របតាមវិធាន៩២ ពាក់ព័ន្ធនឹងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី, ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣, កថាខណ្ឌ១៤, ឯកសារ E267 (“សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា”) ។

២ សេចក្តីសម្រេចលើសំណើសុំកោះហៅសារជាថ្មីដើមបណ្តឹងរដ្ឋប្បវេណី TCCP-187 និងសុំឲ្យពិនិត្យឡើងវិញលើបែបបទពាក់ព័ន្ធនឹងសក្ខីកម្មស្តីពីការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី និងសំណើ និងចម្លើយតបនានាដែលពាក់ព័ន្ធ (E240, E240/1, E250, E250/1, E267, E267/1 និងE267/2) ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៣, កថាខណ្ឌ១៣, ឯកសារ E267/3 (“សេចក្តីសម្រេចលើសំណើសុំកោះហៅសារជាថ្មី”) ។ សូមមើលផងដែរ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ៦៦០, ឯកសារ E188 ។

៣ សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ១៥ ។

៤ ដដែលដូចខាងលើ, ត្រង់កថាខណ្ឌ៣ ។

៥ ចម្លើយតបទៅនឹងសារណារបស់សហព្រះរាជអាជ្ញាទាក់ទង

នឹងតម្លៃជាភស្តុតាងនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី, ថ្ងៃទី៨ ខែមីនា ឆ្នាំ២០១៣, កថាខណ្ឌ៨, ឯកសារ E267/1 («ចម្លើយតបទៅនឹងសារណាអនុលោមតាមវិធាន៩២») ។

៦ សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ៧ ។ សូមមើលផងដែរ សំណើរបស់ អៀង សារី ស្នើឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសម្បថ ប្រសិនបើត្រូវបានអនុញ្ញាតឲ្យផ្តល់សក្ខីកម្មអំពីអ្វីដែលពួកគាត់បានដឹងពីរឿងក្តីព្រហ្មទណ្ឌ, ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១, ឯកសារ E57 ។

៧ ចម្លើយតបរបស់ អៀង សារី ទៅនឹងសារណារបស់សហព្រះរាជអាជ្ញាទាក់ទងនឹងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី, ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៣, ឯកសារ E267/2 ។ សូមមើលផងដែរ សេចក្តីសម្រេចលើសំណើសុំកោះហៅសារជាថ្មី, កំណត់សម្គាល់ជើងទំព័រ៤២ (ក្នុងចំណោមចំណុចផ្សេងៗទៀតបានលើកឡើងថា សក្ខីកម្មដែលមិនបានធ្វើសម្បថគួរត្រូវបានផ្តល់នូវទម្ងន់ និងតម្លៃជាភស្តុតាងទាបជាងសក្ខីកម្មដែលបានធ្វើសម្បថ) ។

៨ សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ៨ ។

៩ សូមមើលវិធាន២៣(៤) នៃវិធានផ្ទៃក្នុង («ដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវបានគេសួរដូចជាសាក្សីធម្មតាក្នុងសំណុំរឿងតែមួយនោះទេ ហើយស្របតាមវិធាន៦២ ដែលទាក់ទងនឹងដីកាចាត់ឲ្យស៊ើបសួរជំនួស អាចត្រូវបានគេស្តាប់ចម្លើយតែប៉ុណ្ណោះ ដោយស្ថិតក្រោមលក្ខខណ្ឌ ដូចគ្នាទៅនឹងជនត្រូវចោទ ឬជនជាប់ចោទដែរ») ។ សូមអានផងដែរ វិធាន២៤(២) នៃវិធានផ្ទៃក្នុង ដែលចែងពីសមាជិកគ្រួសារជិតដិតរបស់ជនជាប់ចោទ ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីដែលឆ្លើយដោយមិនចាំបាច់ធ្វើសម្បថ ។ សូមអានបន្ថែមមាត្រាស្រដៀងគ្នា នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា១៥៦ (សាក្សីមិនស្បថ), ៣១២ (វិសមិតភាពរវាងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី និងឋានៈជាសាក្សី), ៣២៦ (ការស្តាប់ចម្លើយរបស់ភាគី), ៣២៧ (ការជំទាស់ទៅនឹងការស្តាប់ចម្លើយរបស់សាក្សី) ។

១០ សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ៤ ។

១១ ដដែលដូចខាងលើ, កថាខណ្ឌ៥ ។ សូមមើលផងដែរសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ នៅត្រង់កថាខណ្ឌ៥១ និង៥២, ឯកសារ E188 ។

១២ ដដែលដូចខាងលើ, កថាខណ្ឌ១៧ ។

១៣ ដដែលដូចខាងលើ, កថាខណ្ឌ២២ ។ សូមមើលផងដែរ «សេចក្តីសម្រេចលើសំណើសុំកោះហៅសារជាថ្មី», កថាខណ្ឌ១១ ។

១៤ ដដែលដូចខាងលើ, កថាខណ្ឌ៦ ។ សូមមើល សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ នៅត្រង់ កថាខណ្ឌ៥២-៥៥, ឯកសារ E188 ។ សូមមើលផងដែរ «សេចក្តីសម្រេចលើសំណើសុំកោះហៅសារជាថ្មី», កថាខណ្ឌ២១ ។

១៥ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿង កាំង ហ្គេកអ៊ាវ ហៅ ឌុច, ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, កថាខណ្ឌ៤៥, ឯកសារ E188 ។

១៦ «សេចក្តីសម្រេចលើសំណើសុំកោះហៅសារជាថ្មី», កថាខណ្ឌ២២ ។



ខៀវ សំផន លើកដៃសំពះជនរងគ្រោះក្នុងអំឡុងពេលសវនាការស្តីពីការថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី

## ពន្យល់ពាក្យសំខាន់

ជនរងគ្រោះ : សំដៅទៅលើរូបបុគ្គល ឬនីតិបុគ្គលដែលបានទទួលរងព្យសនកម្ម ដោយសារអំពើឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការនៃអង្គជំនុំជម្រះ វិសាញ្ញ ។

ដើមបណ្តឹងរដ្ឋប្បវេណី : សំដៅទៅលើជនរងគ្រោះដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ ត្រូវបានប្រកាសទទួលស្គាល់ដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ ។

ជនជាប់ចោទ : សំដៅទៅលើបុគ្គល ដែលត្រូវចោទប្រកាន់ដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ ។

ភាគី : សំដៅទៅលើសហព្រះរាជអាជ្ញា ជនត្រូវចោទ ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ។

អង្គជំនុំជម្រះវិសាមញ្ញ : សំដៅទៅលើតុលាការពិសេស នៅក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជា ដែលបង្កើតឡើងដោយច្បាប់ស្តីពីការកាត់ទោសឧក្រិដ្ឋកម្មក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។


មជ្ឈមណ្ឌលឯកសារកម្ពុជា

ប្រអប់សំបុត្រលេខ១១១០, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥

ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

អ៊ីម៉ែល : dccam@online.com.kh

គេហទំព័រ : www.dccam.org ឬ www.cambodiatribunal.org



គម្រោងនេះទទួលជំនួយហិរញ្ញវត្ថុពីមូលនិធិ

*John D. and Catherine T. MacArthur Foundation and*

*British Embassy-Cambodia.*


| ល.រ | ឈ្មោះដើម | ឈ្មោះបដិវត្ត | លេខសម្ងាត់ | ប្រភពឯកសារ |
|---|---|---|---|---|
| ១ | សាឡុត ស | ប៉ុល ពត, បងប៉ុល, បងទី១, | ៨៧០, ៨៧ | D427, E1/56.1 |
| ២ | នួន ជា | នួន ជា, បងនួន, បងទី២ | (អត់ដឹង) | D427 |
| ៣ | គឹម ត្រាង | អៀង សារី, វ៉ាន់ | (អត់ដឹង) | D427, E1/21.1 |
| ៤ | ខៀវ សំផន | ហែម, ខាង, ណន | (អត់ដឹង) | D427 |
| ៥ | សុន សេន | ខៀវ, ឃឹម | ៨៩, ៦២ | E1/54.1 |



**ឆាយ ឈុនលី**

បរិញ្ញាបត្រច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**លឹម ជ័យវ័ត្ត**

បរិញ្ញាបត្រច្បាប់ និងបរិញ្ញាបត្រសេដ្ឋកិច្ច ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងជាជ័យលាភីថ្នាក់ជាតិ ទទួលបានពានរង្វាន់មេដាយមាស ក្នុងការប្រកួតសរសេរការប្រឌិត ឆ្នាំ២០១០ ។



**ឌី សុជាតា**

បរិញ្ញាបត្រច្បាប់ សិក្សាជាភាសាអង់គ្លេស ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**ចាន់ ប្រាថ្នា**

បរិញ្ញាបត្រច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



ទិដ្ឋភាពផ្សារថ្មី ថតក្នុងខែសីហា ឆ្នាំ១៩៧៨ ដោយគណៈប្រតិភូមកពីប្រទេស ស៊ុយអែត ។
(បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារកម្ពុជា រក្សាសិទ្ធិ ខែសីហា ឆ្នាំ២០១៣